ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផលការងារ
# ក្រសួងធនធានទឹក និងឧតុនិយម
# ប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តឆ្នាំ២០២៦

ខែ មីនា ឆ្នាំ ២០២៦

មាតិកា


**មុព្វកថា** ........ ១

**១. សេចក្តីផ្តើម** ........ ៣

**២. គោលនយោបាយជាតិលើវិស័យធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា** ........ ៤

**៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០២៤-២០២៨** ........ ៧

**៤. លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២៥** ........ ៩

**៤.១. ការងាររដ្ឋបាល អភិវឌ្ឍន៍ធនធានមនុស្ស និងហិរញ្ញវត្ថុ** ........ ៩

៤.១.១. ការងាររដ្ឋបាល និងធនធានមនុស្ស ........ ៩

៤.១.២. ការងារការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៣

៤.១.៣. ការងារផែនការ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ១៨

៤.១.៤. ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម ........ ២៦

**៤.២. ការងារអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងឧតុនិយម** ........ ៣០

៤.២.១. ការងារធារាសាស្ត្រកសិកម្ម ........ ៣០

៤.២.២. ការងារវិស្វកម្មធនធានទឹក ........ ៣៨

៤.២.៣. ការងារជលសាស្ត្រ និងទន្លេ ........ ៤៣

៤.២.៤. ការងារឧតុនិយម ........ ៤៩

៤.២.៥. ការងារសហគមន៍កសិករប្រើប្រាស់ទឹក ........ ៥០

៤.២.៦. ការងារគ្រប់គ្រង និងអភិរក្សធនធានទឹក ........ ៥៤

៤.២.៧. ការងារទឹកស្អាត និងអនាម័យ ........ ៥៧

**៤.៣. ការរួមចំណែករបស់យេនឌ័រក្នុងការអភិវឌ្ឍ និងគ្រប់គ្រងវិស័យធនធានទឹក** ........ ៦១

**៥. បញ្ហាប្រឈម** ........ ៦៤

**៦. សេចក្តីសន្និដ្ឋាន** ........ ៦៥

**៧. ទិសដៅអនុវត្តឆ្នាំ២០២៦** ........ ៦៧

**៨. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ** ........ ៧៥

**៩. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងធនធានខ្សាច់** ........ ៨០

# បុព្វកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអនេក ក្នុងការដាក់ជូននូវ «របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅអនុវត្តឆ្នាំ២០២៦» របស់ក្រសួងធនធានទឹក និងឧតុនិយម។ របាយការណ៍នេះ គឺជាឯកសារសមិទ្ធផលផ្លូវការនៃអង្គសន្និបាតប្រចាំឆ្នាំលើកទី៣ ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវវឌ្ឍនភាព ការងារសម្រេចបាន និងបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងរយៈពេលមួយឆ្នាំកន្លងទៅ។ ទន្ទឹមនឹងនេះ របាយការណ៍ក៏បានកំណត់នូវទិសដៅយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ឆ្នាំ២០២៦ ក្នុងគោលដៅជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម ឱ្យកាន់តែមានស័ក្តិសិទ្ធិភាព ដើម្បីរួមចំណែកដល់ការសម្រេចបាននូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៧ នៃរដ្ឋសភា សំដៅធានាឱ្យបាននូវសន្តិសុខទឹក និងការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី និងបន្តដឹកនាំប្រកបដោយថាមពល និងចក្ខុវិស័យវែងឆ្ងាយដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងធនធានទឹក និងឧតុនិយម បានប្រកាន់ខ្ជាប់នូវគោលនយោបាយជាតិព្រមទាំងខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការអនុវត្ត «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម ២០២៤-២០២៨»។ ក្នុងស្មារតីរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំដៅកាត់បន្ថយភាពក្រីក្រ និងឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ក្រសួងបានជំរុញល្បឿននៃការកែទម្រង់អភិបាលកិច្ច តាមរយៈការវិភាគមុខងារស្នូល និងមុខងារគាំទ្រ ព្រមទាំងការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរឡើង។

ទន្ទឹមនឹងនេះ ក្រសួងបាននិងកំពុងពង្រឹងការងាររៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព តាមរយៈការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (២០២៦-២០២៨) និងការកសាងលិខិតបទដ្ឋានគតិយុត្តនានា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺដើម្បីធានានូវការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹកប្រកបដោយបរិយាបន្ន ធានាសន្តិសុខទឹកសម្រាប់គ្រប់វិស័យ និងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយធម្មជាតិ ជាពិសេសគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុសកល។

វិស័យធនធានទឹក និងឧតុនិយម បានដើរតួនាទីជាឆ្អឹងខ្នងយ៉ាងសំខាន់ក្នុងការកាត់បន្ថយគ្រោះមហន្តរាយ និងជាថ្នាលដ៏រឹងមាំសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ តាមរយៈការអនុវត្តការងារជួសជុល ស្ដារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ព្រមទាំងប្រព័ន្ធការពារទឹកជំនន់ និងទំនប់ការពារទឹកប្រៃក្នុងឆ្នាំ២០២៥ ក្រសួងបានពង្រឹងសន្តិសុខទឹកយ៉ាងប្រសើរសម្រាប់ការងារកសិកម្ម។ កិច្ចខិតខំប្រឹងប្រែងនេះ បានក្លាយជាសសរស្តម្ភយ៉ាងសំខាន់ក្នុងការគាំទ្រដល់គោលនយោបាយសន្តិសុខស្បៀងជាតិ និងយុទ្ធសាស្ត្រនាំចេញស្រូវ-អង្ករ ស្របតាមមាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

គិតត្រឹមដំណាច់ឆ្នាំ២០២៥ ក្រសួងបានពង្រីកសក្តានុពលស្រោចស្រពលើផ្ទៃដីសរុបចំនួន **២ ០០៦ ៧២២** ហិកតា ក្នុងនោះរួមមាន៖ ផ្ទៃដីស្រូវរដូវវស្សាចំនួន **១ ៤០៤ ៧៩១** ហិកតា និងស្រូវរដូវប្រាំងចំនួន **៦០១ ៩៣១** ហិកតា។ ដោយឡែកក្នុងឆ្នាំ២០២៥ ក្រសួងសម្រេចបាននូវការបង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដាំដុះសរុបចំនួន **៣៨ ២៣២** ហិកតា ដែលក្នុងនោះរួមមាន៖ ផ្ទៃដីស្រូវវស្សាចំនួន **១៧ ៧៤០** ហិកតា ស្រូវរដូវប្រាំងចំនួន **១៩ ១៣៩** ហិកតា ដំណាំរួមផ្សំចំនួន **៧៧៤** ហិកតា និងដំណាំចម្ការចំនួន **៥៧៩** ហិកតា។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងពីគ្រោះទឹកជំនន់ ក្រសួងបានខិតខំជំរុញការងារជួសជុលទំនប់ការពារទឹកជំនន់ ការស្តារប្រឡាយរំដោះទឹក ការការពារច្រាំងទន្លេ និងការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ ។ ជាពិសេស ក្រសួងកំពុង

សម្រុកអនុវត្ត «គម្រោងបញ្ចៀសទឹកជំនន់ចេញពីភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តកណ្តាល» ដែលគ្រោងនឹងបញ្ចប់ការដ្ឋានជាស្ថាពរនៅដើមឆ្នាំ២០២៦ ខាងមុខ។ ក្រសួងបានពង្រឹងការតាមដាន និងប្រមូលទិន្នន័យកម្ពស់ទឹកតាមដងទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ និងដៃទន្លេសំខាន់ៗដទៃទៀត ដើម្បីធ្វើការព្យាករកម្ពស់ទឹកជាប្រចាំថ្ងៃទាំងក្នុងរដូវវស្សា និងរដូវប្រាំង។ ទន្ទឹមនឹងនេះ ការព្យាករ និងការផ្សព្វផ្សាយព័ត៌មានធាតុអាកាសត្រូវបានអនុវត្តជាប្រចាំ ដើម្បីបង្កើនការប្រុងប្រយ័ត្ន និងកាត់បន្ថយហានិភ័យដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ក្នុងក្របខ័ណ្ឌនៃការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាព ក្រសួងបានជំរុញការផ្សព្វផ្សាយ *"ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៃព្រះរាជាណាចក្រកម្ពុជា"* យ៉ាងទូលំទូលាយដល់រដ្ឋបាលរាជធានី-ខេត្ត និងសហគមន៍កសិករប្រើប្រាស់ទឹក នៅទូទាំងប្រទេស។ ជាលទ្ធផលជាក់ស្តែង ក្រសួងសម្រេចបាននូវការចុះកំណត់ផ្ទៃដីអាងទឹកសរុបចំនួន ៣០ កន្លែង ក្នុងភូមិសាស្ត្រខេត្តគោលដៅចំនួនប្រាំ រួមមានៈ ខេត្តឧត្តរមានជ័យ ១៤ កន្លែង ខេត្តប៉ៃលិន ៩ កន្លែង ខេត្តក្រចេះ ៤ កន្លែង ខេត្តមណ្ឌលគិរី ២ កន្លែង និងខេត្តកំពង់ធំ ១ កន្លែង។ ទន្ទឹមនឹងនេះ សម្រាប់ការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រក្នុងខេត្តកំពង់ស្ពឺ ក្រសួងបានរៀបចំនីតិវិធីចុះបញ្ជីប្រព័ន្ធធារាសាស្ត្រសរុបចំនួន ៣៧៥ ប្រព័ន្ធ ដែលក្នុងនោះ ១៦៨ ប្រព័ន្ធ ត្រូវបានចុះបញ្ជីរួចរាល់ដោយទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងបង្កាន់ដៃ ចំណែកឯ ២០៧ ប្រព័ន្ធ ទៀត កំពុងស្ថិតក្នុងដំណាក់កាលអនុវត្តនីតិវិធីរដ្ឋបាល ដើម្បីបន្តចុះបញ្ជីជាស្ថាពរ។

ក្រសួងបានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងទទួលបានការគាំទ្រផ្នែកហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍សរុបចំនួន ១៦ គម្រោង។ តាមរយៈកិច្ចសហការនេះ ការអភិវឌ្ឍវិស័យធនធានទឹកសម្រេចបាននូវសមិទ្ធផលត្រចះត្រចង់ ក្នុងការធានាសន្តិសុខទឹក ការកាត់បន្ថយហានិភ័យនៃគ្រោះទឹកជំនន់ និងការផ្គត់ផ្គង់ទឹកប្រកបដោយចីរភាពដល់អន្តរវិស័យ រួមមានៈ កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ថាមពលអគ្គិសនី ទេសចរណ៍ នាវាចរណ៍ និងបរិស្ថាន។ លើសពីនេះ សមិទ្ធផលទាំងនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងការឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃ សំដៅលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដែលជាកម្លាំងចលករដ៏រឹងមាំក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ។

យោងតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានលើកឡើងថាៈ *"ពិភពលោកនឹងកាន់តែមានសុវត្ថិភាព ស្រស់បំព្រង និងកក់ក្តៅជាងមុន ប្រសិនបើមានស្ត្រីក្លាយជាអ្នកដឹកនាំកាន់តែច្រើន"* ក្រសួងបាននិងកំពុងបន្តយកចិត្តទុកដាក់យ៉ាងសកម្ម ក្នុងកិច្ចការបង្កើនសមត្ថភាពយេនឌ័រ ដើម្បីរួមចំណែកដល់ការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានទឹក។ ទន្ទឹមនឹងនេះ ក្រសួងបានរៀបចំយន្តការគ្រប់ជ្រុងជ្រោយក្នុងគោលដៅបង្កើនកាលានុវត្តភាពដល់មន្ត្រីរាជការជាស្ត្រីដែលមានសមត្ថភាព ឱ្យទទួលបាននូវតួនាទីដឹកនាំ និងសិទ្ធិក្នុងកិច្ចសម្រេចចិត្ត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅជំរុញសមភាពយេនឌ័រក្នុងវិស័យធនធានទឹកឱ្យកាន់តែរឹងមាំ។

ខ្ញុំមានមោទនភាពឥតឧបមា ចំពោះស្មារតីខិតខំប្រឹងប្រែងរួមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងការចូលរួមសហការយ៉ាងជិតស្និទ្ធពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធនានា ដែលបានផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ កិច្ចសហការដ៏រឹងមាំនេះ បានក្លាយជាចលករដ៏មានឥទ្ធិពលជំរុញឱ្យក្រសួងធនធានទឹក និងឧតុនិយម សម្រេចបាននូវសមិទ្ធផលការងារយ៉ាងត្រចះត្រចង់ក្នុងឆ្នាំ២០២៥ ដូចដែលមានបង្ហាញលម្អិតក្នុងរបាយការណ៍នេះ។

ថ្ងៃអង្គារ ១៥កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ថោ ជេដ្ឋា**

# ១. សេចក្តីផ្តើម




ស្ថានីយ៍រ៉ាដា
RADA TOWER
តេជោសែន
TECHO SEN

## ១. សេចក្តីផ្តើម

វិស័យធនធានទឹកគឺ ជាវិស័យមួយដែលមានសារៈសំខាន់មិនអាចខ្វះបានក្នុងការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសំដៅកាត់បន្ថយភាពក្រីក្រ។ ក្នុងន័យនេះក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** តែងតែយកចិត្តទុកដាក់ និងចាត់ទុកវិស័យធនធានទឹក គឺជាវិស័យអាទិភាពមួយក្នុងចំណោម វិស័យ អាទិភាពទាំង ០៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង** និងបច្ចេកវិទ្យា។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបានយល់ច្បាស់ពីសារៈសំខាន់ក្នុងការបង្កើនការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយមប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។ យោងតាមសារៈសំខាន់ និងភាពចាំបាច់លើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព និងដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជា ក្នុងអាណត្តិទី២ បានសម្រេចបង្កើតក្រសួងធនធានទឹក និងឧតុនិយម តាមរយៈព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩។

ក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានទឹក ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមួយដែលធានាបាននូវសន្តិសុខទឹក ទាំងបរិមាណ និងគុណភាព ក្នុងការចូលរួមចំណែកដល់ការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ក្រសួងធនធានទឹក និងឧតុនិយម បានឆ្លងកាត់ស្ថានភាពដ៏លំបាកក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការអភិវឌ្ឍវិស័យ ធនធានទឹក និងឧតុនិយម ប៉ុន្តែដោយការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមាន ការគាំទ្រពីសំណាក់ដៃគូពាក់ព័ន្ធ ក្រសួងសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ តាមរយៈការជួសជុល-ស្តារឡើងវិញ និងសាងសង់ថ្មីនូវ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ទំនប់ការពារទឹកប្រៃ និងព្យាករណ៍ឧតុនិយម និងជលសាស្ត្រ ដែលបានជួយកាត់បន្ថយ គ្រោះមហន្តរាយ បង្កឡើងដោយធម្មជាតិ និងធានាដល់ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលស្រូវដំណាំគ្រប់ប្រភេទដែលជាផ្នែកមួយជួយ ឱ្យសម្រេចបាននូវគោលនយោបាយជាតិស្តីពី សន្តិសុខស្បៀង និងយុទ្ធសាស្ត្រនាំស្រូវ-អង្ករចេញរបស់រាជរដ្ឋាភិបាលកម្ពុជា និងសម្រាប់វិស័យដទៃទៀត រួមមានឧស្សាហកម្ម ដឹកជញ្ជូន ទេសចរ ។ល។

ជាក់ស្តែងក្នុងឆ្នាំ២០២៥កន្លងមកនេះក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តនូវផែនការសកម្មភាពរបស់ខ្លួនដែលបានកំណត់ក្នុងទិសដៅអនុវត្តដូចដែលបានកំណត់នៅក្នុងរបាយការណ៍សន្និបាតប្រចាំឆ្នាំ២០២៤ ដែលជាឆ្នាំបន្តការអនុវត្តផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម (២០២៤-២០២៨) ដោយសម្រេចបាន និងកំពុងអនុវត្តបន្តនូវសកម្មភាពធំៗមួយចំនួនដូចខាងក្រោម៖

- ✓ បាននឹងកំពុងកែទម្រង់ស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ✓ បាននឹងកំពុងធ្វើបច្ចុប្បន្នកម្មគោលនយោបាយ បទដ្ឋានគតិយុត្ត និងស្តង់ដាបច្ចេកទេស
- ✓ បាននឹងកំពុងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក
- ✓ បាននឹងកំពុងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍
- ✓ បាននឹងកំពុងរួមចំណែកលើកកម្ពស់យេនឌ័រក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក

លទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពច្បាស់លាស់ និងប្រាកដនិយម ស្តីពីចក្ខុវិស័យទឹកក្នុងក្របខ័ណ្ឌការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសុខុមាលភាពសង្គមរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

# ២. គោលនយោបាយជាតិលើវិស័យធនធានទឹក នៅព្រះរាជាណាចក្រកម្ពុជា





## ២. គោលនយោបាយជាតិលើវិស័យធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា

តាមលក្ខណៈភូមិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយសម្បូរទៅដោយធនធានទឹក។ ទន្លេ ស្ទឹង បឹងបួ អាងទឹកធម្មជាតិក្រោមដី និងសមុទ្រជាដើម ដែលជាប្រភពធនធានទឹកដ៏សំខាន់សម្រាប់បម្រើឱ្យដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម ឧស្សាហកម្ម ថាមពលវារីអគ្គិសនី នាវាចរណ៍ ទេសចរណ៍ធម្មជាតិ និងការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅប្រចាំថ្ងៃ។

ប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅតាមជនបទបានប្រឈមទៅនឹងកង្វះទឹកយ៉ាងខ្លាំងនារដូវប្រាំងហើយ និងកូនរដូវប្រាំងនៅក្នុងរដូវវស្សាផងដែរ ដែលផ្ទុយទៅវិញនៅរដូវវស្សាមានទឹកសម្បូរហូរហៀរ។ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពពុំមានគ្រប់គ្រាន់ និងមានលក្ខណៈចាស់ទ្រុឌទ្រោមដែលនាំឱ្យមានផលលំបាកចំពោះការរក្សាទឹកទុក ការផ្គត់ផ្គង់ទឹក ការបែងចែកទឹក និងការផលិតស្បៀង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវចក្ខុវិស័យទឹកនៅក្នុងសង្គម ដើម្បីធានា ឱ្យមានការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសមធម៌។ គោលនយោបាយជាតិលើវិស័យធនធានទឹកដែលបានរៀបចំនៅឆ្នាំ២០០៤ សំដៅ៖

- ការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព
- ប្រមើលមើលទុកជាមុន និងមានវិធានការជួយដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយលើបញ្ហា ប្រឈមនានាដែលអាចកើតមានឡើងក្នុងវិស័យទឹក
- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រជាតិ និងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រតាមផ្នែកនានា ស្តីពីការគ្រប់គ្រងធនធានទឹក
- តម្រង់ទិសនូវរាល់សកម្មភាពរបស់ស្ថាប័នគ្រប់លំដាប់ថ្នាក់ ផ្នែកឯកជន និងសាធារណៈ ក្នុងការអភិវឌ្ឍការប្រើប្រាស់ និងការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កែលម្អ ព្រមទាំងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយជាតិ ស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយនិរន្តរភាព។

### ❖ ចក្ខុវិស័យទឹកក្នុងប្រទេសកម្ពុជា

ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព តម្លាភាព និងសមធម៌ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យទឹកដូចខាងក្រោម៖

- ផ្តល់លទ្ធភាពឱ្យដល់ជនគ្រប់រូប ក្នុងការប្រើប្រាស់ទឹកសម្រាប់បរិភោគគ្រប់គ្រាន់ ប្រកបដោយ អនាម័យល្អមានសុវត្ថិភាព និងតម្លៃសមស្រប
- ផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់វិស័យកសិកម្ម ឧស្សាហកម្ម និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត
- ដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរិមានូវគ្រោះគំរាមកំហែងដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃពីមហន្តរាយដែលបង្កឡើងដោយទឹក
- គ្រប់គ្រងបរិស្ថានធនធានទឹកដែលគ្មានសារជាតុបំពុល។

### ❖ គោលការណ៍គ្រឹះជាមូលដ្ឋានក្នុងវិស័យទឹក

ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេស រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកគោលការណ៍គ្រឹះជាមូលដ្ឋានសំខាន់ៗដូចខាងក្រោម៖

- ការគ្រប់គ្រងទឹក និងធនធានទឹកជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល

- រាល់គម្រោងការងារទឹកត្រូវរៀបចំឡើងផ្អែកលើទិន្នន័យ និងព័ត៌មានស្តីពីទឹកស្របតាមផែនការអភិវឌ្ឍន៍ធនធានទឹកជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ផែនការបរិស្ថានជាតិ និងគោលការណ៍តំបន់ ដោយធានាបាននូវតុល្យភាពនៃការប្រើប្រាស់ទឹកនាពេលបច្ចុប្បន្ន និងពេលអនាគត
- បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់នៅក្នុងគ្រួសារនីមួយៗដូចជា៖ សម្រាប់ការហូបចុក បោកគក់ ងូត តម្រូវការជាមូលដ្ឋានប្រចាំថ្ងៃ និងសម្រាប់បម្រើដល់ការចិញ្ចឹមសត្វ ត្រី ការស្រោចស្រពសួនច្បារ ដំណាំ
- ការប្រើប្រាស់ និងការអភិវឌ្ឍលើវិស័យធនធានទឹក ត្រូវធានាឱ្យបាននូវប្រសិទ្ធភាព និរន្តរភាព និងមិនបង្កឱ្យប៉ះពាល់ដល់បរិស្ថាន។

### ❖ គោលនយោបាយជាតិលើវិស័យធនធានទឹក

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ និងមានគោលនយោបាយក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាពដូចតទៅ៖

ក. សក្តានុពលទឹកលើដី និងទឹកក្រោមដី

ក.១. ការវាយតម្លៃធនធានទឹក

ក.២. ការគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេ

ខ. ការចាត់ចែង ឬការធ្វើអាជីវកម្មសមស្រប

ខ.១. ទឹកសម្រាប់កសិកម្ម

ខ.២. ទឹកសម្រាប់ថាមពលវារីអគ្គិសនី

ខ.៣. ទឹកសម្រាប់ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម

ខ.៤. ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

ខ.៥. ទឹកសម្រាប់នាវាចរ និងទេសចរណ៍

ខ.៦. ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក និងភាពជាដៃគូ

គ. ការបែងចែក និងការចែកចាយទឹកប្រកបដោយសមធម៌

គ.១. ការបែងចែក និងការចែកចាយទឹក

គ.២. ព័ត៌មាន និងចំណេះដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃទឹក

ឃ. ការកាត់បន្ថយនូវគ្រោះមហន្តរាយដែលកើតឡើងពីទឹក

ឃ.១. វិធានការនៃការកាត់បន្ថយគ្រោះមហន្តរាយ

ឃ.២. ការប្រមូលទិន្នន័យ ការព្យាករណ៍ និងការប្រកាសជូនដំណឹងជាមុន

ង. ការថែរក្សា ការការពារ និងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី

ង.១. ក្របខ័ណ្ឌច្បាប់

ង.២. ការពង្រឹងសមត្ថភាពស្ថាប័ន

ង.៣. ផ្នែកហិរញ្ញវត្ថុ

ច. ទិដ្ឋភាពជាលក្ខណៈអន្តរជាតិនៃទឹក

ឆ. ការគ្រប់គ្រងធនធានទឹកនៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង

ជ. ការគ្រប់គ្រងទឹកតំបន់ឆ្នេរ និងទឹកសមុទ្រ

ជ.១. ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌបញ្ញត្តិ

ជ.២. ចំណេះដឹងជាមូលដ្ឋាន

ជ.៣. សកម្មភាពរបស់មនុស្សនៅតំបន់ឆ្នេរ និងទឹកឆ្នេរ

ជ.៤. ទឹកសមុទ្រ

### ❖ ការអនុវត្តគោលនយោបាយលើវិស័យធនធានទឹក

- គោលនយោបាយជាតិលើវិស័យធនធានទឹក នឹងត្រូវបានអនុវត្តដោយអ្នកប្រើប្រាស់ទឹក ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអ្នកពាក់ព័ន្ធទាំងឡាយក្នុងការអនុវត្តនូវរាល់សកម្មភាព ដើម្បីសម្រេចបានយ៉ាងពេញលេញនូវគោលបំណងនៃគោលនយោបាយនេះ។ ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវលើការអនុវត្តគោលនយោបាយតាមផ្នែក និងសកម្មភាពនានាឲ្យមានលក្ខណៈស្របគ្នាជាមួយនឹងគោលនយោបាយជាតិ។ ក្រសួងធនធានទឹកនិងឧតុនិយម និងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា រៀបចំបញ្ចូលនូវយុទ្ធសាស្ត្រ និងសកម្មភាពនានាទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការ ចាំឆ្នាំចាំបាច់ជួយ ដល់ការរំលេចភារៈកិច្ចទទួលខុសត្រូវស្របតាមគោលនយោបាយនេះ។ ដោយឡែកក្រសួងធនធានទឹក និងឧតុនិយមមានភារៈកិច្ចទទួលខុសត្រូវលើការត្រួតពិនិត្យនូវរាល់សកម្មភាពនានាពាក់ព័ន្ធនឹងធនធានទឹក ព្រមទាំងមានភារៈកិច្ចក្នុងការចាត់វិធានការជាបន្ទាន់លើរាល់សកម្មភាពដែលពុំទាន់បានសម្រេចនូវគោលបំណង នៃគោលនយោបាយនេះ។
- ក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវជូនដំណឹងដល់មន្ត្រីថ្នាក់កណ្តាល និងថ្នាក់ខេត្តស្ដីពីគោលនយោបាយ ដោយធ្វើការពន្យល់លើចំណុចនានាដែលមានផលប៉ះពាល់ដល់សកម្មភាពការងារ។ មន្ត្រីថ្នាក់ខេត្ត នឹងទទួលខុសត្រូវលើការផ្សព្វផ្សាយនូវគោលនយោបាយនេះទៅដល់មន្ត្រីទូទៅ និងប្រជាពលរដ្ឋថ្នាក់ស្រុក ឃុំនិងភូមិ ព្រមទាំងពន្យល់លើចំណុចនានា ដែលមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹក។ ក្រសួងធនធានទឹកត្រូវផ្សព្វផ្សាយផងដែរនូវគោលនយោបាយនេះ ដល់អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ព្រមទាំងធ្វើការពន្យល់នូវភាពទំនាក់ទំនងគ្នានៃគោលនយោបាយនេះក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក។
- ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវតាមដានពិនិត្យលើការអនុវត្តគោលនយោបាយនេះ ស្របពេលជាមួយនឹងការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងលើកសំណើសុំទៅរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការកែប្រែក្នុងករណីចាំបាច់។

# ៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០២៤-២០២៨




ZOOMLION

## ៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០២៤-២០២៨

វិស័យធនធានទឹក និងឧតុនិយម ដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ដូចនេះក្រសួងធនធានទឹក និងឧតុនិយម បានដាក់ចេញនូវចក្ខុវិស័យ និងបេសកកម្ម សម្រាប់ធ្វើការអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយមមានដូចខាងក្រោម៖

**ចក្ខុវិស័យ៖** ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលធានាបាននូវសន្តិសុខទឹក ទាំងបរិមាណ និងគុណភាព សម្រាប់ចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យ។

**បេសកកម្ម៖** បង្កើនការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ចូលរួមចំណែកដល់ការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចជាតិ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០២៤-២០២៨ បានកំណត់នូវ គោលបំណង គោលដៅយុទ្ធសាស្ត្រសំខាន់ៗ និងទិសដៅសម្រាប់អនុវត្តបន្តទៀត ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួង៖

**គោលបំណង៖** ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់គោលបំណងច្បាស់លាស់គឺ "ការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានទឹក និងឧតុនិយមប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ ស័ក្តិសិទ្ធិភាព និងនិរន្តរភាព ដើម្បីទ្រទ្រង់នូវប្រព័ន្ធអេកូឡូស៊ី និងកាត់បន្ថយនូវគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិដូចជា ទឹកជំនន់ ភាពរាំងស្ងួត មកលើការរស់នៅរបស់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិសាធារណៈ។

**គោលដៅ៖** ក្រសួងធនធានទឹក និងឧតុនិយម មានគោលដៅបង្កើនលទ្ធភាពស្រោចស្រពដោយប្រព័ន្ធ ធារាសាស្ត្រលើដំណាំស្រូវឱ្យបានចំនួន ៣០,០០០ ហិកតាក្នុង១ឆ្នាំ លើលទ្ធភាពស្រោចស្រពដែលមានស្រាប់។

**យុទ្ធសាស្ត្រសំខាន់ៗ៖** ដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅ ឱ្យបានជោគជ័យ ក្រសួងធនធានទឹក និងឧតុនិយមបានរៀបចំយុទ្ធសាស្ត្រសំខាន់ៗចំនួន ៥ មានដូចខាងក្រោម៖

- លើកកម្ពស់ការគ្រប់គ្រងរដ្ឋបាល ការអភិវឌ្ឍធនធានមនុស្ស និងការបញ្ជ្រាបយេនឌ័រ
- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងការកាត់បន្ថយគ្រោះទឹកជំនន់ រាំងស្ងួត និងទឹកប្រៃ
- បង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹករួមទាំងការអនុវត្តអនុត្តរភាព ប្រព័ន្ធធារាសាស្ត្រ
- ពង្រឹងការគ្រប់គ្រង និងនវានុវត្តន៍លើព័ត៌មាន និងទិន្នន័យធនធានទឹក និងឧតុនិយម
- បង្កើនប្រសិទ្ធភាពការការពារ និងការអភិរក្សវិស័យធនធានទឹក

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រខាងលើឱ្យបានជោគជ័យក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំផែនការសកម្មភាពមានដូចខាងក្រោម៖

- បង្កើនសមត្ថភាពលើការគ្រប់គ្រងរដ្ឋបាល និងកិច្ចដំណើរការស្ថាប័ន
- បង្កើនការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
- ជំរុញការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ក្នុងវិស័យធនធានទឹក និងឧតុនិយម
- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកតាមវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះក្នុងក្របខ័ណ្ឌអាងទន្លេ-ស្ទឹង
- គ្រប់គ្រង អភិវឌ្ឍន៍ និងអនុវត្តន៍អនុត្តរភាពប្រព័ន្ធធារាសាស្ត្រ
- ពង្រឹងការគ្រប់គ្រង និងការកាត់បន្ថយផលប៉ះពាល់ ដោយប្រើប្រាស់វិធានការហេដ្ឋារចនាសម្ព័ន្ធ
- ពង្រឹងការគ្រប់គ្រង និងការកាត់បន្ថយផលប៉ះពាល់ដោយប្រើប្រាស់វិធានការមិនមែនហេដ្ឋារចនាសម្ព័ន្ធ

- បង្កើត និងគាំទ្រកិច្ចដំណើរការមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យធនធានទឹក និងឧតុនិយម
- បង្កើនការគ្រប់គ្រងប្រព័ន្ធព័ត៌មាន ទិន្នន័យធនធានទឹក និងទិន្នន័យប្រព័ន្ធធារាសាស្ត្រ
- បង្កើនសមត្ថភាពការគ្រប់គ្រងប្រព័ន្ធព័ត៌មាន ទិន្នន័យជលសាស្ត្រ ឧតុនិយម និងនវានុវត្តន៍
- បន្តកសាង រៀបចំ និងធ្វើបច្ចុប្បន្នភាពលើច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធនានា
- ពង្រឹងវិធានការទប់ស្កាត់ ការពារ និងអភិរក្សធនធានទឹក។




*ក្រាហ្វិកទី ១: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០២៤-២០២៨*

# ៤. លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២៥





## ៤. លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២៥

### ៤.១. ការងាររដ្ឋបាល អភិវឌ្ឍន៍ធនធានមនុស្ស និងហិរញ្ញវត្ថុ

ក្នុងឆ្នាំ ២០២៥ ដែលជាឆ្នាំបន្តនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលមានស្នូលនៃយុទ្ធសាស្ត្រ គឺការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច។ ក្នុងឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតនូវ គណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារជាច្រើនដើម្បីបង្កើនប្រសិទ្ធភាពការងារ។ ក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តកម្មវិធី និងសកម្មភាពជាច្រើន ដោយផ្តោតសំខាន់ទៅលើការគ្រប់គ្រងការងាររដ្ឋបាលសំដៅធានាបានប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យធនធានទឹក។ ដើម្បីសម្រេចបានគោលបំណងនេះ ការអភិវឌ្ឍធនធានមនុស្ស និងការគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានយកចិត្តទុកដាក់ និងជំរុញឱ្យប្រសើរឡើងតាមរយៈការអភិវឌ្ឍសមត្ថភាពជំនាញរបស់មន្ត្រីរាជការ ការប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវតាមគោលដៅ និង ការគ្រប់គ្រងតាមរយៈប្រព័ន្ធឌីជីថល។ក្នុងឆ្នាំកន្លងមកក្រសួងបានសម្រេចបាននូវលទ្ធផលដ៏គួរឱ្យកត់សម្គាល់លើកិច្ចការរដ្ឋបាល ការអភិវឌ្ឍន៍ធនធានមនុស្ស និងហិរញ្ញវត្ថុ។ ខាងក្រោមនេះ គឺជាលទ្ធផលដែលសម្រេចបានក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ។

#### ៤.១.១. ការងាររដ្ឋបាល និងធនធានមនុស្ស

ក្នុងឆ្នាំ២០២៥នេះ ក្រសួងធនធានទឹក និងឧតុនិយមបានបន្តផ្តោតលើការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការការងាររដ្ឋបាល និងសមត្ថភាពបំពេញការងាររបស់មន្ត្រីរាជការ តាមរយៈការពង្រឹងកិច្ចការរដ្ឋបាល ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឌីជីថល និងការពង្រឹងការអនុវត្តសហលក្ខខណ្ឌតិ្តកៈមន្ត្រីរាជការ។ ការអភិវឌ្ឍធនធានមនុស្សត្រូវបានអនុវត្តដោយផ្តោតលើការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការ និងការលើកកម្ពស់ស្មារតីធ្វើការងារជាក្រុម។

##### ក. អភិបាលកិច្ច

ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំ និងពង្រឹងអភិបាលកិច្ច ដោយផ្តោតសំខាន់លើការគ្រប់គ្រងប្រសិទ្ធភាព និងការចងសម្ពន្ធភាពក្នុងការងាររដ្ឋបាល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ អភិបាលកិច្ចត្រូវបានអភិវឌ្ឍឡើងតាមគោលការណ៍គ្រប់គ្រងល្អ ដែលផ្អែកលើភាពត្រឹមត្រូវ ថ្លៃថ្នូរ និងមានសុចរិតភាព ដើម្បីបំពេញតម្រូវការការងារជាក់ស្តែង និងធានាបាននូវការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយមប្រកបដោយចីរភាព។ ក្នុងនាមជាស្ថាប័នដែលមានតួនាទីសំខាន់ក្នុងការគ្រប់គ្រងធនធានទឹក និងឧតុនិយម ក្រសួងបានយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាពក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក និងការពង្រឹងសមត្ថភាពមន្ត្រីរាជការដើម្បីបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាព។ ក្នុងឆ្នាំ២០២៥ ក្រសួងបានបង្កើត និងប្រកាសសុពលភាពគណៈកម្មការ និងអនុគណៈកម្មការរបស់ក្រសួងធនធានទឹក និងឧតុនិយម ដែលមានអនុគណៈកម្មការចំនួន ៧ ជាសេនាធិការ រួមមាន៖

- ក.១. គណៈកម្មការវាយតម្លៃការតែងតាំង និងការបញ្ចប់មុខតំណែងមន្ត្រីរាជការ របស់ក្រសួងធនធានទឹក និងឧតុនិយម
- ក.២. គណៈកម្មការគ្រប់គ្រង ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម
- ក.៣. គណៈកម្មាធិការលើកកម្ពស់អភិបាលកិច្ច ក្រសួងធនធានទឹក និងឧតុនិយម
- ក.៤. គណៈកម្មការសិទ្ធិមនុស្សក្រសួងធនធានទឹក និងឧតុនិយម
- ក.៥. គណៈកម្មការគ្រប់គ្រង ប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម
- ក.៦. គណៈកម្មការតម្រង់ទិស សម្រាប់គម្រោងស្តារ និងគ្រប់គ្រងអាងស្ទឹងស្វាយចេក ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ
- ក.៧. គណៈកម្មាធិការតម្រង់ទិសគម្រោងសម្រាប់គម្រោងកែលម្អសន្តិសុខទឹកកម្ពុជា

## ខ. ការគ្រប់គ្រងធនធានមនុស្ស




គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម ក្របខណ្ឌមន្ត្រីរាជការសរុបមានចំនួន ១ ១៨៦ នាក់ ក្នុងនោះស្រីមានចំនួន ២៨០ នាក់ (ថ្នាក់កណ្តាលចំនួន ៦៨៩នាក់ ស្រីចំនួន ១៧៥ នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន ៤៩៧ នាក់ ស្រីចំនួន ១០៥ នាក់) មានកម្រិតជំនាញ៖ ឧត្តមចំនួន ៨២២ នាក់ មធ្យមចំនួន ១៥៨ នាក់ បឋមចំនួន ៦២ នាក់ កម្មករជំនាញចំនួន ២១ នាក់ និងសាមញ្ញចំនួន ១២៣ នាក់។

*ក្រាហ្វិកទី ២: កម្រិតជំនាញ*

មន្ត្រីជាប់កិច្ចសន្យាថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត មានចំនួន ៤៨១ នាក់ ក្នុងនោះស្រីមានចំនួន ១៥០ នាក់ (ថ្នាក់កណ្តាលចំនួន ១១៦ នាក់ ស្រីចំនួន ៣៤ នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន ៣៦៥ នាក់ ស្រីចំនួន ១១៦ នាក់) ។

ឆ្នាំទំនប់មានចំនួន ២៥០ នាក់ ក្នុងនោះស្រីមានចំនួន ១៥ នាក់ (ថ្នាក់កណ្តាលចំនួន ០ នាក់ និងថ្នាក់រាជធានី-ខេត្ត ចំនួន ២៥០ នាក់ ស្រីចំនួន ១៥ នាក់។




*ក្រាហ្វិកទី ៣: ស្ថិតិមន្ត្រីរាជការ*

ក្រាហ្វិកទី៤ បង្ហាញជូនពីការស្នើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការសរុប ចំនួន ៣៧២ នាក់ ក្នុងនោះស្រីមាន ចំនួន ៩២ នាក់ (ថ្នាក់ កណ្តាលមានចំនួន ២១៨ នាក់ ស្រីចំនួន ៥៧ នាក់ និងថ្នាក់ រាជធានី-ខេត្ត មានចំនួន ១៥៤ នាក់ ស្រីចំនួន ៣៥ នាក់)។




*ក្រាហ្វិកទី ៤: ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំងមន្ត្រីរាជការ*




*ក្រាហ្វិកទី ៥: ការតែងតាំង និងដំឡើងឋានៈមន្ត្រីរាជការ*

ក្រៅពីនេះក្រសួងក៏បានយកចិត្តទុកដាក់អនុវត្តការងារគ្រប់គ្រងវត្តមានមន្ត្រីរាជការនៅគ្រប់អង្គភាពចំណុះ ស្របតាមអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។ និងលិខិតលេខ ២៩៨៤/២៤ មស.ន.វអជ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ ស្ដីពីប្រព័ន្ធគ្រប់គ្រងវត្តមាន និងស្ថានភាពមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

## គ. ការងារបណ្ដុះបណ្ដាល




*ក្រាហ្វិកទី ៦: ការបណ្ដុះបណ្ដាលធនធានមនុស្ស*

ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមបណ្ដាអង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយមនោះ ក្រសួងបានបញ្ជូនមន្ត្រីរាជការ ទៅបណ្ដុះបណ្ដាលនៅក្នុង និងក្រៅប្រទេស បានសរុបចំនួន ៧៤៣ នាក់ ក្នុងនោះស្រីមានចំនួន ២២២ នាក់ ( ក្នុងប្រទេស សរុបមានចំនួន ៦៩៨ នាក់ ស្រីចំនួន ១១៧ នាក់ និងក្រៅប្រទេសសរុបមានចំនួន ៤៥ នាក់ ស្រីចំនួន ៥ នាក់) ដូចមានបង្ហាញក្នុងក្រាហ្វិកទី ៥។



*រូបភាពទី ១: ចូលរួមវគ្គបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាពនៅក្នុងប្រទេស ក្នុងឆ្នាំ២០២៥*

## ឃ. ការងារកែទម្រង់រដ្ឋបាលសាធារណៈ

ការងារកែទម្រង់រដ្ឋបាលសាធារណៈ គឺជាដំណើរការសំខាន់សម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ក្នុងឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយមបានខិតខំប្រឹងប្រែង និងចូលរួមយ៉ាងសកម្មជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា (គ.វ.វ) ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាល និងប្រព័ន្ធសេវាសាធារណៈ។ ក្រសួងបានចងក្រងផែនការរយៈពេលវែងសម្រាប់ការកែទម្រង់ស្ថាប័ន និងការងារដែលមានទិសដៅច្បាស់លាស់។ ក្នុងនោះផងដែរ ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការ ត្រូវបានអនុវត្តដើម្បីបង្កើនសមត្ថភាពបច្ចេកទេស និងជំនាញគ្រប់គ្រងការងាររដ្ឋបាល។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងការគ្រប់គ្រងទិន្នន័យ និងការបំពេញភារកិច្ចប្រចាំថ្ងៃ។ ខាងក្រោមនេះជាវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០២៥

- រៀបចំសេចក្តីព្រាងអនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- សម្របសម្រួលគ្រប់ផ្នែកទាំងអស់របស់ក្រសួង ដើម្បីការងារកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព ដឹកនាំធ្វើបច្ចុប្បន្នភាព តួនាទីភារកិច្ចរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល រៀបចំដឹកនាំធ្វើបច្ចុប្បន្នភាព មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា រៀបចំផែនការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងផ្ទាំទំនប់នៅតាមប្រព័ន្ធធារាសាស្ត្រ រៀបចំដាក់ឱ្យចរាចរឯកសាររដ្ឋបាលតាមប្រព័ន្ធព័ត៌មានវិទ្យា និងដាក់ឱ្យដំណើរការយកវត្តមានមន្ត្រីរាជការតាមប្រព័ន្ធ CheckInMe
- រៀបចំសៀវភៅសេចក្តីណែនាំស្តីពីការតាក់តែងលិខិតរដ្ឋបាល និងបែបបទរដ្ឋបាលរបស់ក្រសួង រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងធនធានទឹក និងឧតុនិយមឱ្យចំគោលដៅចុះសម្របសម្រួលការងារដឹកនាំអង្គភាព ការគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីរាជការ ផ្ទាំទំនប់ នៅតាមមន្ទីរធនធានទឹក និងឧតុនិយមខេត្ត។ បានពិនិត្យនិងរៀបចំលើកសំណើ ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនអាយុ ចំនួន១៥នាក់ ទៅក្រសួងមុខងារសាធារណៈ
- បានពិនិត្យ និងបូកសរុបសម្រង់ព័ត៌មានស្តីពីប្រព័ន្ធគ្រប់គ្រងវត្តមាន និងស្ថានភាពមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាគ្រប់អង្គភាព របាយការណ៍វត្តមានប្រចាំខែទាំង ១២ខែ ឆ្នាំ២០២៥ ទៅក្រសួងមុខងារសាធារណៈ
- បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពរៀបចំសៀវភៅស្ថិតិក្របខ័ណ្ឌមុខងារសាធារណៈ ទាំង១២ខែ ឆ្នាំ២០២៥ សម្រាប់ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- ធ្វើបច្ចុប្បន្នភាពលើទិន្នន័យប្រវត្តិរូបថ្នាក់ដឹកនាំ ទីប្រឹក្សា ជំនួយការ និងមន្ត្រីក្នុងនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ទៅក្នុងប្រព័ន្ធរបស់ក្រសួងមុខងារសាធារណៈ
- បានចុះពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើមុខដំណែងក្នុងក្របខណ្ឌ ក.ខ.គ មន្ត្រីនៅតាមមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ធំ, ខេត្តក្រចេះ, ខេត្តមណ្ឌលគិរី, ខេត្តព្រះសីហនុ, ខេត្តស្វាយរៀង, ខេត្តកែប, ខេត្តប៉ៃលិន, ខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពត និងខេត្តកោះកុង
- បានពិនិត្យ និងបូកសរុបការងារដំឡើងកាំបៀវត្សតាមសញ្ញាបត្ររបស់មន្ត្រីរាជការបានចំនួន ១៥នាក់ ទៅក្រសួងមុខងារសាធារណៈ
- បានពិនិត្យ និងសម្របសម្រួលលើសំណើ ស្តីពីការបែងចែកភារកិច្ច និងកំណត់របៀបរបបធ្វើការងារមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប
- បានពិនិត្យ និងរៀបចំតារាងឧបសម្ព័ន្ធស្តីពីការបែងចែកមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីផ្ទាំទំនប់ប្រព័ន្ធធារាសាស្ត្រសម្រាប់ផែនការ ឆ្នាំ២០២៦ ទៅក្រសួងមុខងារសាធារណៈ

### ៤.១.២. ការងារការគ្រប់គ្រងហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម បានផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយទំនួលខុសត្រូវ ដើម្បីធានាបានប្រសិទ្ធភាពការគ្រប់គ្រង។ ការរៀបចំ និងការប្រើប្រាស់ថវិកាបានធ្វើឡើងស្របទៅតាមគោលការណ៍នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីធានាថាធនធានហិរញ្ញវត្ថុត្រូវបានប្រើប្រាស់សមស្របតាមតម្រូវការការងារ។ ការបែងចែកថវិកាបានអនុវត្តយ៉ាងប្រុងប្រយ័ត្ន ដោយផ្តោតសំខាន់ទៅលើគម្រោង និងសកម្មភាព ដែលជាអាទិភាព។ ក្រសួងក៏បានពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងតាមដានការប្រើប្រាស់ថវិកាជាប្រចាំ ដើម្បីធានានូវភាពត្រឹមត្រូវ ប្រសិទ្ធភាព និងការទទួលខុសត្រូវ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបានអនុវត្តតាមស្តង់ដារ នៃគណនេយ្យសាធារណៈ ដោយផ្តល់នូវភាពបរិយាយ និងសេចក្តីជាក់លាក់អំពីស្ថានភាពហិរញ្ញវត្ថុ។

នាយកដ្ឋានហិរញ្ញវត្ថុ ជាសេនាធិការឱ្យក្រសួងធនធានទឹក និងឧតុនិយម ទទួលបន្ទុកអនុវត្តសកម្មភាពក្នុងមាត្រា៩ នៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម ដូចតទៅ៖

- ប្រមូលផ្តុំតម្រូវការ លើកគម្រោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយ និងតាមដានវំលឹកពីការប្រតិបត្តិ
- សម្របសម្រួលជំពូកថវិកា និងរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ គ្រឿងបន្លាស់សម្រាប់យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- គ្រប់គ្រងព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ

#### ក. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០២៥-២០២៧ និងគម្រោងផែនការថវិកាតាមកម្មវិធីឆ្នាំ២០២៥

##### ក.១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០២៥- ២០២៧

###### ក.១.១. គោលបំណងនៃគោលនយោបាយ

ក្រសួងធនធានទឹក និងឧតុនិយម មានគោលបំណងនៃគោលនយោបាយចំនួន ១ គឺ "**ការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានទឹក ប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងនិរន្តរភាព**"

###### ក.១.២. រចនាសម្ព័ន្ធកម្មវិធី

ដើម្បីអនុវត្តគោលបំណងនៃគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំកម្មវិធី ចំនួន ៥ ដូចខាងក្រោម ៖

កម្មវិធីទី១៖ បង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក
មានអនុកម្មវិធី ចំនួន ៧ (ថ្នាក់កណ្តាល ចំនួន ៦ និងមន្ទីររាជធានី-ខេត្ត ចំនួន ១)

កម្មវិធីទី២៖ លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងទឹកប្រៃ
មានអនុកម្មវិធី ចំនួន ៣ (ថ្នាក់កណ្តាល ចំនួន ២ និងមន្ទីររាជធានី-ខេត្ត ចំនួន ១)

កម្មវិធីទី៣៖ បង្កើនប្រសិទ្ធភាពការការពារ និងការអភិរក្សវិស័យធនធានទឹក

មានអនុកម្មវិធីចំនួន ២ (ថ្នាក់កណ្តាល ចំនួន ២)

កម្មវិធីទី៤៖ ពង្រឹងការគ្រប់គ្រង នវានុវត្តន៍លើព័ត៌មាន និងទិន្នន័យធនធានទឹក និងឧតុនិយម

មានអនុកម្មវិធី ចំនួន ៥ (ថ្នាក់កណ្តាល ចំនួន ៤ និងមន្ទីររាជធានី-ខេត្ត ចំនួន ១)

កម្មវិធីទី៥៖ កិច្ចការរដ្ឋបាលទូទៅ

មានអនុកម្មវិធី ចំនួន ៨ (ថ្នាក់កណ្តាល ចំនួន ៧ និងមន្ទីររាជធានី-ខេត្ត ចំនួន ១)

### ក.១.៣. គោលបំណងកម្មវិធី

| កម្មវិធី | | គោលបំណងកម្មវិធី |
|---|---|---|
| កម្មវិធីទី១៖ | បង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក | លើកកម្ពស់ការគ្រប់គ្រង ប្រើប្រាស់បែងចែកទឹកប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព តាមរយៈការស្តារឡើងវិញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ និងអភិរក្សធនធានទឹក |
| កម្មវិធីទី២៖ | លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ គ្រោះរាំងស្ងួត និងទឹកប្រៃ | ការពារ និងកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិតាមរយៈ ការសិក្សាស្រាវជ្រាវ និងសាងសង់ទំនប់ អាងទឹក ទំនប់ការពារ ប្រឡាយដោះទឹក ហេដ្ឋារចនាសម្ព័ន្ធ ពាក់ព័ន្ធ និងការចុះអន្តរាគមន៍សង្គ្រោះដំណាំស្រូវវស្សា និងស្រូវប្រាំង ពេលជួបការខ្វះខាតទឹក និងគ្រោះរាំងស្ងួត |
| កម្មវិធីទី៣៖ | បង្កើនប្រសិទ្ធភាពការការពារ និងការអភិរក្សវិស័យធនធានទឹក | លើកកម្ពស់ការគ្រប់គ្រងធនធានទឹក ប្រកបដោយនិរន្តរភាពតាមរយៈការរៀបចំតាក់តែងអនុក្រឹត្យ ការរៀបចំ និងកែលម្អលិខិតបទដ្ឋាន និងនីតិវិធីនានាដែលពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយ និងអនុវត្ត |
| កម្មវិធីទី៤៖ | ពង្រឹងការគ្រប់គ្រង នវានុវត្តន៍លើព័ត៌មាន និងទិន្នន័យធនធានទឹក និងឧតុនិយម | - ពង្រឹង និងពង្រីក ការព្យាករ ការផ្សព្វផ្សាយព័ត៌មានឧតុនិយម និងជលសាស្ត្រ ស្តីពី គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រកបដោយប្រសិទ្ធភាព ឱ្យកាន់តែមានសុក្រឹត្យភាព និងស័ក្តិសិទ្ធភាព តាមរយៈការពង្រឹង និងពង្រីកបន្ថែមនូវស្ថានីយឧតុនិយម និងជលសាស្ត្រ ។<br>-រៀបចំសារពើភ័ណ្ឌ និងផែនទីភូមិសាស្ត្រប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ទឹកប្រៃ អាង ទន្លេ ស្ទឹង |
| កម្មវិធីទី៥៖ | កិច្ចការរដ្ឋបាលទូទៅ | បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន តាមរយៈការផ្តល់ សេវាគាំទ្រ និងពង្រឹងសមត្ថភាព បណ្តុះបណ្តាល និងអប់រំសម្រាប់ការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម ប្រកបដោយនិរន្តរភាព |

*តារាងទី ១: កម្មវិធី និងគោលបំណងកម្មវិធី*

### ក.១.៤. អង្គភាពថវិកា

ក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតអង្គភាពថវិកាចំនួន ២៩ ក្នុងនោះ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន ២ រួមមាន៖ ១)អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង២)អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស។ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២៧ គឺ ១)មន្ទីរធនធានទឹក និងឧតុនិយម ទាំង២៥ រាជធានី ខេត្ត ២)គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង៣)អាជ្ញាធរទន្លេសាប៖

a. **<u>រដ្ឋបាលកណ្តាល</u>** ៖ មាន ៤ អង្គភាពថវិកា រួមមាន៖

❖ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ មានចំនួន ២៖

- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- អាជ្ញាធរទន្លេសាប

❖ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ មានចំនួន ២៖

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល

.នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស

.នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ

.នាយកដ្ឋានហិរញ្ញវត្ថុ
.មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម
.នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស
.នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក
.នាយកដ្ឋានទឹកស្អាត និងអនាម័យ
.នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ
.នាយកដ្ឋានវិស្វកម្ម
.នាយកដ្ឋានឧតុនិយម
.នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក
.នាយកដ្ឋានធារាសាស្ត្រកសិកម្ម

b. **មន្ទីរជំនាញរាជធានី ខេត្ត ៖** អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២៥។

## ក.២. ការរៀបចំគម្រោងផែនការថវិកាតាមកម្មវិធីឆ្នាំ២០២៥

គម្រោងចំណាយតាមកម្មវិធីឆ្នាំ២០២៥ ស្នើឡើងរបស់ក្រសួង

ឯកតា ៖ លានរៀល

| បរិយាយ | សរុបរួម | កម្មវិធីទី១ | កម្មវិធីទី២ | កម្មវិធីទី៣ | កម្មវិធីទី៤ | កម្មវិធីទី៥ |
|---|---|---|---|---|---|---|
| **សរុបតាមកម្មវិធី** (I+II) | 351.255,0 | 264.099,4 | 5.532,5 | 24.102,1 | 14.413,1 | 43.107,9 |
| I. **ថ្នាក់កណ្តាល** | 303.820,0 | 248.711,4 | 2.991,5 | 24.102,1 | 12.908,1 | 15.106,9 |
| ក. ចំណាយចរន្ត | 183.300,0 | 128.711,4 | 2.991,5 | 24.102,1 | 12.628,1 | 14.866,9 |
| ខ. ចំណាយមូលធន | 120.520,0 | 120.000,0 | - | - | 280,0 | 240,0 |
| II. **ថ្នាក់រាជធានី-ខេត្ត** | 47.435,0 | 15.388,0 | 2.541,0 | - | 1.505,0 | 28.001,0 |
| ក. ចំណាយចរន្ត | 46.861,0 | 15.388,0 | 2.541,0 | - | 1.505,0 | 27.427,0 |
| ខ. ចំណាយមូលធន | 574,0 | - | - | - | - | 574,0 |

*តារាងទី ២: គម្រោងចំណាយតាមកម្មវិធីឆ្នាំ២០២៥ ស្នើឡើងរបស់ក្រសួង*

## ក.៣. ការគ្រប់គ្រងថវិកាកម្មវិធីឆ្នាំ២០២៥

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាកម្មវិធីឆ្នាំ ២០២៥ (ឥណទានអនុម័ត)

ឯកតា ៖ លានរៀល

| បរិយាយ | សរុបរួម | កម្មវិធីទី១ | កម្មវិធីទី២ | កម្មវិធីទី៣ | កម្មវិធីទី៤ | កម្មវិធីទី៥ |
|---|---|---|---|---|---|---|
| **សរុបតាមកម្មវិធី** (I+II) | 311.552,0 | 241.593,6 | 3.327,0 | 4.378,2 | 2.845,8 | 59.407,4 |
| I. **ថ្នាក់កណ្តាល** | 268.027,0 | 230.508,6 | 2.311,0 | 4.378,2 | 2.684,8 | 28.144,4 |
| ក. ចំណាយចរន្ត | 148.027,0 | 110.508,6 | 2.311,0 | 4.378,2 | 2.684,8 | 28.144,4 |
| ខ. ចំណាយមូលធន | 120.000,0 | 120.000,0 | - | - | - | - |
| II. **ថ្នាក់រាជធានី-ខេត្ត** | 43.525,0 | 11.085,0 | 1.016,0 | - | 161,0 | 31.263,0 |
| ក. ចំណាយចរន្ត | 43.525,0 | 11.085,0 | 1.016,0 | - | 161,0 | 31.263,0 |
| ខ. ចំណាយមូលធន | - | - | - | - | - | - |

*តារាងទី ៣: ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាកម្មវិធីឆ្នាំ ២០២៥(ឥណទានអនុម័ត)*

## ខ. ការអនុវត្តចំណាយថវិកា និងលទ្ធផលការងារសម្រេចបានឆ្នាំ២០២៥

### ខ.១.របាយការណ៍ចំណាយថវិកាប្រចាំឆ្នាំ២០២៥ របស់ក្រសួងធនធានទឹក និងឧតុនិយម




*ក្រាហ្វិកទី ៧: ការចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងធនធានទឹក និងឧតុនិយម*

ការអធិប្បាយឥណទាន និងសារប័ព្ទថវិកា — ឯកតា៖ លានរៀល

| ជំពូក | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៥ | ចលនាឥណទាន | | ស្ថានភាព ឥណទានថ្មី | ចំណាយ ឆ្នាំ២០២៥ | ឥណទាន នៅសល់ | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | កើន | ថយ | | | | | |
| | | ១ | ២ | ៣ | ៤=១+២-៣ | ៥ | ៦=៤-៥ | ៧=៥/៤ | ៨ |
| **សរុបរួមចំណាយថវិកា (I+II)** | | **311.552,0** | **80.611,1** | **1.280,0** | **390.883,1** | **386.017,0** | **4.866,0** | **98,8%** | |
| **ក. សរុបចំណាយចរន្ត** | | **191.552,0** | **5.311,1** | **1.280,0** | **195.583,1** | **191.814,1** | **3.769,0** | **98,1%** | |
| 64 | បន្ទុកបុគ្គលិក | 41.408,0 | 765,5 | 711,7 | 41.461,9 | 39.118,5 | 2.343,3 | 94,3% | |
| 60 | ការទិញ | 9.074,0 | - | - | 9.074,0 | 8.748,7 | 325,3 | 96,4% | |
| 61 | សេវាកម្ម | 126.756,0 | 918,4 | 568,4 | 127.106,0 | 126.611,1 | 494,9 | 99,6% | |
| 62 | អត្ថប្រយោជន៍សង្គម | 898,0 | - | - | 898,0 | 883,4 | 14,6 | 98,4% | |
| 65 | ឧបត្ថម្ភធន | 12.746,0 | 3.627,2 | - | 16.373,2 | 16.208,8 | 164,4 | 99,0% | |
| 63 | ពន្ធ និងអាករ | 670,0 | - | - | 670,0 | 243,6 | 426,5 | 36,4% | |
| **ខ. សរុបចំណាយមូលធន** | | **120.000,0** | **75.300,0** | **-** | **195.300,0** | **194.202,9** | **1.097,1** | **99,4%** | |
| 21 | អចលកម្មូបី | 120.000,0 | 75.300,0 | - | 195.300,0 | 194.202,9 | 1.097,1 | 99,4% | |
| **I- សរុបចំណាយថវិកាផ្នែក រដ្ឋបាល ថ្នាក់កណ្តាល** | | **388.027,0** | **155.376,4** | **732,8** | **542.670,6** | **538.153,7** | **4.516,9** | **99,2%** | |
| **ក. សរុបចំណាយចរន្ត** | | **268.027,0** | **80.076,4** | **732,8** | **347.370,6** | **343.950,8** | **3.419,8** | **99,0%** | |
| 64 | បន្ទុកបុគ្គលិក | 23.129,0 | 320,4 | 254,0 | 23.195,4 | 21.894,0 | 1.301,3 | 94,4% | |
| 60 | ការទិញ | 4.347,0 | - | - | 4.347,0 | 4.126,3 | 220,7 | 94,9% | |
| 61 | សេវាកម្ម | 107.305,0 | 828,8 | 478,8 | 107.655,0 | 107.342,4 | 312,6 | 99,7% | |
| 62 | អត្ថប្រយោជន៍សង្គម | | | | | | | | |
| 65 | ឧបត្ថម្ភធន | 12.746,0 | 3.627,2 | - | 16.373,2 | 16.208,8 | 164,4 | 99,0% | |
| 63 | ពន្ធ និងអាករ | 500,0 | - | - | 500,0 | 176,4 | 323,7 | 35,3% | |
| **ខ. សរុបចំណាយមូលធន** | | **120.000,0** | **75.300,0** | **-** | **195.300,0** | **194.202,9** | **1.097,1** | **99,4%** | |
| 21 | អចលកម្មូបី | 120.000,0 | 75.300,0 | - | 195.300,0 | 194.202,9 | 1.097,1 | 99,4% | |
| **II-សរុបចំណាយថវិកាផ្នែក មន្ទីរជំនាញរាជធានី ខេត្ត** | | **43.525,0** | **534,7** | **547,2** | **43.512,5** | **42.066,2** | **1.446,3** | **96,7%** | |
| **ក. សរុបចំណាយចរន្ត** | | **43.525,0** | **534,7** | **547,2** | **43.512,5** | **42.066,2** | **1.446,3** | **96,7%** | |
| 64 | បន្ទុកបុគ្គលិក | 18.279,0 | 445,1 | 457,7 | 18.266,5 | 17.224,5 | 1.042,0 | 94,3% | |
| 60 | ការទិញ | 4.727,0 | - | - | 4.727,0 | 4.622,4 | 104,6 | 97,8% | |
| 61 | សេវាកម្ម | 19.451,0 | 89,6 | 89,6 | 19.451,0 | 19.268,7 | 182,3 | 99,1% | |
| 62 | អត្ថប្រយោជន៍សង្គម | 898,0 | | | 898,0 | 883,4 | 14,6 | 98,4% | |
| 63 | ពន្ធ និងអាករ | 170,0 | | | 170,0 | 67,2 | 102,8 | 39,5% | |

*តារាងទី ៤: ការចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងធនធានទឹក និងឧតុនិយម*

## គ. លទ្ធផលការងារសម្រេចបានឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៥ នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តសកម្មភាព ដូចខាងក្រោម៖

- បានចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម ឆ្នាំ២០២៥ រវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានបើកប្រាក់បៀវត្ស និងបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ តាមប្រព័ន្ធធនាគារទាន់ពេលវេលា
- បានរៀបចំកម្មវិធីចំណាយថ្នាក់ជាតិរបស់ក្រសួងប្រចាំឆ្នាំ និងប្រចាំត្រីមាស
- បានបញ្ចូលផែនការចំណាយសាច់ប្រាក់ប្រចាំឆ្នាំ ត្រីមាស និងពាក់កណ្តាលឆ្នាំ២០២៥ នៅក្នុងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ (CMS) របស់អគ្គនាយកដ្ឋានរតនាគារជាតិ ទាន់ពេលវេលា

- បានផ្សព្វផ្សាយឯកសារថវិកា រួមមាន ១).សៀវភៅផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ ២).សៀវភៅគម្រោងផែនការថវិកាតាមកម្មវិធីស្នើឡើងសម្រាប់ឆ្នាំ២០២៥, ៣).ផែនការលទ្ធកម្មប្រចាំឆ្នាំ២០២៥ និង ៤).ការគ្រប់គ្រងឆ្នាំ២០២៥ (ចំណាត់ថ្នាក់សេដ្ឋកិច្ច និងកម្មវិធី) លើគេហទំព័ររបស់ក្រសួង
- បានរៀបចំវេទិកាសាធារណៈ ស្តីពីការផ្សព្វផ្សាយថវិកាប្រចាំឆ្នាំ ២០២៥ របស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងគម្រោងថវិកាប្រចាំឆ្នាំ២០២៦ និងបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាន់ពេលវេលា
- បានរៀបចំឯកសារទូទាត់ចំណាយបន្ទុកបុគ្គលិក ទូទាត់ត្រង់ ទូទាត់រជ្ជទេយ្យបុរេប្រទាន និងចំណាយផ្សេងៗ
- បានរៀបចំឯកសារទូទាត់ពន្ធលើមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២៥
- បានរៀបចំរបាយការចំណាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស
- បានរៀបចំរបាយការណ៍ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់ក្រសួង
- បានរៀបចំរបាយការណ៍សមិទ្ធកម្ម នៃការអនុវត្តថវិកាកម្មវិធីប្រចាំប្រចាំឆ្នាំ ២០២៤ និងប្រចាំឆមាសទី១ ឆ្នាំ២០២៥
- បានរៀបចំរបាយការណ៍លទ្ធកម្មប្រចាំត្រីមាស និងឆមាស
- បានរៀបចំរបាយការណ៍រជ្ជទេយ្យបុរេប្រទាន
- បានរៀបចំតារាងប្រៀបធៀបកើនឡើង-ថយចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៥ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាប្រចាំ ជំរុញការធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ និងបន្តធ្វើបច្ចុប្បន្នភាពទ្រព្យសម្បត្តិរដ្ឋក្នុងប្រព័ន្ធ SARMIS
- បានអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Nontax Revenue Management Information System - NRMIS)
- បានបញ្ជូនមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ចូលរួមវគ្គបណ្តុះបណ្តាល "ជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង" នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៥ ដោយមានសិក្ខាកាមចូលរួម ចំនួន ៥ រូប ក្នុងនោះស្ត្រី ចំនួន ២ រូប
- បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំនានាតាមការចាត់តាំងរបស់ក្រសួង។

ទន្ទឹមនឹងនេះផងដែរ នាយកដ្ឋានបាន និងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលជាកម្មវិធីអាទិភាព មួយក្នុងចំណោមកម្មវិធីកែទម្រង់អាទិភាពផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដូចតទៅ៖

❖ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)**

- បានរៀបចំផែនការសកម្មភាពលម្អិត (MAP), KPIs ឆ្នាំ២០២៥ និងបានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ដោយបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទាន់ពេលវេលា។
- បានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥ (សកម្មភាពការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ)
- បាន និងកំពុងប្រមូលធាតុដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពរួមសម្រាប់អនុវត្តបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០២៥-២០២៨ (PIMS) ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់យោបល់។
- បាន និងកំពុងកែសម្រួលសេចក្តីព្រាងចុងក្រោយរបាយការណ៍លទ្ធផលនៃការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ ឆ្នាំ២០២៤ (PFM Assessment) តាម

ការផ្តល់យោបល់របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសៀវភៅគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMM) របស់ក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥ ដោយមានសិក្ខាកាមចូលរួម ចំនួន ២០០ រូប ក្នុងនោះស្ត្រី ចំនួន ៩៨ រូប។

❖ **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)**

- បានកត់ត្រាមុខងារវិភាជន៍ថវិកា (BA) ក្នុងប្រព័ន្ធFMIS រួមមាន ក).ការញែករដ្ឋទេយ្យបុរេប្រទានដើមឆ្នាំ២០២៥ និង ខ).និយ័តកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៥
- បានបញ្ចូល និងកត់ត្រាមុខងារការទិញ (PO) និងមុខងារលទ្ធកម្មពេញលេញ (PR)
- បានបញ្ចូលអាណត្តិទូទាត់ត្រង់ ចំណាយកិច្ចលទ្ធកម្ម ចំណាយបន្ទុកបុគ្គលិក រដ្ឋទេយ្យបុរេប្រទាន ជានា-ចំណាយ និងចំណាយដែលមានហានិភ័យទាប (ទឹក ភ្លើង ពន្ធផ្លូវ) នៅក្នុងមុខងារគណនីត្រូវសង (AP)
- បានបញ្ចូល (ក).ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៧ (ខ).គម្រោងចំណាយប្រាក់បៀវត្សមន្ត្រីរាជការ និង (គ).គម្រោងចំណាយថវិកាប្រចាំឆ្នាំ២០២៦ ទៅក្នុងប្រព័ន្ធរៀបចំផែនការថវិកា (BPS)
- បានកត់ត្រាចំណូលនៅក្នុងមុខងារគណនីត្រូវទារ (AR)។

### ៤.១.៣. ការងារផែនការ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្រសួងធនធានទឹក និងឧតុនិយម បានចូលរួមអនុវត្តផែនការសកម្មភាព និងសហប្រតិបត្តិការអន្តរជាតិដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក(២០២៤-២០២៨)។ តាមរយៈផែនការយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការទាំងនេះ បានអនុញ្ញាតឱ្យក្រសួងអាចទទួលបានការគាំទ្រប្រកបដោយប្រសិទ្ធភាពទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍គម្រោងសំខាន់ៗក្នុងវិស័យធនធានទឹក និងឧតុនិយម នៅកម្ពុជា។

ក្នុងឆ្នាំ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួន ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល ៥ឆ្នាំ ២០២៤-២០២៨ និងគោលនយោបាយជាតិ ស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ក្នុងឆ្នាំកន្លងមក ក្រសួងបានសម្រេចបាននូវសមិទ្ធផលដ៏គួរឱ្យកត់សម្គាល់លើការអនុវត្តផែនការរបស់ខ្លួន ដោយសម្រេចបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

#### ក. ការងារផែនការ

- បន្តសហការជាមួយក្រសួងផែនការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដោយផ្តល់ធាតុចូលលើការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយម រយៈពេល ៥ឆ្នាំ (២០២៤-២០២៨) របស់ក្រសួងធនធានទឹក និងឧតុនិយម
- សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបញ្ចូលទិន្នន័យ សូចនាករ ចូលរួមទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០២៤-២០២៨) និងយុទ្ធសាស្ត្របញ្ចកោណដំណាក់ទី១ របស់រាជរដ្ឋាភិបាល
- រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល(PIP) របស់ក្រសួងប្រចាំឆ្នាំផ្ញើទៅជូនក្រសួងផែនការ ចុះត្រួតពិនិត្យតាមដាន វាយតម្លៃ(M&E) ការអនុវត្តគម្រោងប្រើប្រាស់ថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍តាមបណ្តារាជធានី-ខេត្តបានចំនួន ៦ខេត្ត និងធ្វើបច្ចុប្បន្នភាពទិន្នន័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹករយៈពេល ៥ឆ្នាំ (២០២៤-២០២៨)
- ចូលរួមសហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាតាមកម្មវិធីប្រចាំឆ្នាំនីមួយៗ

- ធ្វើការបូកសរុបរបាយការណ៍តាមបណ្តានាយកដ្ឋានទាំង១២ និងតាមបណ្តារាជធានី-ខេត្តទាំង២៥
- បូកសរុបរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារលើវិស័យធនធានទឹក និងឧតុនិយមប្រចាំខែនីមួយៗ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ របស់ក្រសួងផ្ញើរជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ដឹកនាំក្នុងក្រសួង ព្រមទាំងជូនដល់បណ្តានាយកដ្ឋានក្រោមឱវាទក្រសួងដើម្បីឯកសារ
- ការពង្រឹងសមត្ថភាពមន្ត្រីមន្ទីរលើជំនាញក្នុងការកសាងផែនការយុទ្ធសាស្ត្រលើវិស័យធនធានទឹក គោលនយោបាយជាតិលើវិស័យធនធានទឹក ការគ្រប់គ្រប់កម្មវិធីវិនិយោគសាធារណៈ ការគ្រប់គ្រងទិន្នន័យប្រព័ន្ធព័ត៌មានស្ថិតិ ចំនួន ៨វគ្គ មន្ត្រីសរុបចំនួន ១៩០រូប
- រៀបចំសិក្ខាសាលាស្តីពីការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹករយៈពេល ៥ឆ្នាំ និងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងការប្រមូលទិន្នន័យលើវិស័យធនធានទឹក និងឧតុនិយម សរុបចំនួន ៧វគ្គ សិក្ខាកាមចូលរួមចំនួន ១៩៥ រូប
- បន្តបញ្ជូនមន្ត្រីក្រោមឱវាទចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ចុះបេសកកម្ម តាមបណ្តាខេត្តដែលក្រសួងបានចាត់តាំងសរុបចំនួន ១៣០លើក(មន្ត្រីសរុបចំនួន ៣០៣រូប ក្នុងនោះស្ត្រីចំនួន ៦២រូប)។

### ក.១. ការងារស្ថិតិ

- បន្តរៀបចំចងក្រងបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិរបស់ក្រសួងសម្រាប់លើកផែនការអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយមរយៈពេលខ្លី មធ្យម និងវែងលើគ្រប់ផ្នែកទាំងអស់
- ចុះប្រមូល និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រព័ន្ធធារាសាស្ត្រចំនួន ១០ខេត្ត បានចំនួន ៦០ប្រព័ន្ធ
- បានរៀបចំគ្រប់គ្រង ចងក្រងជារបាយការណ៍វឌ្ឍនៈភាព បញ្ជីកម្រងសំនួរ និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ Database និងប្រព័ន្ធព័ត៌មានប្រព័ន្ធស្រោចស្រពនៅកម្ពុជា
- បានចុះពង្រឹងសមត្ថភាពមន្ត្រីមន្ទីរលើជំនាញការគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិ និងជំនាញការរៀបចំផែនទីតាមកម្មវិធី GIS ក្នុងមន្ទីរធនធានទឹក និងឧតុនិយមខេត្តកណ្តាលសរុបចំនួន ២៥រូប
- ការងារគាំទ្រអង្គភាព បានចូលរួមកែលម្អការគ្រប់គ្រងអង្គភាព និងពង្រឹងសមត្ថភាពមន្ត្រីរាជការ ដោយបានកិច្ចប្រជុំផ្ទៃក្នុងសរុបចំនួន ១៣២លើក មន្ត្រីសរុបចំនួន២២១រូប

### ក.២.ការងារវិមជ្ឈការ និងសហវិមជ្ឈការ

- បន្តលើកកម្ពស់ការងារផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វិស័យធនធានទឹក និងឧតុនិយម
- ចុះពិនិត្យតាមដានមុខងារដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ ក្នុងខេត្តចំនួន ៣ខេត្ត រួមមាន ខេត្តកណ្តាល កំពង់ធំ និងខេត្តសៀមរាប
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើមុខងារវិស័យធនធានទឹក និងឧតុនិយម ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅខេត្តកំពង់ធំ សរុបសិក្ខាកាមចូលរួមចំនួន ៥៥នាក់
- រៀបចំកិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យមុខងារដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ លើកទិសដៅអនុវត្តបន្ត និងរៀបចំជារបាយការណ៍ បានចំនួន៣ លើក សរុបចំនួន ៦២រូប



*រូបភាពទី ២:* សកម្មភាពពង្រឹងសមត្ថភាពមន្ត្រី និងការងារចុះប្រមូល និងធ្វើបច្ចុប្បន្នក្រសួង-ស្ថាប័ន

## ខ. កិច្ចសហប្រតិបត្តិការ

ក្រសួងធនធានទឹក និងឧតុនិយមបានផ្តល់សារសំខាន់ដល់កិច្ចសហប្រតិបត្តិការដែលជាសកម្មភាពមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍក្នុងវិស័យធនធានទឹក និងឧតុនិយម។ កិច្ចសហប្រតិបត្តិការបានជួយបង្កើនភាពរឹងមាំក្នុងការងារសហសេវា និងការចែករំលែកចំណេះដឹង បច្ចេកទេស និងព័តមាន ដល់ក្រសួង-ស្ថាប័ន ដែលជាដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ។

### ខ.១ កិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន

ក្រសួងធនធានទឹក និងឧតុនិយមបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេស ដើម្បីធានាបាននូវការគ្រប់គ្រងធនធានទឹក និងការព្យាករណ៍ធាតុអាកាស ប្រកបដោយប្រសិទ្ធភាព និងជឿទុកចិត្តបាន។

កិច្ចសហប្រតិបត្តិការទាំងនេះមានគោលបំណងចំបងក្នុងការចែករំលែកព័ត៌មាន បច្ចេកទេស និងធនធាន ដើម្បីបង្កើតចលនាសហសេវា និងការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ប្រទេសជាតិ។ កិច្ចសហប្រតិបត្តិការទាំងនេះបានចូលរួមចំណែកដល់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក។ ខាងក្រោមនេះជាសកម្មភាព និងលទ្ធផលដែលកើតចេញពីកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ៖

- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈការបង្កើតក្រុមការងារត្រី-វិស័យ សម្រាប់ការសម្របសម្រួលការអនុវត្តកម្មវិធីនយោបាយ និងសកម្មភាពដែលពាក់ព័ន្ធនឹង សហគមន៍កសិកម្មទំនើបសហគមន៍កសិករប្រើប្រាស់ទឹក និងភូមិគំរូ
- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម តាមរយៈការបង្កើតក្រុមការងារបច្ចេកទេសចម្រុះកសិកម្ម និងទឹក
- សហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងអភិវឌ្ឍន៍ ដើម្បីដោះស្រាយនិងអន្តរាគមន៍លើបញ្ហាប្រភពទឹកសម្រាប់ផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋ
- សហការជាមួយក្រសួងបរិស្ថាន ដោយធ្វើជាជនបង្គោលនៃ UN Water សម្រាប់រៀបចំ SDG 6.5.1 : IWRM ដែលត្រូវការវាយតម្លៃរយៈពេល ២ឆ្នាំម្តង និងជាសមាជិកក្រុមការងារ បច្ចេកទេសប្រែប្រួលអាកាសធាតុ និងក្រុមការងារបច្ចេកទេសសម្របសម្រួលការគ្រប់គ្រងឋបនីយជីវមណ្ឌល បឹងទន្លេសាប។ ក្រសួងក៏បានសហការជាមួយគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការ សម្របសម្រួល និងពិនិត្យលើសំណើវិនិយោគរបស់វិនិយោគិន
- ចូលរួមសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈគណៈកម្មធិការវិនិយោគកម្ពុជា (ច្រកចេញ ចូលតែមួយ) ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណើវិនិយោគនានា
- ចូលរួមសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការប្រមូលទិន្នន័យ និងការសិក្សាគម្រោងអភិវឌ្ឍន៍ផ្លូវនាវាចរណ៍ ហ្វូណនតេជោ
- ចូលរួមសហការជាមួយក្រសួងផែនការ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨)
- ចូលរួមសហការជាមួយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការគណៈកម្មការទន្លេមេគង្គក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាព
- ចូលរួមសហការជាមួយអាជ្ញាធរទន្លេសាបក្នុងការកំណត់ព្រំប្រទល់ និងបោះបង្គោលតំបន់ទាំងបី នៃអាងបឹងទន្លេសាប



*រូបភាពទី ៣: កិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន*

## ខ.២ កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍

តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ក្រសួងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់។ កិច្ចសហប្រតិបត្តិការទាំងនេះបានបង្ហាញនូវគុណប្រយោជន៍សំខាន់ៗ ដូចជា ការបង្កើត គម្រោងសម្រាប់គ្រប់គ្រងធនធានទឹក ប្រសិទ្ធភាពក្នុងការងារឧតុនិយម និងការចងសម្ព័ន្ធភាពជាមួយស្ថាប័នអន្តរជាតិដើម្បីចូលរួមដោះស្រាយបញ្ហាសកល។ ខាងក្រោមនេះគឺជាសកម្មភាព និងលទ្ធផលដែលកើតចេញពីកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ក្នុងឆ្នាំ២០២៥៖

### ខ.២.១ ការងារសហប្រតិបត្តិការអន្តរជាតិ និងការងារអាស៊ាន

- បន្តសហប្រតិបត្តិការអន្តរជាតិ ជាពិសេសជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានលើវិស័យអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម
- បន្តការងារសម្របសម្រួលជំនួយពីបរទេស និងដៃគូអភិវឌ្ឍន៍លើផ្នែកបច្ចេកវិទ្យាការប្រែប្រួលអាកាសធាតុ
- រៀបចំឯកសារកិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងធនធានទឹក និងឧតុនិយមជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍
- រៀបចំផែនការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងធ្វើរបាយការណ៍លើការអនុវត្តកិច្ចសហប្រតិបត្តិការនេះជូនថ្នាក់ដឹកនាំ

### ខ.២.២ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

ក្រសួងធនធានទឹក និងឧតុនិយម បានបន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការទាក់ទាញជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស ក៏ដូចជាការផ្តល់ហិរញ្ញប្បទានដល់ការស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធទឹក ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយមនៅកម្ពុជា។ ដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួនដែលបាន និងកំពុងបន្តផ្តល់ហិរញ្ញប្បទានជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស រួមមាន៖ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD) ធនាគារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) ទីភ្នាក់ងារសហប្រតិបត្តិការ អន្តរជាតិកូរ៉េ(KOICA) ធនាគារនីហរ័ណអាហរ័ណកូរ៉េ(Korea Eximbank EDCF) ធនាគារពិភពលោក(WB) ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី ប្រទេសបារាំង សហគមន៍អឺរ៉ុប ប្រទេសឥណ្ឌា ប្រទេសកូរ៉េ និងសាធារណរដ្ឋប្រជាមានិតចិន ។ល។






*រូបភាពទី ៤: កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា*

| ល.រ<br>No | ឈ្មោះគម្រោង<br>Project Name | ដៃគូរអភិវឌ្ឍន៍/ប្រទេស<br>DP / Country Name | រយៈពេលនៃគម្រោង<br>Project Duration | ភាគរយនៃការបញ្ចប់<br>Completion Percentage |
|---|---|---|---|---|
| 1 | គម្រោងខ្សែច្រវ៉ាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន Climate Friendly Agri-business Value Chain ( CFAVC ) | ADB | 2020-2026 | 58% |
| 2 | គម្រោងកែសម្រួលវិស័យធារាសាស្ត្រកសិកម្ម<br>Irrigated Agriculture improvement Project ( IAIP-ADB/AF ) | ADB | 2019-2027 | 52% |
| 3 | គម្រោងកែសម្រួលវិស័យធារាសាស្ត្រកសិកម្ម<br>Irrigated Agriculture Improvement Project ( IAIP-EIB ) | EIB | 2023-2025 | 15% |
| 4 | Flood Diversion from Phnom Penh Phase 1 & 2 | RGC | 2023-2026 | 99% |
| 5 | គម្រោងអភិវឌ្ឍន៍សំណង់ស្ពាក់ទឹកកំពង់គោ<br>Kampong Ko Barrage | RGC | 2024-2026 | 85% |
| 6 | Water Reservoir ( Steung Kranhuong ) | RGC | 2025-2027 | 20% |
| 7 | Water Reservoir ( Dam 2 ) | RGC | 2025-2027 | 30% |
| 8 | Integrated Water Resources Management ( IWRM ) | ADB / AIIB | 2025-2031 | 10% |
| 9 | Second Integrated Water Resources Management ( SIWRM ) | ADB | 2027-2032 | NA |
| 10 | Climate Adaptive Irrigation and Sustainable Agriculture for Resilience ( CAISAR ) | AIIB, IFAD and GCF | 2026-2032 | 8% |
| 11 | Country Climate Resilient Sustainable Irrigation and Water Drought and Flood Mitigation Project ( CCRSIWDFMP ) | AIIB | 2027-2032 | 12% |
| 12 | គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងឃ្លៀច<br>Stung Khleach Water Resources Development Project | RGC | 2025-2028 | 0% |
| 13 | គម្រោងស្វាយចេក<br>SVAY CHEK Project | AFD, EU | 2024-2027 | 10% |
| 14 | កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរកសិ-អេកូឡូស៊ីសម្រាប់កម្ពុជា ( ដំណាក់កាលទី១ ) WAT4CAM-Phase 1 | AFD, EU | 2019-2025 | 89% |
| 15 | គម្រោងប្រព័ន្ធធារាសាស្ត្រស្ទឹងព្រែកត្នោត និងគ្រប់គ្រងទឹកជំនន់<br>Stung Prek Thnot Irrigation and Flood Control Project | China | 2023-2025 | 100% |
| 16 | គម្រោងអភិឌ្ឍន៍អាងស្តុកទឹកដងកាំបិត<br>Dang Kambet Reservoir Development Project | China | 2023-2025 | 78% |
| 17 | គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់<br>Stung SVA HAB Water Resources Development Project | India | 2018-2024 | 30% |
| 18 | គម្រោងអភិវឌ្ឍន៍ឯកសាររចនាស្តង់ដារជាតិ សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងការរំដោះទឹក។<br>Project for Development of National Standard Design Documents for Irrigation and Drainage ( NaSDeP ) | Japan | 2022-2026 | 90% |
| 19 | គម្រោងស្តារ និងកែលម្អប្រព័ន្ធធារាសាស្ត្រ និងប្រឡាយនៅភាគនិរតី រាជធានីភ្នំពេញ<br>The Southwest Phnom Penh Irrigation and Drainage Rehabilitation and Improvement Project ( CP-P14 & CP-P28 ) | JICA/Japan | 2014-2026 | 67% |
| 20 | គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងកាត់បន្ថយទឹកជំនន់<br>Irrigation Development and Flood Mitigation Project ( KHM-19 ) | Korea | 2017-2026 | 89% |
| 21 | គម្រោងកាត់បន្ថយទឹកជំនន់ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្របរិល | Korea | 2024-2029 | 12% |

| | | | | |
|---|---|---|---|---|
| | Barvel Flood Mitigation and Irrigation Development Project ( KHM-35 ) | | | |
| 22 | គម្រោងអភិវឌ្ឍន៍ទំនប់ដូនទ្រី<br>Dauntri Dam Development | Korea | 2021-2025 | 100% |
| 23 | គម្រោងកែលម្អសន្តិសុខទឹកកម្ពុជា<br>Cambodia Water Security Improvement Project ( CaWSIP ) | WB | 2024-2030 | 10% |

*តារាងទី ៥: វឌ្ឍនភាពនៃការអនុវត្តបណ្តាគម្រោងដែលកំពុងដំណើរការ និងបញ្ចប់ក្នុងឆ្នាំ២០២៥ ដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា*

តារាងទី២ខាងលើ បង្ហាញពីវឌ្ឍនភាពនៃការអនុវត្តបណ្តាគម្រោងទាំង ២៣ ដែលកំពុងដំណើរការ និងបញ្ចប់ក្នុងឆ្នាំ២០២៥ ដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកម្ពុជា។ គិតត្រឹមឆ្នាំ២០២៥ មានគម្រោងចំនួន ២ ត្រូវបានបញ្ចប់គឺ គម្រោងប្រព័ន្ធធារាសាស្ត្រស្ទឹងព្រែកត្នោតនិងគ្រប់គ្រងទឹកជំនន់ និង គម្រោងអភិវឌ្ឍន៍ទំនប់ដូនទ្រី និងមានគម្រោងចំនួន ២១ កំពុងត្រូវបានអនុវត្ត ដែលគាំទ្រថវិកា ដោយដៃគូអភិវឌ្ឍន៍។ នៅក្នុងឆ្នាំ២០២៥ ក៏មានគម្រោង ចំនួន ៥ កំពុងត្រូវបានអនុវត្ត ដែលគាំទ្រថវិកាដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានថវិកាសរុបចំនួនប្រមាណ ៥៩៩,៨៥ លានដុល្លារអាមេរិក។




*ក្រាហ្វិកទី ៨: ចំនួនដៃគូអភិវឌ្ឍន៍ និងជំនួយជាហិរញ្ញប្បទាននិងជំនួយឥតសំណងផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់គម្រោងដែលបានអនុវឌ្ឍន៍ក្នុងឆ្នាំ២០២៥*

ក្រាហ្វិកទី៨ បង្ហាញពីចំនួនដៃគូអភិវឌ្ឍន៍ និងជំនួយជាហិរញ្ញប្បទាននិងជំនួយឥតសំណងផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់គម្រោងដែលបានអនុវត្តក្នុងឆ្នាំ២០២៥។ គិតត្រឹមឆ្នាំ២០២៥ មានដៃគូអភិវឌ្ឍន៍ចំនួន ១១៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD) ធនាគារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB) ធនាគារវិនិយោគអឺរ៉ុប (EIB) មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD) មូលនិធិអាកាសធាតុបៃតង(GCF) សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន(JICA) ប្រទេសកូរ៉េ(KOICA) ប្រទេសឥណ្ឌា និងធនាគារពិភពលោក(WB) ដែលគាំទ្រថវិកាសរុបចំនួនប្រមាណ ២.២៧៩,២៣ លានដុល្លារអាមេរិក សម្រាប់ការអនុវត្តចំនួន ១៦ គម្រោង។



*រូបភាពទី ៥: ទំនប់ដូនទ្រីដែលមានសក្តានុពលស្តុកទឹកបានប្រមាណជាង១៦៣លានម៉ែត្រគូប និងអាចស្រោចស្រពលើផ្ទៃដីកសិកម្មនៅរដូវវស្សាចំនួន ៣៣,០០០ហិកតា និងរដូវប្រាំងចំនួន ៤,៥០០ហិកតា និងមានប្រជាពលរដ្ឋទទួលផលចំនួន ៨,៥០០គ្រួសារ*




*ក្រាហ្វិកទី ៩: ចំនួនគម្រោង ដែលបាន បញ្ចប់ កំពុង អនុវត្ត និងគ្រោងអនុវត្ត ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០៣៦*

ក្នុងឆ្នាំ២០២៥ មានគម្រោងចំនួន២ត្រូវបានបញ្ចប់ គម្រោងចំនួន១៦កំពុងត្រូវបានអនុវត្តន៍ ដោយប្រើប្រាស់ថវិកាជាហិរញ្ញប្បទាន និងជំនួយឥតសំណងរបស់ ដៃគូអភិវឌ្ឍន៍ ដោយក្នុងនោះមានដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជាៈ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ធនាគារវិនិយោគអឺរ៉ុប (EIB) ធនាគារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB) សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន(JICA) ប្រទេសកូរ៉េ(KOICA) ដូចមានបង្ហាញក្នុងក្រាហ្វិកទី៩។




*ក្រាហ្វិកទី ១០:* ជំនួយជាហិរញ្ញប្បទាន និងជំនួយឥតសំណងផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់គម្រោងដែលបានបញ្ចប់ កំពុងអនុវត្ត និងគ្រោងអនុវត្ត ពីឆ្នាំ២០១៧ ដល់ឆ្នាំ ២០៣៦ (លានដុល្លារ)

ក្រាហ្វិកទី១០ ខាងលើ: បង្ហាញពីជំនួយជាហិរញ្ញប្បទាន និងជំនួយឥតសំណងផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់គម្រោងដែលបានបញ្ចប់ កំពុងអនុវត្ត និងគ្រោងអនុវត្ត ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០៣៦ ដែលមានថវិកាប្រមាណ ២.៤២៣,១១ លានដុល្លា ដែលក្នុងនោះ ធនាគារវិនិយោគរចនាសម្ព័ន្ធអាស៊ី (AIIB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង សាធារណរដ្ឋប្រជាមានិតចិន មានចំណែកច្រើនជាងគេ។



*រូបភាពទី ៦: ពិធីសម្ពោធគម្រោងអភិវឌ្ឍន៍អាងស្តុកទឹកដងកាំបិត ក្នុងខេត្តកំពង់ធំ*

## ៤.១.៤. ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ និងឧតុនិយម ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៦។ មជ្ឈមណ្ឌល មានភារកិច្ចសំខាន់ៗ ដូចជា ការសិក្សាតម្រូវការអភិវឌ្ឍធនធានមនុស្សសម្រាប់ វិស័យធនធានទឹក និងឧតុនិយម សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មី និងទំនើបកម្មលើប្រព័ន្ធធារាសាស្ត្រ ផ្សព្វផ្សាយបច្ចេកទេស និង

រៀបចំឯកសារព័ត៌មានបច្ចេកទេសដែលទាក់ទងនឹងវិស័យធនធានទឹក គឺជាអង្គភាពសំខាន់មួយដែលបានចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយវិស័យធនធានទឹក និងឧតុនិយម។ សកម្មភាព និងលទ្ធផលដែលមជ្ឈមណ្ឌលសម្រេចបាន ក្នុងឆ្នាំ២០២៥ រួមមាន៖

### ក. ការសិក្សាស្រាវជ្រាវ

- បានជ្រើសរើសទីតាំង និងតម្លើងឧបករណ៍តម្រូវការទឹករបស់ដំណាំស្រូវ វាស់ដោយដៃ ចំនួន ៣កន្លែង (១កន្លែង នៅខេត្តកណ្តាល និង២កន្លែងទៀតនៅខេត្តកំពង់ស្ពឺ)
- ការកត់ត្រា ប្រមូល និងចងក្រងទិន្នន័យតម្រូវការទឹករបស់ដំណាំស្រូវ នៅខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ចាប់ពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២៥ រហូតដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ២០២៥
- ការជួសជុល និងថែទាំបុស្តិ៍តម្រងទឹកភ្លៀងលើកទី១ នៅក្នុងខែឧសភា ឆ្នាំ២០២៥ និងលើកទី២ ក្នុងខែតុលា ឆ្នាំ២០២៤

### ខ. ការបណ្តុះបណ្តាល

មជ្ឈមណ្ឌល បានធ្វើការបណ្តុះបណ្តាល ដល់មន្ត្រីថ្នាក់ជាតិ មន្ត្រីរាជធានី ខេត្ត និងបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងសិក្ខាសាលាទាំងក្នុង និងក្រៅប្រទេសផងដែរ។ ខាងក្រោមនេះគឺការបណ្តុះបណ្តាល និងចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលា ដែលមជ្ឈមណ្ឌលបានអនុវត្តក្នុងឆ្នាំ២០២៥នេះ មានដូចខាងក្រោម៖

### គ. ការបណ្តុះបណ្តាលក្នុងប្រទេស

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ជាតិ និងមន្ត្រីមន្ទីរធនធានទឹក ឧតុនិយមរាជធានី ខេត្ត បានចំនួន ៦ វគ្គ សរុបចំនួន ១៨០នាក់ ដែលវគ្គនីមួយៗមានសិក្ខាកាមចូលរួមចំនួន ៣០នាក់ វគ្គដែលបានបណ្តុះបណ្តាលរួមមាន៖

- **ថ្នាក់ជាតិ(ថ្នាក់កណ្តាល និងមន្ទីររាជធានី ខេត្ត)**

- ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ (ពីថ្ងៃទី២១ ខែកក្កដា ដល់ថ្ងៃទី១ ខែសីហា ២០២៥)
- កិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ(ពីថ្ងៃទី៤ ដល់ថ្ងៃទី១៥ ខែសីហាឆ្នាំ២០២៥)
- គោលការណែនាំនៃការប្រើប្រាស់ និងគ្រប់គ្រងទឹកតាមអាងស្តុកខេត្ត (ពីថ្ងៃទី១៨ ដល់២៩ ខែសីហា ឆ្នាំ២០២៥)

- **ថ្នាក់ក្រោមជាតិ និងគណកម្មាធិការ ស.ក.ប.ទ.**

- ពង្រឹងគណកម្មាធិការ ស.ក.ប.ទ.ប្រព័ន្ធធារាសាស្ត្រលំហាច លើការគ្រប់គ្រង ការថែទាំ និងការប្រមូលភាគទាន (ពីថ្ងៃទី១ ដល់ថ្ងៃទី១៨ ខែកក្កដា ២០២៥)
- ពង្រឹងគណកម្មាធិការ ស.ក.ប.ទ. ប្រព័ន្ធធារាសាស្ត្រវត្តជ្រៃ លើការគ្រប់គ្រង ការថែទាំ និងប្រមូលភាគទាន (ពីថ្ងៃទី១ ដល់ថ្ងៃទី១៧ ខែកញ្ញា ២០២៥)
- ពង្រឹងគណកម្មាធិការ ស.ក.ប.ទ. ប្រព័ន្ធធារាសាស្ត្រវត្តហ្លួង លើការគ្រប់គ្រង ការថែទាំ និងការប្រមូលភាគទាន (ពីថ្ងៃទី១ ដល់ ថ្ងៃ២៤ ខែតុលា ២០២៥)






*រូបភាពទី ៧: ការបណ្តុះបណ្តាលថ្នាក់ជាតិក្នុងប្រទេស*

## ឃ. ការបណ្តុះបណ្តាល/សិក្ខាសាលាក្រៅប្រទេស

- បញ្ជូនមន្ត្រីចំនួន ១រូប ចូលរួមវគ្គបណ្តុះបណ្តាល ឯកទេសអន្តរជាតិស្តីពី បច្ចេកវិទ្យាបរិស្ថានលើកទី៣៥ នៅប្រទេសកូរ៉េ ពីថ្ងៃទី២២ដល់៣០ ខែមេសាឆ្នាំ២០២៥
- បញ្ជូនមន្ត្រីចំនួន ១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ទឹក-កសិកម្ម និងការគ្រប់គ្រងកិច្ចដំណើរការ ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម នៅប្រទេសកូរ៉េ ពីថ្ងៃទី២០ដល់២៩ ខែឧសភាឆ្នាំ២០២៥
- បញ្ជូនមន្ត្រីចំនួន ១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងលទ្ធកម្ម និងកិច្ចសន្យានៅប្រទេសវៀតណាមពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែកញ្ញាឆ្នាំ២០២៥
- បញ្ជូនមន្ត្រីចំនួន ២រូប ចូលរួមបណ្តុះបណ្តាលស្តីពី ប្រព័ន្ធសុវត្ថិភាព ក្នុងការផ្គត់ផ្គង់ទឹកជាមួយនឹងភាពធននៃការប្រែប្រួលអាកាសធាតុនៅប្រទេសចិន ពីថ្ងៃទី១០ដល់២៩ ខែកញ្ញាឆ្នាំ២០២៥
- បញ្ជូនមន្ត្រីចំនួន ១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សុវត្ថិភាពទំនប់ នៅប្រទេសឥណ្ឌាពីថ្ងៃទី៣ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៥
- បញ្ជូនមន្ត្រីចំនួន ២រូប ចូលរួមសន្និសីទ និងកិច្ចប្រជុំលើកទី២០នៃបណ្តាញអន្តជាតិស្តីពីទឹក និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងស្រែ (INWEPF) នៅទីក្រុងស៊ីហ្គា ប្រទេសជប៉ុន ពីថ្ងៃទី១០ ដល់ថ្ងៃទី១៥ ខែវិច្ឆិកាឆ្នាំ២០២៥។




*រូបភាពទី ៨: ការបណ្តុះបណ្តាលថ្នាក់ក្រៅជាតិក្នុងប្រទេស*

## ង. ការសហការជាមួយគម្រោងសហប្រតិបត្តិការជាមួយដៃគូរ

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧត្តមនិយម បានសហការជាមួយគម្រោងសហប្រតិបត្តិការបច្ចេកទេសសម្រាប់ពង្រឹងសមត្ថភាពរបស់មន្ត្រីលើវិស័យធនធានទឹកជាមួយដៃគូអភិវឌ្ឍន៍នានារួមមាន៖

- Japan Water Agency (JWA) លើការតម្លើងឧបករណ៍ Paddich ដើម្បីសិក្សាស្រាវជ្រាវពីការកាត់បន្ថយការបំភាយឧស្ម័ន មេតាន និងការបង្កើនទិន្នផលស្រូវ ដោយវិធីសាស្ត្រស្រោចស្រពពន្លិច និងបង្ហូតនៅប្រព័ន្ធធារាសាស្ត្រ លំហាច ស្ថិតក្នុងខេត្តកំពង់ឆ្នាំង។
- ចូលរួមជាមន្ត្រីសមភាគី គម្រោងស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ (ប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹក NaSDeP) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដោយចូលរួមជាគ្រូបង្គោល នឹងបានធ្វើការបណ្តុះបណ្តាលបន្ត ដល់មន្ត្រីថ្នាក់ជាតិ និងមន្ត្រីតាមបណ្តាជធានី-ខេត្ត បានចំនួន ៥លើក សរុប ២៤៤នាក់ ស្រី៤៣នាក់។
- ចូលរួមជាមន្ត្រីសមភាគី គម្រោងស្តារឡើងវិញប្រព័ន្ធស្រោចស្រព និងដោះទឹកភាគនារតីនៃរាជធានីភ្នំពេញ (CP-P14 & CP-P28) ស្ថិតក្នុងខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។



*រូបភាពទី ៩: ការបណ្តុះបណ្តាលថ្នាក់ក្រោមជាតិក្នុងប្រទេស*





*រូបភាពទី ១០: រូបភាពការសិក្សាតម្រូវការទឹករបស់តំណាំស្រូវ*








*រូបភាពទី ១១: រូបភាពការពិសោធន៍ នៃការស្រោចស្រពដោយបង្ហោក និងពន្លិចទឹករបស់តំណាំស្រូវ*

## ៤.២. ការងារអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងឧតុនិយម

ការងារអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងឧតុនិយម គឺជាការងារស្នូល និងមានសារៈសំខាន់ក្នុងការចូលរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក ២០២៤-២០២៨ ដើម្បីធានាបានការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងបរិយាប័ន្ន ក៏ដូចជាការផ្តល់សេវាព្យាករណ៍ជាតុអាកាសទាន់ពេលវេលា និងអាចទុកចិត្តបាន។

ខាងក្រោមនេះគឺជាលទ្ធផលដែលក្រសួងទទួលបានក្នុងឆ្នាំ២០២៥ ដែលអនុវត្តដោយបណ្តានាយកដ្ឋានបច្ចេកទេសចំណុះក្រសួង៖

### ៤.២.១. ការងារធារាសាស្ត្រកសិកម្ម

វិស័យធនធានទឹកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រោចស្រពផ្ទៃដីដំណាំកសិកម្មគ្រប់ប្រភេទ វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យគមនាគមន៍ ជីវៈចម្រុះ ជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃផងដែរ។ នាយកដ្ឋានធារាសាស្ត្រកសិកម្ម បានដើរតួនាទីជាសេនាធិការដ៏សំខាន់មួយឱ្យក្រសួងធនធានទឹក និងឧតុនិយម ក្នុងការងារថែទាំប្រព័ន្ធធារាសាស្ត្រ និងអភិវឌ្ឍវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហេតុដូចនេះ ការរីកចម្រើននៃវិស័យធនធានទឹក ជាពិសេសការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដែលមានលក្ខណៈពេញលេញ ពិតជាបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការងារបង្កបង្កើនផលរបស់បងប្អូនប្រជាកសិករ។ ផ្ទៃដីដែលធ្លាប់តែប្រេះ ហួតហែង នៅរដូវប្រាំង និងលិចទឹកនៅរដូវវស្សា បានប្រែក្លាយជាផ្ទៃដីក្រាលដោយដំណាំពណ៌ខៀវខ្ចី-លឿងទុំ នៅគ្រប់រដូវ។ ប្រព័ន្ធធារាសាស្ត្របានរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងក្នុងឆ្នាំ២០២៥ នេះ សម្រេចបានសមិទ្ធិផលជាច្រើនដូចខាងក្រោម៖

## ក. ការងារថែទាំប្រព័ន្ធធារាសាស្រ្ត

ការងារថែទាំប្រព័ន្ធធារាសាស្រ្តជាប្រចាំ គឺជាការងារមួយ ក្នុងចំណោមការងារដ៏ទៃទៀតរបស់នាយកដ្ឋាន ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាប្រសិទ្ធភាព និងអាយុកាលប្រើប្រាស់នៃប្រព័ន្ធធារាសាស្រ្ត ដើម្បីធានាបាននូវការផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាព សម្រាប់កសិកម្ម និងការប្រើប្រាស់។ ការងារថែទាំទាំងនេះ ត្រូវបានអនុវត្តទៅតាមស្តង់ដារបច្ចេកទេស ដើម្បីការពារ ឬទប់ស្កាត់ការខូចខាតប្រព័ន្ធ។ ក្រសួងធនធានទឹក និងឧតុនិយម បានផ្តោតលើការថែទាំប្រព័ន្ធធារាសាស្រ្តជាប្រចាំ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្រ្ត។ ការងារទាំងនេះរួមមាន ការពិនិត្យជាប្រចាំ ការជួសជុលភ្លាមៗតាមលក្ខខណ្ឌនៃការខូចខាត និងការពង្រឹងសមត្ថភាពមន្ត្រីដែលមានភារកិច្ចក្នុងការគ្រប់គ្រងប្រព័ន្ធ។ នៅក្នុងឆ្នាំ២០២៥ នាយកដ្ឋានធារាសាស្រ្តកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត បានអនុវត្តលើការងារថែទាំប្រព័ន្ធធារាសាស្រ្តសរុបចំនួន ១៨៦ប្រព័ន្ធ តាមបណ្តា ២៥ រាជធានី-ខេត្ត ដែលរួមមាន៖

- ការងារថែទាំប្រចាំ ប្រព័ន្ធធារាសាស្រ្តខ្នាតមធ្យមចំនួន ១៦៦ ប្រព័ន្ធ
- ការងារថែទាំប្រចាំ ប្រព័ន្ធធារាសាស្រ្តខ្នាតធំចំនួន ១៣ ប្រព័ន្ធ
- ការងារថែទាំខួប ប្រព័ន្ធធារាសាស្រ្តចំនួន ៧ ប្រព័ន្ធ




*ក្រាហ្វិកទី ១១: ចំនួនប្រព័ន្ធធារាសាស្រ្តដែលបានថែទាំប្រចាំ*




*ក្រាហ្វិកទី ១២: ចំនួនទំនប់ ប្រឡាយ (ខ្សែ) និង សំណង់សិល្បការ្យ (កន្លែង)*




*ក្រាហ្វិកទី ១៣: ប្រវែងទំនប់ និងប្រឡាយ (គិតជាគីឡូម៉ែត្រ)*

| ល.រ | ឈ្មោះ មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត | ២០២៥ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទំនប់ | | ប្រឡាយ | | សំណង់ | ផ្ទៃដី (ហ.ត) | | អ្នកទទួលផល | |
| | | ប្រព័ន្ធ | ខ្សែ | ប្រវែង (គ.ម) | ខ្សែ | ប្រវែង (គ.ម) | សិល្បការ្យ (កន្លែង) | ប្រាំង | វស្សា | គ្រួសារ | ប្រជាជនសរុប |
| ក | ការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ ខ្នាតធំ | 13 | 6 | 57 | 119 | 796 | 1,751 | 139,826 | 354,252 | 162,554 | 578,152 |
| ខ | ការងារថែទាំខួប | 7 | 1 | 1 | 6 | 43 | 86 | 11,404 | 20,163 | 4,005 | 35,955 |
| គ | ការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ ខ្នាតមធ្យម | 166 | 166 | 421 | 453 | 853 | 2,624 | 72,582 | 433,372 | 190,223 | 811,472 |
| | **សរុបរួម៖** | **186** | **173** | **478** | **578** | **1,692** | **4,461** | **223,812** | **807,787** | **356,782** | **1,425,579** |

*តារាងទី ៦: សមិទ្ធិផលសម្រេចបានសម្រាប់ការងារថែទាំប្រព័ន្ធធារាសាស្ត្រចំនួន ១៨៦ ប្រព័ន្ធ ទាំង ២៥ រាជធានី-ខេត្ត*

| ល.រ | ឈ្មោះ មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត | ២០២៥ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទំនប់ | | ប្រឡាយ | | សំណង់ | ផ្ទៃដី (ហ.ត) | | អ្នកទទួលផល | |
| | | ប្រព័ន្ធ | ខ្សែ | ប្រវែង (គ.ម) | ខ្សែ | ប្រវែង (គ.ម) | សិល្បការ្យ (កន្លែង) | ប្រាំង | វស្សា | គ្រួសារ | ប្រជាជនសរុប |
| ក | **ការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ (ខ្នាតធំ)** | | | | | | | | | | |
| 1 | កង្ហត | 1 | | | 9 | 131.04 | 95 | 25,741 | 70,000 | 23,854 | 95,706 |
| 2 | ប៉ូរាមគុណ (ថ្មី) | 1 | | | 24 | 58.26 | 252 | 700 | 7,200 | 902 | 6,210 |
| 3 | អាចាង | 1 | | | 12 | 63.52 | 108 | 5,150 | 10,300 | 6,979 | 28,443 |
| 4 | លំហាច | 1 | | | 8 | 49.53 | 255 | 1,555 | 5,083 | 1,334 | 6,557 |
| 5 | ៣០កញ្ញា | 1 | 1 | 14 | 4 | 62.29 | 164 | 3,000 | 35,000 | 50,462 | 175,941 |
| 6 | តាំងក្រសាំង | 1 | 1 | 3 | 2 | 18.74 | 80 | 1,000 | 9,869 | 3,137 | 12,307 |
| 7 | ស្ទឹងកែវ | 1 | 2 | 1 | 16 | 76.42 | 63 | 4,000 | 11,200 | 9,788 | 44,045 |
| 8 | កណ្តាលស្ទឹង | 1 | | | 9 | 28.53 | 119 | 1,950 | 8,600 | 17,530 | 68,754 |
| 9 | ស្ទឹងស្រែង (ដំហាន១) | 1 | 1 | 3 | 5 | 96.89 | 90 | 12,250 | 50,000 | 1,561 | 4,684 |
| 10 | ការពារទឹកជំនន់ និងស្រោចស្រព កំពង់ត្របែក | 1 | 1 | 36 | 14 | 50.20 | 141 | 6,000 | 9,000 | 8,121 | 4,381 |
| 11 | ដីគោ | 1 | | | 3 | 70.28 | 116 | 64,980 | 108,300 | 22,473 | 65,636 |
| 12 | ដំណាក់អំពិល | 1 | | | 9 | 68.50 | 196 | 9,000 | 23,700 | 13,563 | 52,154 |
| 13 | ហនុមាន | 1 | | | 4 | 22.10 | 72 | 4,500 | 6,000 | 2,850 | 13,334 |
| | **សរុប ក៖** | **13** | **6** | **57** | **119** | **796** | **1,751** | **139,826** | **354,252** | **162,554** | **578,152** |

*តារាងទី ៧: សមិទ្ធិផលការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ ខ្នាតធំ*





*តារាងទី ៨: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រ កង្ហត (ខ្នាតធំ) ស្ថិតក្នុងខេត្តបាត់ដំបង*





*រូបភាពទី ១២: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រ ៣០កញ្ញា (ខ្នាតធំ) ស្ថិតក្នុងខេត្តកំពង់ធំ*





រូបភាពទី ១៣: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រ វ៉ៃគោ (ខ្នាតធំ) ស្ថិតក្នុងខេត្តព្រៃវែង

| ល.រ | ឈ្មោះមន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត | ២០២៥ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទំនប់ | | ប្រឡាយ | | សំណង់ | ផ្ទៃដី (ហ.ត) | | អ្នកទទួលផល | |
| | | ប្រព័ន្ធ | ខ្សែ | ប្រវែង (គ.ម) | ខ្សែ | ប្រវែង (គ.ម) | សិល្បការ្យ (កន្លែង) | ប្រាំង | វស្សា | គ្រួសារ | ប្រជាជនសរុប |
| ខ | ការងារថែទាំខួប | | | | | | | | | | |
| 1 | ប្រឡាយមេទី២នៃប្រព័ន្ធធារាសាស្ត្រអាងទឹកត្រពាំ | 1 | | | 1 | 16.05 | 33 | 7,000 | 12,000 | | 12,750 |
| 2 | ប្រឡាយអូរជីម៉ាស | 1 | | | 1 | 6.92 | 14 | 842 | 1,050 | 1,528 | 7,640 |
| 3 | ប្រឡាយទំពេជ | 1 | | | 1 | 4.30 | 5 | 885 | 1,500 | 287 | 1,403 |
| 4 | ប្រព័ន្ធធារាសាស្ត្រទឹកជុំ | 1 | | | 1 | 5.95 | 15 | 350 | 1,209 | 650 | 2,500 |
| 5 | ទំនប់ព្រែកជីកលំហាច (ដំហាន២) | 1 | 1 | 1.30 | | | 1 | 583 | 1,555 | 1,334 | 6,557 |
| 6 | ប្រឡាយមេទី២នៃប្រព័ន្ធធារាសាស្ត្រថ្មល់បត់ | 1 | | | 1 | 7.00 | 3 | 450 | 1,170 | | 3,975 |
| 7 | ប្រឡាយរំចេក | 1 | | | 1 | 3.20 | 15 | 1,294 | 1,679 | 206 | 1,130 |
| | សរុប ខ៖ | 7 | 1 | 1.30 | 6 | 43.42 | 86 | 11,404 | 20,163 | 4,005 | 35,955 |

តារាងទី ៩: សមិទ្ធិផលការងារថែទាំខួប





រូបភាពទី ១៤: ការងារថែទាំខួបប្រព័ន្ធធារាសាស្ត្រត្រពាំងថ្ម ស្ថិតក្នុងខេត្តបន្ទាយមានជ័យ





រូបភាពទី ១៥ :ការងារថែទាំខួបប្រព័ន្ធធារាសាស្ត្រ ប្រឡាយទំពេជ ស្ថិតក្នុងខេត្តកំពង់ធំ

| ល.រ | ឈ្មោះមន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត | ២០២៥ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន ប្រព័ន្ធ | ទំនប់ | | ប្រឡាយ | | សំណង់ សិល្បការ្យ | ផ្ទៃដី (ហ.ត) | | អ្នកទទួលផល | |
| | | | ខ្សែ | ប្រវែង (គ | ខ្សែ | ប្រវែង (គ.ម) | | ប្រាំង | វស្សា | គ្រួសារ | ប្រជាជនសរុប |
| គ | ការងារថែទាំជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ (ខ្នាតមធ្យម) | | | | | | | | | | |
| 1 | ខេត្តបន្ទាយមានជ័យ | 7 | 5 | 18.81 | 9 | 18.44 | 43 | 6,130 | 8,705 | 11,807 | 102,393 |
| 2 | ខេត្តបាត់ដំបង | 9 | 4 | 27.30 | 15 | 46.60 | 157 | 17,187 | 130,725 | 8,403 | 41,309 |
| 3 | ខេត្តកំពង់ចាម | 10 | 10 | 21.06 | 63 | 49.09 | 202 | 4,520 | 4,193 | 9,332 | 42,250 |
| 4 | ខេត្តកំពង់ឆ្នាំង | 7 | 7 | 15.68 | 10 | 16.35 | 58 | 2,146 | 4,563 | 4,873 | 30,248 |
| 5 | ខេត្តកំពង់ស្ពឺ | 9 | 12 | 15.49 | 25 | 67.45 | 110 | 761 | 11,196 | 17,359 | 86,684 |
| 6 | ខេត្តកំពង់ធំ | 7 | 3 | 7.82 | 16 | 52.55 | 207 | 6,497 | 5,180 | 12,124 | 51,096 |
| 7 | ខេត្តកំពត | 7 | 7 | 12.54 | 57 | 89.06 | 178 | 3,845 | 6,990 | 15,496 | 20,952 |
| 8 | ខេត្តកណ្តាល | 8 | 5 | 16.69 | 3 | 7.57 | 270 | 2,287 | - | 2,530 | 10,307 |
| 9 | ខេត្តកែប | 4 | 4 | 6.47 | 9 | 16.39 | 49 | 308 | 1,536 | 2,166 | 9,930 |
| 10 | ខេត្តកោះកុង | 8 | 13 | 52.48 | 6 | 12.26 | 41 | - | 5,856 | 6,229 | 29,525 |
| 11 | ខេត្តក្រចេះ | 8 | 9 | 9.04 | 17 | 21.18 | 67 | 1,695 | 2,462 | 2,615 | 12,314 |
| 12 | ខេត្តមណ្ឌលគិរី | 4 | 6 | 13.54 | 34 | 49.86 | 105 | 896 | 4,387 | 1,628 | 5,951 |
| 13 | ខេត្តឧត្តរមានជ័យ | 8 | 9 | 28.13 | 11 | 24.00 | 47 | 1,736 | 10,015 | 5,728 | 25,256 |
| 14 | រាជធានីភ្នំពេញ | 2 | 2 | 12.33 | 13 | 8.35 | 13 | 236 | 694 | 9,990 | 42,991 |
| 15 | ខេត្តព្រះសីហនុ | 6 | 6 | 57.80 | 6 | 55.25 | 26 | - | 10,085 | 7,213 | 22,552 |
| 16 | ខេត្តព្រះវិហារ | 8 | 8 | 15.79 | 12 | 11.39 | 57 | 390 | 146,405 | 13,873 | 30,837 |
| 17 | ខេត្តព្រៃវែង | 9 | 11 | 12.69 | 7 | 42.60 | 145 | 4,333 | 22,285 | 21,147 | 100,300 |
| 18 | ខេត្តពោធិ៍សាត់ | 7 | 6 | 12.34 | 40 | 77.21 | 245 | 6,750 | 17,206 | 7,315 | 34,363 |
| 19 | ខេត្តរតនគិរី | 5 | 7 | 5.01 | 32 | 33.36 | 133 | 251 | 2,216 | 1,088 | 3,739 |
| 20 | ខេត្តសៀមរាប | 3 | 1 | 2.68 | 10 | 34.95 | 160 | 140 | 2,956 | 1,252 | 6,506 |
| 21 | ខេត្តស្ទឹងត្រែង | 8 | 11 | 8.03 | 30 | 26.25 | 59 | 1,998 | 4,821 | 2,782 | 13,022 |
| 22 | ខេត្តស្វាយរៀង | 8 | 8 | 19.89 | 8 | 14.86 | 31 | 5,900 | 14,769 | 10,462 | 29,611 |
| 23 | ខេត្តតាកែវ | 8 | 6 | 17.37 | 5 | 24.27 | 83 | 3,223 | 5,047 | 7,064 | 24,365 |
| 24 | ខេត្តត្បូងឃ្មុំ | 3 | 3 | 10.91 | 5 | 29.64 | 46 | 350 | 5,606 | 5,442 | 24,053 |
| 25 | ខេត្តប៉ៃលិន | 3 | 3 | 0.67 | 10 | 23.83 | 92 | 1,003 | 5,474 | 2,305 | 10,918 |
| | **សរុប គ៖** | **166** | **166** | **420.53** | **453** | **852.74** | **2,624** | **72,582** | **433,372** | **190,223** | **811,472** |

*តារាងទី ១០ :សមិទ្ធិផលការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ ខ្នាតមធ្យម*




*រូបភាពទី ១៦ :ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រក្រូចសើច (ខ្នាតមធ្យម) ស្ថិតក្នុងខេត្តពោធិ៍សាត់*




*រូបភាពទី ១៧: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រលំពោធិ៍ (ខ្នាតមធ្យម) ស្ថិតក្នុងខេត្តកំពង់ចាម*





*រូបភាពទី ១៨: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រអូរយ៉េះ (ខ្នាតមធ្យម) ស្ថិតក្នុងខេត្តមណ្ឌលគិរី*





*រូបភាពទី ១៩: ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រអាងស្តុកទឹកតាវ៉ាន់ (ខ្នាតមធ្យម) ស្ថិតក្នុងខេត្តត្បូងឃ្មុំ*

### ខ. ការងារថែទាំ និងជួសជុលម៉ាស៊ីនបូមទឹក

ការងារជួសជុល និងថែទាំម៉ាស៊ីនបូមទឹក គឺជាការងារចាំបាច់សម្រាប់ធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ និងអាយុកាលរបស់ម៉ាស៊ីនបូមទឹក ដែលអាចផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម និងសកម្មភាពប្រើប្រាស់ទឹកផ្សេងៗ។ ការងារនេះរួមមាន ការត្រួតពិនិត្យជាប្រចាំ ការជួសជុលជាបន្ទាន់ ការជួសជុល និងថែទាំទុយោ និងការដូរប្រេងម៉ាស៊ីន ឬគ្រឿងបន្លាស់ដែលខូចខាត ដើម្បីធានាបាននូវស្ថានភាពដំណើរការបានពេញលេញ។ ក្នុងឆ្នាំ ២០២៥ នេះ នាយកដ្ឋានធារាសាស្ត្រកសិកម្ម បានយកចិត្តទុកដាក់ និងពង្រឹងការថែទាំ និងការជួសជុល ដូចជា៖

- ជួសជុលថែទាំម៉ាស៊ីនបូមទឹកចល័ត (Kirloskar) ឥណ្ឌា ៦៥ សេះ បានចំនួន ១១ គ្រឿង
- ថែទាំ និងបាញ់ថ្នាំម៉ាស៊ីនបូមទឹកចល័ត ៦៥សេះ បានចំនួន ៦០ គ្រឿង
- ថែទាំ និងបាញ់ថ្នាំទុយោចេញ បានចំនួន ៦០ដើម (៣ម៉ែត្រ/១ដើម)
- ថែទាំ និងបាញ់ថ្នាំទុយោចូលបានចំនួន ៤០ដើម (៦ម៉ែត្រ/១ដើម)



*រូបភាពទី ២០: ម៉ាស៊ីនបូមទឹកចល័ត កម្លាំង ៦៥សេះ ក្រោយការងារថែទាំ និងជួសជុលរួចរាល់នៅជម្រកគ្រឿងចក្រ និងម៉ាស៊ីនបូមទឹក*



*រូបភាពទី ២១: ទុយោចេញ ចូល ដែលបានថែទាំ និងបាញ់ថ្នាំរួច*



*រូបភាពទី ២២: រូបភាពគ្រឿងបន្លាស់ម៉ាស៊ីនបូមទឹកចល័ត កម្លាំង ៦៥សេះ*

### គ. ការងារអន្តរាគមន៍

ការងារអន្តរាគមន៍ គឺជាសកម្មភាពដែលត្រូវចុះអនុវត្តន៍ជាបន្ទាន់ ក្នុងករណីមានហេតុការណ៍ដែលបង្កការខូចខាតដល់ប្រព័ន្ធធារាសាស្ត្រ និងការដាំដុះ ដែលតម្រូវឱ្យមានកិច្ចអន្តរាគមន៍បូមទឹកសង្គ្រោះ ពេលជួបគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់។ ការងារអន្តរាគមន៍នេះរួមមាន ការជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រដែលខូចខាត ការផ្គត់ផ្គង់ទឹកបន្ទាន់ ការការពារ និងការទប់ស្កាត់ការខូចខាត ដែលបង្កឡើងដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ នៅក្នុងឆ្នាំ ២០២៥ នេះផងដែរ នាយកដ្ឋានធារាសាស្ត្រកសិកម្មបានធ្វើការអន្តរាគមន៍ជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្របានចំនួន ៣២គម្រោង តាមបណ្តាខេត្តចំនួន ១៤ខេត្ត និងការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវប្រាំងបានចំនួន ៣៩,០២២ហិកតា ដោយប្រើប្រាស់ម៉ាស៊ីនបូមទឹកចំនួន ៤១៧គ្រឿង នៅខេត្តចំនួន ១៤។

| ល.រ | ឈ្មោះខេត្ត | ទីតាំងអន្តរាគមន៍ | | | ម៉ាស៊ីនបូមទឹក (គ្រឿង) | ផ្ទៃដីអន្តរាគមន៍ (ហិកតា) | ផ្ទៃដីសម្រេចបាន (ហិកតា) |
|---|---|---|---|---|---|---|---|
| | | ភូមិ | ឃុំ | ស្រុក | | | |
| ១ | ខេត្តបន្ទាយមានជ័យ | 7 | 1 | 1 | 9 | 1,250 | 1,250 |
| ២ | ខេត្តកំពង់ចាម | 16 | 11 | 4 | 65 | 2,456 | 2,456 |
| ៣ | ខេត្តកំពង់ឆ្នាំង | 21 | 9 | 5 | 42 | 1,911 | 1,911 |
| ៤ | ខេត្តកំពង់ស្ពឺ | 18 | 10 | 5 | 94 | 468 | 468 |
| ៥ | ខេត្តកំពង់ធំ | 16 | 12 | 5 | 25 | 8,500 | 8,500 |
| ៦ | ខេត្តកំពត | 13 | 7 | 3 | 14 | 9,055 | 9,055 |
| ៧ | ខេត្តកណ្ដាល | 19 | 14 | 8 | 39 | 3,688 | 3,688 |
| ៨ | ខេត្តក្រចេះ | 12 | 8 | 3 | 12 | 1,315 | 1,315 |
| ៩ | ខេត្តព្រៃវែង | 10 | 8 | 6 | 11 | 2,000 | 2,000 |
| ១០ | ខេត្តពោធិ៍សាត់ | 7 | 7 | 3 | 4 | 1,678 | 1,678 |
| ១១ | ស្វាយរៀង | 25 | 13 | 3 | 4 | 3,993 | 3,993 |
| ១២ | ខេត្តតាកែវ | 6 | 3 | 3 | 6 | 695 | 695 |
| ១៣ | ខេត្តប៉ៃលិន | 3 | 1 | 1 | 4 | 925 | 925 |
| ១៤ | ខេត្តត្បូងឃ្មុំ | 9 | 9 | 4 | 88 | 1,088 | 1,088 |
| សរុបទាំង ១៤ខេត្ត | | 182 | 113 | 54 | 417 | 39,022 | 39,022 |

តារាងទី ១១: ខេត្តដែលត្រូវបានអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវប្រាំង




ក្រាហ្វិកទី ១៤: ចំនួនគម្រោងជួសជុលបន្ទាន់នៅតាមបណ្ដាខេត្តទាំង ១៤




ក្រាហ្វិកទី ១៥: សមិទ្ធផលពីការងារជួសជុលបន្ទាន់





រូបភាពទី ២៣: សកម្មភាពការងារជួសជុលបន្ទាន់ទំនប់ការពារទឹកប្រៃព្រែនប់ ស្ថិតនៅខេត្តព្រះសីហនុ





រូបភាពទី ២៤: សកម្មភាពការងារជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រប្រឡាយបឹងក្រពឹក ស្ថិតនៅខេត្តកំពង់ចាម



*រូបភាពទី ២៥: សកម្មភាពការងារជួសជុលបន្ទាន់សំណង់ទ្វារទឹកអ៊ុងប៉ាង និងស្ពានប្រឡាយនាំទឹក ស្ថិតនៅខេត្តកណ្តាល*



*រូបភាពទី ២៦: សកម្មភាពអន្តរាគមន៍បូមទឹក*

### ៤.២.២. ការងារវិស្វកម្មធនធានទឹក

ក្នុងឆ្នាំ ២០២៥ ក្រសួងធនធានទឹក និងឧតុនិយម បានផ្តោតលើការរៀបចំ និងអនុវត្តគម្រោងវិស្វកម្ម ដើម្បីអភិវឌ្ឍន៍ធនធានទឹក តាមរយៈការស្តារ និងការសាងសង់ប្រព័ន្ធធារាសាស្រ្ត ដែលមានលក្ខណៈសេដ្ឋកិច្ចខ្ពស់។ កិច្ចការសំខាន់ៗក្នុងវិស័យវិស្វកម្ម រួមមាន ការសិក្សា ការរៀបចំគម្រោងស្ថាបត្យកម្ម ការសាងសង់ប្រព័ន្ធធារាសាស្រ្ត និងអាងស្តុកទឹក។ ទស្សនវិស័យសម្រាប់ក្រសួងធនធានទឹក និងឧតុនិយម បានកំណត់ឱ្យមានការវិនិយោគកាន់តែច្រើនលើការស្តារប្រព័ន្ធធារាសាស្រ្ត និងការកសាងគម្រោងថ្មីៗ ដើម្បីសុវត្ថិភាពទឹក ទប់ស្កាត់គ្រោះទឹកជំនន់ និងបង្កើនការផ្គត់ផ្គង់ទឹក។

ប្រព័ន្ធធារាសាស្រ្តដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សាប្រភពទឹករួមមាន ទំនប់ ប្រឡាយ ស្ថានីយបូមទឹក និងប្រព័ន្ធធារាសាស្រ្តផ្សេងទៀត ដែលមានស្ថិតិលម្អិតក្នុងផែនការយុទ្ធសាស្រ្តថវិការបស់នាយកដ្ឋានវិស្វកម្ម។ ធនធានទឹកមានសារៈសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដូចជាជួយដល់វិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម ថាមពលអគ្គិសនី គមនាគមន៍ នាវាចរណ៍ វប្បធម៌ ទេសចរណ៍ ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងជួយផ្គត់ផ្គង់ទឹកប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទាំងនៅទីក្រុង និងជនបទ។ជាលទ្ធផល នាយកដ្ឋានបានសម្រេចការងារក្នុងឆ្នាំ២០២៥ មានដូចខាងក្រោម៖

បានអនុវត្តលើគម្រោងប្រព័ន្ធធារាសាស្រ្ត ចំនួន ២៣គម្រោង (ដេញថ្លៃចំនួន ៤គម្រោង) នៅតាមបណ្តាខេត្ត ចំនួន ១៥ខេត្ត រួមមានខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកណ្តាល ខេត្ត

កោះកុង ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ ដែលជួយបង្កើនលទ្ធភាពស្រោចស្រពផ្ទៃដីស្រូវសរុប ៤៩,១២៩ហ.ត ក្នុងនោះ( ស្រូវវស្សា ចំនួន ២៤,៥៨៧ហ.ត និង ស្រូវប្រាំង ចំនួន ២២,៣៧៨ហ.ត )និងដំណាំរួមផ្សំចំនួន១,៧៩៤ហ.ត។




*ក្រាហ្វិកទី ១៦: សមិទ្ធផលនៃការអនុវត្តគម្រោង២០២៥*




*ក្រាហ្វិកទី ១៧: ផ្ទៃដីស្រោចស្រព*




| | ខេត្តបន្ទាយមានជ័យ | ខេត្តបាត់ដំបង | ខេត្តកំពង់ធំ | ខេត្តកំពង់ចាម | ខេត្តកំពង់ស្ពឺ | ខេត្តកំពត | ខេត្តកណ្ដាល | ខេត្តកោះកុង | ខេត្តសៀមរាប | ខេត្តព្រៃវែង | ខេត្តពោធិ៍សាត់ | ខេត្តស្វាយរៀង | ខេត្តត្បូងឃ្មុំ | ខេត្តតាកែវ | ខេត្តឧត្តរមានជ័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វស្សា | 1036 | 2257 | 4094 | 1860 | 960 | 1010 | 1100 | 600 | 1325 | 650 | 4333 | 600 | 450 | 2139 | 2173 |
| ប្រាំង | 2680 | 1628 | 7652 | 800 | 596 | 404 | 995 | 550 | 2231 | 650 | 1538 | 250 | 876 | 1504 | 394 |
| ដំណាំរួមផ្សំ | 150 | 68 | 71 | 35 | 60 | 250 | 45 | 330 | 30 | 20 | 165 | 20 | 297 | 145 | 108 |

*ក្រាហ្វិកទី ១៨: ផ្ទៃដីស្រោចស្រពតាមបណ្ដាខេត្តទាំង ១៥*




*ផែនទី ១: ផែនទីបង្ហាញពីទីតាំងនៃការអនុវត្តគម្រោង២០២៥*

## ក.គម្រោងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ ចំនួន ១៩គម្រោង (ដេញថ្លៃចំនួន ២គម្រោង)

| ល.រ | លទ្ធផលការងារ | [illegible] | | | ខេត្ត | ប្រភពទឹក |
|---|---|---|---|---|---|---|
| | | ទំនប់ | ប្រឡាយ | សំណង់ | | |
| ១ | ស្តារអូរតាកេរ្តិ៍ ស្ថិតនៅឃុំស្ទើងជ័យ ស្រុកជើងព្រៃ | | ១,៧៥០ | ២ | កំពង់ចាម | ទំនប់ទឹកថា |
| ២ | ស្តារប្រឡាយរងបន្ទាយស្ទោង (ដំណាក់កាល១) ស្ថិតនៅឃុំបន្ទាយស្ទោង ស្រុកស្ទោង | | ៣,៤០០ | ៦ | កំពង់ធំ | ប្រព័ន្ធធារាសាស្ត្រ ៣០កញ្ញា និងស្ទឹងស្ទោង |
| ៣ | ស្តារឡើងវិញប្រឡាយតាហោ ស្ថិតនៅឃុំចុងដូង ឃុំបារាយណ៍ ស្រុកបារាយណ៍ | | ៣,១៥០ | ៣ | | ស្ទឹងតូច និងស្ទឹងជីនិត |
| ៤ | ជួសជុលទំនប់អាងទឹកពាម (ដំណាក់កាល២) ស្ថិតនៅឃុំម្សាក្រង ស្រុកស្ទោង | ៦,០០០ | | ៧ | | ស្ទឹងស្ទោង |
| ៥ | ស្ថាបនាកែលម្អភ្លឺខ្នងសងខាងព្រែកទឹកដោះ ស្ថិតនៅឃុំកំពង់អុស ស្រុកពញាឮ | | ២,១០០ | ១ | កណ្តាល | ទន្លេសាប |
| ៦ | ស្ថាបនាលើកកម្រិតខ្នងភ្លឺប្រឡាយសន្លុងដោយចាក់បេតុងពីលើ ស្ថិតនៅឃុំសន្លុង ស្រុកខ្សាច់កណ្តាល | | | ១ | | ប្រឡាយមេសន្លុង |
| ៧ | ជួសជុលទំនប់ការពារទឹកប្រៃចំការលើ (ដំណាក់កាល១) ស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ | ២,៥០០ | | | កោះកុង | |
| ៨ | ជួសជុលទំនប់អាងទឹកជ្រោយប្រស់ទី២ (ដំណាក់កាល២) ស្ថិតនៅឃុំជ្រោយប្រស់ ស្រុកកោះកុង | ១,១៤០ | | ៣ | | |
| ៩ | ជួសជុលទំនប់អាងទឹកអ្នកតាធំ ស្ថិតនៅឃុំអន្សាចំបក់ ស្រុកក្រគរ | ១,៥០០ | | ៣ | ពោធិ៍សាត់ | ផ្ទៃរងទឹកភ្លៀងជួរភ្នំក្រវាញ |
| ១០ | ស្តារអូរយាយហុក (ដំណាក់កាល១) ស្ថិតនៅឃុំតាលោ ស្រុកតាលោសែនជ័យ | | ៤,០០០ | ១៥ | | សំណង់ដំណាក់ឈើក្រំ |
| ១១ | សាងសង់សំណង់ស្នាក់ទឹកពោធិ៍អណ្តែត (ដំណាក់កាល២) ស្ថិតនៅឃុំកញ្ជរ ស្រុកកណ្តៀង | | | ១ | | ស្ទឹងពោធិ៍សាត់ |
| ១២ | ជួសជុលទំនប់អាងទឹកស្លូង៧៨ (ដំណាក់កាល២) ស្ថិតនៅឃុំស្ពានត្នោត ស្រុកជីក្រែង | ៤,៨០០ | | ៧ | សៀមរាប | ស្ទឹងជីក្រែង |
| ១៣ | ជួសជុលទំនប់សណ្តារអាងទឹកគៀនតាស៊ីវ (ដំណាក់កាល៣) ស្ថិតនៅឃុំស្វាយយា ស្រុកស្វាយជ្រំ | ៣,៨២០ | | ៤ | ស្វាយរៀង | ពីទំនប់ដៃគូ |
| ១៤ | ស្តារប្រឡាយមេរំដោះទឹកស្រះកែវ (ដំណាក់កាល១) ស្ថិតនៅឃុំក្រាំងលាវ ស្រុកបាទី និងឃុំខ្វាវ ស្រុកសំរោង | | ៤,៦០០ | ១៥ | តាកែវ | ផ្ទៃរងទឹកភ្លៀងភ្នំស្រង់ |
| ១៥ | ជួសជុលទំនប់អាងទឹកកណ្តែក ស្ថិតនៅសង្កាត់កូនក្រៀល ក្រុងសំរោង | ៣,២០០ | | ៤ | ឧត្តរមានជ័យ | |
| ១៦ | ជួសជុលទំនប់អាងទឹកទំនប់ថ្មី (ដំណាក់កាល៣) ស្ថិតនៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង | ២,០០០ | | ៣ | | |
| ១៧ | ជួសជុលទំនប់អាងទឹកបឹងធំ ស្ថិតនៅឃុំការខ្នុរ ស្រុកក្រូចឆ្មារ | ៤,៨៣០ | | ៣ | ត្បូងឃ្មុំ | ទន្លេមេគង្គ |
| ១៨ | ជួសជុលប្រព័ន្ធអាងទឹកចាន់ថ្នាល ស្ថិតនៅឃុំក្រាំងចេក ស្រុកសាមគ្គីមុនីជ័យ | ៧០០ | ១,៥០០ | ៧ | កំពង់ស្ពឺ | ទំនប់អូរស្សា និងអូរក្រសាំង |
| ១៩ | ស្តារប្រឡាយរងកន្លោង ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ | | ២,៨៥០ | ១១ | ព្រៃវែង | អាងទឹកស្នេហ៍ |

*តារាងទី ១២: គម្រោងស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ*



*រូបភាពទី ២៧: ស្ថានភាពទំនប់អាងទឹកជ្រោយប្រស់ទី២ (ដំណាក់កាល២) ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង*





*រូបភាពទី ២៨: ស្ថានភាពសំណង់ស្ទាក់ទឹកពោធិ៍អណ្តែត (ដំណាក់កាលទី២) ឃុំកញ្ជរ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់*




*រូបភាពទី ២៩: ស្ថានភាពទំនប់អាងទឹកស្ទួង៧៨ (ដំហាន២) ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប*

## ខ. គម្រោងពង្រឹងសក្តានុពលប្រព័ន្ធធារាសាស្ត្រ ចំនួន ៤គម្រោង (ដេញថ្លៃចំនួន ២គម្រោង)

| ល.រ | លទ្ធផលការងារ | ទំហំការងារ | | | ខេត្ត | ប្រភពទឹក |
|---|---|---|---|---|---|---|
| | | ទំនប់ | ប្រឡាយ | សំណង់ | | |
| ១ | ស្តារអូរប្រឡាយក្តាន់ (ដំហាន២) ស្ថិតនៅឃុំហោត់ទឹក ស្រុកមង្គលបុរី | | ៥,០០០ | ១៤ | បន្ទាយមានជ័យ | |
| ២ | ស្តារប្រឡាយមេជ័យលាភី (ដំហាន២) ស្ថិតនៅឃុំកន្ទឺ២ និងឃុំបាយដំរាំ ស្រុកបាណន់ | | ៥,០០០ | ១៤ | បាត់ដំបង | សំណង់កង្ហត |
| ៣ | ស្តារប្រឡាយមេប្រផុង(ដំហាន២) ឃុំសំរោងលើ និងឃុំសំរោងក្រោម ស្រុកបន្ទាយមាស | | ៣,០០០ | ១៥ | កំពត | ស្ទឹងដំណាក់សុក្រម |
| ៤ | ស្តារប្រឡាយមេភ្នំដិនសោម (ដំហាន២) ឃុំភ្នំដិន ឃុំគីរីចុងកោះ និងឃុំសោម ស្រុកគីរីវង់ | | ៣,០០០ | ៨ | តាកែវ | ព្រែកវិញតេ |

*តារាងទី ១៣: គម្រោងពង្រឹងសក្តានុពលប្រព័ន្ធធារាសាស្ត្រ*





*រូបភាពទី ៣០: ស្ថានភាពអូរប្រឡាយក្តាន់ (ដំហាន២) ឃុំហោត់ទឹក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ*

## គ. គម្រោងត្រៀមបម្រុង ចំនួន ២គម្រោង

| ល.រ | លទ្ធផលការងារ | ទំហំការងារ | | | ខេត្ត |
|---|---|---|---|---|---|
| | | ទំនប់ | ប្រឡាយ | សំណង់ | |
| ១ | ស្តាបនាលើកកម្រិតខ្នងទំនប់សណ្តរខាងក្នុងស្ទឹងព្រែកត្នោត (ព្រៃស) ស្ថិតនៅភូមិ៣ម សង្កាត់ព្រៃស ខណ្ឌដង្កោ | ១.០០០ | | ២ | រាជធានីភ្នំពេញ |
| ២ | ជួសជុលទំនប់អាងទឹកព្រែកសំរោង៣ និងសាងសង់សំណង់សិល្បការ្យ ស្ថិតនៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ | ១.១៨០ | | ១ | កណ្តាល |

*តារាងទី ១៤: គម្រោងត្រៀមបម្រុង*

### ឃ. ការងារជួសជុលបន្ទាន់

ក្នុងឆ្នាំ២០២៥នេះ នាយកដ្ឋានវិស្វកម្មបានធ្វើការជួសជុលបន្ទាន់នូវប្រព័ន្ធធារាសាស្ត្រដែលរងការបាក់ស្រុតបេតុងជើងទេ ការកាយបិទរូងនាគ និងការកាយបើកមុខទឹកបានចំនួន ៥កន្លែង រួមមានដូចខាងក្រោម៖

| ល.រ | ការងារជួសជុលបន្ទាន់ | ខេត្ត |
|---|---|---|
| ១ | សំណង់ស្នាក់ទឹកសាលាតាអន ស្ថិតឃុំព្រែកនរិន្ទ និងឃុំព្រែកខ្ពប ស្រុកឯកភ្នំ | ខេត្តបាត់ដំបង |
| ២ | ទំនប់អូរក្បៀរ ស្ថិតឃុំស្វាយរំពារ ស្រុកបរសេដ្ឋ | ខេត្តកំពង់ស្ពឺ |
| ៣ | លុបរូងនាគនៅភូមិបន្ទាយស្ទោង ស្ថិតឃុំបន្ទាយស្ទោង ស្រុកស្ទោង | ខេត្តកំពង់ធំ |
| ៤ | កាយបើកមុខទឹកសង្គ្រោះស្រូវប្រាំង ស្ថិតឃុំបន្ទាយស្ទោង ស្រុកស្ទោង | |
| ៥ | ស្តារបើកមុខទឹកប្រឡាយភូមិល្វេស ស្ថិតឃុំបន្ទាយស្ទោង ស្រុកស្ទោង | |

*តារាងទី ១៥: ការងារជួសជុលបន្ទាន់*




*រូបភាពទី ៣១: ការបាក់ស្រុតបេតុងជើងទេខាងឆ្វេង នៅសំណង់ស្នាក់ទឹកសាលាតាអន*




*រូបភាពទី ៣២: ការកាយរូងនាគ និងចាក់ដីកិនបង្ហាប់ទំនប់អូរក្បៀរ*

### ង. គម្រោងបន្ថែមអនុវត្តចុងឆ្នាំ២០២៥ ចំនួន ១គម្រោង

គម្រោងសាងសង់ទំនប់អាងទឹកវិទ្យាស្ថានពហុជំនាញ តេជោសែន និងសាងសង់សំណង់សិល្បការ្យ នៅឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ។





*រូបភាពទី ៣៣: ការសាងសង់ទំនប់អាងទឹកវិទ្យាស្ថានពហុជំនាញ តេជោសែន និងសាងសង់សំណង់សិល្បការ្យ*

### ៤.២.៣. ការងារជលសាស្ត្រ និងទន្លេ

នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ គឺជាអង្គភាពបច្ចេកទេសដែលមានតួនាទីស្នូល ក្នុងការរៀបចំកសាងគម្រោងដំឡើងស្ថានីយជលសាស្ត្រលើទីតាំងប្រភពទឹកសំខាន់ៗបម្រើដល់ការអភិវឌ្ឍន៍វិស័យធនធានទឹក កសាងគម្រោងផែនការរយៈពេលខ្លី មធ្យម និងវែងលើការងារការហូរច្រោះ កំណកដី និងការបាក់ច្រាំងទន្លេ ព្រែក ស្ទឹង បឹងបួរ ធ្វើការស្រាវជ្រាវតាមដាននូវរាល់របបជលសាស្ត្រ ប្រមូលទិន្នន័យ ការវាស់កម្ពស់ទឹក ជារទឹក កករទឹក ការពិនិត្យតាមដានគុណភាពទឹកនៅតាមស្ថានីយជលសាស្ត្រសំខាន់ៗ សិក្សាស្រាវជ្រាវបាតុភូតជលសាស្ត្រ គំរូជលសាស្ត្រ ជលគណនា ជលគតិ និងសក្តានុពលទឹកលើដី និងក្រោមដី ការគ្រប់គ្រង និងផ្លាស់ប្តូរព័ត៌មានជលសាស្ត្រព្រមទាំងធ្វើការព្យាករ និងជូនដំណឹងជាមុននូវគ្រោះទឹកជំនន់ ដែលអាចកើតមានឡើង ដើម្បីមានវិធានការទាន់ពេលវេលា រៀបចំប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលពាក់ព័ន្ធទៅនឹងការវិវត្តន៍ នៃវិស័យធនធានទឹក និងឧតុនិយម ក្នុងការបម្រើដល់វិស័យនានាដែលពាក់ព័ន្ធនឹងទឹក។

ការត្រួតពិនិត្យ តាមដានរបបជលសាស្ត្រ និងការងារច្រាំងទន្លេ ផ្តោតលើការតាមដានស្ថានភាពទន្លេ និងប្រព័ន្ធជលសាស្ត្រ។ ក្រសួងធនធានទឹក និងឧតុនិយម តាមរយៈនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ បានអនុវត្តសកម្មភាពតាមដានស្ថានភាពជលសាស្ត្រ ពិនិត្យស្ថានភាពច្រាំងទន្លេដែលប្រឈមនឹងការបាក់ច្រាំង ។ លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០២៥ មានដូចជា៖

#### ក. ការងារគ្រប់គ្រងទិន្នន័យ និងព្យាករណ៍ទឹកជំនន់

ស្ថានីយជលសាស្ត្រមានការវិវត្តយ៉ាងលឿនចាប់ពីឆ្នាំពី២០១៥ មកដល់ឆ្នាំ២០១៩ មានការកើនឡើងខ្លាំង ដោយមានការជួយគាំទ្រពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា និងគណៈកម្មធិការជាតិទន្លេមេគង្គកម្ពុជា ដែលស្ថានីយជលសាស្ត្រស្វ័យប្រវត្តិមានចំនួន ១២ស្ថានីយ នៅមុនឆ្នាំ២០១៥ ដល់ចំនួន ៧៨ស្ថានីយ នៅឆ្នាំ២០១៩ តែមកដល់ឆ្នាំ២០២៥នេះ ស្ថានីយជលសាស្ត្រស្វ័យប្រវត្តិដែលនៅដំណើរការមានចំនួន ៦៣ស្ថានីយ ដោយមានការថយចុះជាបន្តបន្ទាប់នាពេលថ្មីៗនេះ ព្រោះឧបករណ៍ស្ថានីយទាំងនោះមានអាយុកាលយូរឆ្នាំមកហើយ និងគ្មានគ្រឿងបន្លាស់គ្រប់គ្រាន់សម្រាប់ដោះដូរ។ ចំណែកស្ថានីយជលសាស្ត្រ មិនស្វ័យប្រវត្តិមានចំនួន ៣០ ស្ថានីយ។ នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេបានធ្វើការតាមដានប្រមូលកម្ពស់ទឹក នៅតាមដងទន្លេ មេគង្គ ទន្លេសាប ទន្លេបាសាក់ និងដៃទន្លេសំខាន់ៗមួយចំនួន ជាប្រចាំសប្តាហ៍នៅរដូវប្រាំង ហើយបានព្យាករណ៍កម្ពស់ទឹក ជាប្រចាំថ្ងៃ ទាំងរដូវប្រាំង និងវស្សា។ ការដាក់បញ្ចូលព័ត៌មានជលសាស្ត្រនៅលើគេហទំព័ររបស់នាយកដ្ឋាន និងបានបញ្ចូលទិន្នន័យដែលទទួលបានពីបណ្តាស្ថានីយជលសាស្ត្រនានាចូលក្នុងកុំព្យូទ័រផ្ទុកទិន្នន័យ (Database)។ បានធ្វើការផ្លាស់ប្តូរទិន្នន័យជាប្រចាំ ជាមួយប្រទេសជាសមាជិក MRC តាមប្រព័ន្ធ HydMet និងអ៊ីម៉ែល និងបានចុះពិនិត្យ និងថែទាំស្ថានីយ Mekong-Hycos និង AHS (Automatic Hydrological Station)។ នៅក្នុងឆ្នាំ២០២៥នេះ នាយកដ្ឋានបានធ្វើការតាមដានជារៀងរាល់ថ្ងៃទន្លេ ស្ទឹង ចំនួន ១៣កន្លែង និងអាងទឹកសំខាន់ៗចំនួន ៨កន្លែង និងបានដាក់បញ្ចូលទៅក្នុងកម្មវិធីទូរស័ព្ទដៃ (MOWRAM APP)



# ព្រឹត្តិបត្រព័ត៌មាន និងព្យាករណ៍កម្ពស់ទឹក

ក្រសួងធនធានទឹក និងឧតុនិយម
នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ

1. កម្ពស់ទឹកពិនិត្យឃើញនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ វេលាម៉ោង ៧:០០ព្រឹក តាមបណ្តាស្ថានីយជលសាស្ត្រ៖

| ឈ្មោះស្ថានីយ | ទឹកមានកម្ពស់ (ម៉ែត្រ) | ធៀបម្សិលមិញ (ម៉ែត្រ) | ធៀបឆ្នាំមុន (ម៉ែត្រ) | ធៀបមធ្យម (ម៉ែត្រ) | ទឹកភ្លៀង (មម) ១៥-កញ្ញា-២០២៥ | កម្រិតកម្ពស់ប្រុងប្រយ័ត្ន (ម៉ែត្រ) |
|---|---|---|---|---|---|---|
| ១-ទន្លេមេគង្គ-ស្ទឹងត្រែង (Stung Treng) | 8.11 | +0.24 | -0.48 | -0.40 | 0.0 | 10.70 |
| ២-ទន្លេមេគង្គ-ក្រចេះ (Kratie) | 18.53 | -0.16 | +0.26 | -0.31 | 0.0 | 22.00 |
| ៣-ទន្លេមេគង្គ-កំពង់ចាម (Kg.Cham) | 12.36 | -0.26 | +1.00 | -0.75 | 6.5 | 15.20 |
| ៤-ទន្លេបាសាក់-ចតុមុខ (Chaktomuk) | 8.29 | -0.09 | +1.13 | -0.39 | 24.7 | 10.50 |
| ៥-ទន្លេមេគង្គ-អ្នកលឿង (Neak Loeung) | 5.94 | -0.06 | +0.93 | -0.33 | 2.2 | 7.50 |
| ៦-ទន្លេបាសាក់-កោះខែល (Koh Khel) | 7.16 | -0.06 | +0.74 | +0.29 | 26.7 | 7.90 |
| ៧-ទន្លេសាប-ព្រែកក្តាម (Prek Kdam) | 7.32 | -0.06 | +1.10 | -0.30 | 0.0 | 9.50 |
| ៨-បឹងទន្លេសាប-កំពង់លួង (Kampong Luong) | 6.60 | +0.08 | | | | |

I. កម្ពស់ទឹកព្យាករណ៍សម្រាប់ថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ តាមបណ្តាស្ថានីយជលសាស្ត្រ៖

| ឈ្មោះស្ថានីយ | កម្ពស់ទឹកព្យាករណ៍តាមបណ្តាស្ថានីយជលសាស្ត្រ (ម៉ែត្រ) ១៦-កញ្ញា-២០២៥ | ១៧-កញ្ញា-២០២៥ | ១៨-កញ្ញា-២០២៥ |
|---|---|---|---|
| ១-ទន្លេមេគង្គ-ស្ទឹងត្រែង (Stung Treng) | 8.13 ↑ | 8.10 ↓ | 8.06 ↓ |
| ២-ទន្លេមេគង្គ-ក្រចេះ (Kratie) | 18.82 ↑ | 18.91 ↑ | 18.85 ↓ |
| ៣-ទន្លេមេគង្គ-កំពង់ចាម (Kg.Cham) | 12.33 ↓ | 12.45 ↑ | 12.51 ↑ |
| ៤-ទន្លេបាសាក់-ចតុមុខ (Chaktomuk) | 8.23 ↓ | 8.20 ↓ | 8.22 ↑ |
| ៥-ទន្លេមេគង្គ-អ្នកលឿង (Neak Loeung) | 5.91 ↓ | 5.87 ↓ | 5.85 ↓ |
| ៦-ទន្លេបាសាក់-កោះខែល (Koh Khel) | 7.13 ↓ | 7.10 ↓ | 7.07 ↓ |
| ៧-ទន្លេសាប-ព្រែកក្តាម (Prek Kdam) | 7.28 ↓ | 7.24 ↓ | 7.22 ↓ |

ស្ថានភាពទឹកទន្លេ ៖ ស្ថានីយជលសាស្ត្រទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ទឹកបាននិងកំពុងឡើងនិងស្រកបន្តិចបន្តួចៗ
ការផ្សាយរបស់ក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥




*រូបភាពទី ៣៤: ព្រឹត្តិបត្រព័ត៌មាន និងព្យាករណ៍កម្ពស់ទឹក និងសេចក្តីជូនដំណឹងស្តីពីស្ថានភាពទឹកជំនន់*







*រូបភាពទី ៣៥: ផែនទីស្ថានីយជលសាស្ត្រតាមអាងស្ទឹងក្នុងប្រទេសកម្ពុជា និងគេហទំព័រនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ www.dhrw-cam.org*







*ក្រាហ្វិកទី ១៩: ក្រាហ្វិកបង្ហាញពីកម្ពស់ទឹកនៅតាមបណ្តាស្ថានីយជលសាស្ត្រលើទន្លេមេ*

## ខ. ការងារជលសាស្ត្រ

ការជួសជុល និងថែទាំស្ថានីយជលសាស្ត្រ ត្រូវបានធ្វើឡើងនៅតាមផែនការ និងតម្រូវការចាំបាច់ របស់ក្រសួងធនធានទឹក និងឧតុនិយម ដោយបានធ្វើការវាស់កម្ពស់ទឹក និងវាស់ធារទឹក ដើម្បីប្រមូលទិន្នន័យជលសាស្ត្រ បម្រើដល់ការអភិវឌ្ឍវិស័យធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ និងដល់អ្នកសិក្សាស្រាវជ្រាវនានាជាដើម។ នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ បានដំឡើងស្ថានីយជលសាស្ត្រ ៤កន្លែង ជួសជុលស្ថានីយជលសាស្ត្រ ៦កន្លែង និងជួសជុលក្តារម៉ែត្រវាស់កម្ពស់ទឹក ២កន្លែង។



*រូបភាពទី ៣៦: រូបភាពសកម្មភាពជួសជុល និងថែទាំស្ថានីយជលសាស្ត្រ និងក្តារម៉ែត្រវាស់កម្ពស់ទឹក*



*រូបភាពទី ៣៧: រូបភាពសកម្មភាពវាស់ធារទឹកដោយឧបករណ៍ Current Meter និង ADCP*

## គ. គម្រោងការពារច្រាំងទន្លេ

គម្រោងការពារច្រាំងទន្លេ ត្រូវបានអនុវត្តជារៀងរាល់ឆ្នាំ ដោយចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥នេះ បានប្រវែង ១៥,២២៥ម៉ែត្រ ដែលក្នុងនោះឆ្នាំ២០២៥ បានប្រវែង ៣,៧០០ម៉ែត្រ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| ច្រាំងទន្លេ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | ឆ្នាំ២០២៥ |
|---|---|---|---|
| ប្រវែង (ម៉ែត្រ) | ៦,៨២០ | ៤,៧០៥ | ៣,៧០០ |
| សរុបបន្តបន្ទាប់ | | ១១,៥២៥ | ១៥,២២៥ |

ការអនុវត្តគម្រោងការពារច្រាំងទន្លេក្នុងឆ្នាំ២០២៥ បានចំនួន ៩គម្រោងរួមមាន៖

| ល.រ | គម្រោង | ប្រវែង (ម៉ែត្រ) | ខេត្ត |
|---|---|---|---|
| ១ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល | ២៥០ | ខេត្តកណ្ដាល |
| ២ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិការកោង ឃុំការកោង១ ស្រុកមុខកំពូល | ៤៥០ | |
| ៣ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិពាម ឃុំការកោង១ ស្រុកមុខកំពូល | ២០០ | |
| ៤ | គម្រោងការពារច្រាំងទន្លេបាសាក់ នៅសង្កាត់ព្រែកជ្រៃ ក្រុងសំពៅពូន | ៥០០ | |
| ៥ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ | ៥០០ | ខេត្តកំពង់ចាម |
| ៦ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅព្រែកស្តី ឃុំព្រះអណ្ដូង ស្រុកស្ទឹងត្រង់ (ដំហាន១) | ៣៥០ | |
| ៧ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិខ្លបតាងួន ឃុំខ្លបតាងួន ស្រុកស្ទឹងត្រង់ | ៣៥០ | |
| ៨ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិបឹងកាចូត ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ | ៤០០ | |
| ៩ | គម្រោងការពារច្រាំងទន្លេមេគង្គ នៅព្រែកស្តី ឃុំព្រះអណ្ដូង ស្រុកស្ទឹងត្រង់ (ដំហាន២) | ៧០០ | |
| | សរុប | ៣ ៧០០ | |





*រូបភាពទី ៣៨: គម្រោងការពារច្រាំងទន្លេមេគង្គ នៅពាមក្រៅ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម*





*រូបភាពទី ៣៩: គម្រោងការពារច្រាំងទន្លេមេគង្គ ស្ថិតនៅព្រែកស្តី ឃុំព្រះអណ្ដូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម (ដំហាន១ និងដំហាន២)*





*រូបភាពទី ៤០: គម្រោងការពារច្រាំងទន្លេមេគង្គ ស្ថិតនៅភូមិខ្លបតាងួន ឃុំខ្លបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម*



*រូបភាពទី ៤១: គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិបឹងកាចូត ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម*



*រូបភាពទី ៤២: គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិពាម ឃុំកោះកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល*



*រូបភាពទី ៤៣: គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិកោះកោង ឃុំកោះកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល*



*រូបភាពទី ៤៤: គម្រោងការពារច្រាំងទន្លេមេគង្គ នៅភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល*



*រូបភាពទី ៤៥: គម្រោងការពារច្រាំងទន្លេបាសាក់ ស្ថិតនៅសង្កាត់ព្រែកជ្រៃ ក្រុងសំពៅពូន ខេត្តកណ្ដាល*

### ឃ. ការត្រួតពិនិត្យតាមដាន និងវិភាគគុណភាពទឹក

ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពទឹកនៅតាមដងទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ ព្រមទាំងដៃទន្លេសំខាន់ៗ មួយចំនួន ត្រូវបានធ្វើជាប្រចាំខែ រៀងរាល់ឆ្នាំ ដោយបានចុះយកសំណាកទឹក កករដី ចំនួន ១៩ស្ថានីយ និងការវិភាគគុណភាពទឹក ចំនួន១៨ប៉ារ៉ាម៉ែត្រ ហើយបានត្រួតពិនិត្យ និងបញ្ចូលទិន្នន័យ ទៅក្នុងប្រព័ន្ធកុំព្យូទ័រផ្ទុកទិន្នន័យ។




List of sampling stations and location

| Station Name | Station Code | River/ Stung | X | Y |
|---|---|---|---|---|
| Stung Treng | H 014501 | Mekong | 609978 | 1497635 |
| Kratie | H 014901 | Mekong | 610846 | 1378739 |
| Kampong Cham | H 019802 | Mekong | 551047 | 1325954 |
| Chroy Changvar | H 019801 | Mekong | 493530 | 1280781 |
| Neak Loeung | H 019806 | Mekong | 530483 | 1244518 |
| Kaorm Samnor | H 019807 | Mekong | 522778 | 1223497 |
| Phnom Krom | H 020108 | Tonle Sap Lake | 371882 | 1469940 |
| Kampong Loung | H 020106 | Tonle Sap Lake | 415402 | 1393110 |
| Back Prea | H 020107 | Sangkeo | 465434 | 1356366 |
| Kampong Chhnang | H 020103 | Tonle Sap | 479001 | 1306141 |
| Prek Kdam | H 020102 | Tonle Sap | 491622 | 1280856 |
| Phnom Penh Port | H 020101 | Tonle Sap | 494877 | 1268892 |
| Takhmao | H 033401 | Bassac | 503189 | 1245571 |
| Koh Khel | H 033402 | Bassac | 507402 | 1227630 |
| Koh Thom | H 033403 | Bassac | 326601 | 1471822 |
| Phum Pi | H 440102 | Sesan | 764736 | 1526003 |
| Angdoung Meas | H 440103 | Sesan | 727529 | 1553933 |
| Lumphat | H 450101 | Sreprok | 665380 | 1498414 |
| Siempang | H 430102 | Sekong | 650399 | 1561352 |

*ផែនទី ២: ផែនទីទីតាំងស្ថានីយគុណភាពទឹកក្នុងប្រទេសកម្ពុជា*

| No | Analytical parameter | Analytical Methods | Methods Code |
|---|---|---|---|
| 1 | Temperature | Thermometer | 2550-Temp/SM |
| 2 | pH | Electrometric | 4500-$H^+$/SM |
| 3 | Conductivity | Electrometric | 2510-Ec/SM |
| 4 | Total Suspended Solid | 105° c | |
| 5 | Ca | EDTA Titration | 3500-Ca-B/SM |
| 6 | Mg | EDTA Titration | 3500-Mg-B/SM |
| 7 | Na | Flame Photometer | 3500-Na-B/SM |
| 8 | K | Flame Photometer | 3500-K-B/SM |
| 9 | Cl | Mercurimetric | 4500-Cl/SM |
| 10 | $SO_4$ | Turbid | 4500-$SO_4$/SM |
| 11 | Alkalinity/ Acidity | Titration | 2320-A/SM |
| 12 | Dissolved Oxygen (DO) | Winkler | 4500-O/SM |
| 13 | Chemical Oxygen Demand (COD) | Permanganate Oxidation | 5220-COD/SM |
| 14 | Total phosphorous (T-P) | Digestion with $K_2S_2O_8$ | 4500-P/SM |
| 15 | Total Nitrogen (T-N) | Digestion with $K_2S_2O_8$ | 4500-N/SM |
| 16 | Ammonium ($NH_4$-N) | Indophenols blue | 4500-$NH_4$/SM |
| 17 | Nitrite ($NO_2$-N) | | 4500-$NO_{2-3}$/SM |
| 18 | Nitrate $NO_3$ -N | Cd reduction | 4500-$NO_{2-3}$/SM |
| 19 | Faecal Coliform | Multi tube | |

*តារាងទី ១៦: ប៉ារ៉ាម៉ែត្រគុណភាពទឹក*

| No. | St. Name | River | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|---|
| 1 | Stung Treng | Mekong | A | A | A | B | A | A |
| 2 | Kratie | Mekong | A | A | A | B | A | A |
| 3 | Kampong Cham | Mekong | A | A | A | B | A | A |
| 4 | Chroy Chanvar | Mekong | A | A | A | B | A | A |
| 5 | Neak Loeung | Mekong | A | A | A | B | A | A |
| 6 | Kaorm Samnor | Mekong | A | A | A | B | A | A |
| 7 | Phnom Krom | Tonle Sap Lake | B | B | A | B | B | B |
| 8 | Kampong Loung | Tonle Sap Lake | B | B | B | B | B | B |
| 9 | Kampong Chhnang | Tonle Sap | B | B | B | B | A | A |
| 10 | Prek Kdam | Tonle Sap | B | B | B | B | A | A |
| 11 | Phnom Penh Port | Tonle Sap | B | A | A | B | A | A |
| 12 | Takhmao | Basac | B | B | B | B | A | A |
| 13 | Khos Khel | Basac | B | A | A | B | A | A |
| 14 | Khos Thom | Basac | B | A | A | B | A | A |
| 15 | Back Prea | Sangkeo | B | B | B | B | B | B |
| 16 | Phum Pi | Se San | B | A | A | B | A | A |
| 17 | Angdoung Meas | Se San | A | A | A | B | A | A |
| 18 | Lumphat | Srepork | B | A | A | B | A | A |
| 19 | Siempang | Sekong | A | A | A | B | A | A |

*តារាងទី ១៧: ចំណាត់ថ្នាក់គុណភាពទឹកសម្រាប់ការពារជីវិតក្នុងទឹក*

A-គុណភាពល្អប្រសើរ B-គុណភាពល្អ

C- គុណភាពមធ្យម D-គុណភាពអន់







*រូបភាពទី ៤៦: សកម្មភាពយកសំណាកទឹក និងកករដី និងសកម្មភាពវិភាគគុណភាពទឹក និងកករដី*

### ៤.២.៤. ការងារឧតុនិយម

ឧតុនិយម ជាការងារបច្ចេកទេសជំនាញសំខាន់មួយដែលមានតួនាទីស្នូលក្នុងការពិនិត្យ តាមដានបាតុភូតធម្មជាតិតាមរដូវរួមមាន ភ្លៀង ផ្គរ រន្ទះ អព្ទ ខ្យល់ព្យុះជាដើម ដែលត្រូវបានប្រើប្រាស់សម្រាប់ការជូនដំណឹង ការស្រាវជ្រាវ និងការព្យាករធាតុអាកាសប្រចាំម៉ោង ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំរដូវ និងប្រចាំឆ្នាំ។ នៅក្នុងឆ្នាំ២០២៥នេះ ប្រទេសកម្ពុជាបានទទួលរងឥទ្ធិពលព្យុះចំនួន ២៧លើក ចាប់ពីខែមិថុនា ដល់ខែធ្នូ ដែលបានធ្វើឱ្យប្រទេសកម្ពុជាយើងជួបនូវគ្រោះទឹកជំនន់នៅតាមបណ្ដាខេត្តមួយចំនួន។ ជារួមលទ្ធផលដែលនាយកដ្ឋានសម្រេចបាននូវសកម្មភាពការងាររួមមានដូចខាងក្រោម៖

#### ក. ការគ្រប់គ្រងទិន្នន័យព័ត៌មាន និងការព្យាករ

នាយកដ្ឋានឧតុនិយម ជានាយកដ្ឋានទទួលបន្ទុកពិនិត្យ សង្កេត ចងក្រងទិន្នន័យព័ត៌មានឧតុនិយម សម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ ព្យាករណ៍ធាតុអាកាស និងអាកាសធាតុ ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំរដូវ និងប្រចាំឆ្នាំ មានជាអាទិ៍៖ កម្ដៅ សីតុណ្ហភាព បរិមាណទឹកភ្លៀង ទិសដៅខ្យល់ និងល្បឿនខ្យល់ សំណើមបរិយាកាស គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ឥទ្ធិពលព្យុះ ផ្គររន្ទះ និងខ្យល់កន្ត្រាក់។ រាល់ទិន្នន័យព័ត៌មានឧតុនិយមទាំងនោះក៏ត្រូវបានប្រើប្រាស់នៅក្នុងវិស័យជាច្រើនដូចជា កសិកម្ម គមនាគមន៍ ទេសចរណ៍ សុខាភិបាល ឧស្សាហកម្ម សំណង់ ។ល។ នាយកដ្ឋានបានសហការជាមួយអ្នកជំនាញផ្នែករ៉ាដា ( ឧតុនិយមបារាំងអន្តរជាតិ MFI ) ជួសជុល និងថែទាំប្រព័ន្ធរ៉ាដាតេដោសែន និងប្រព័ន្ធម៉ូដែលសម្រាប់ព្យាករណ៍ និងបានដំណើរការឡើងវិញនៅលើគេហទំព័រ www.cambodiameteo.com (Radar Animation) និងបានបញ្ចូលប្រព័ន្ធផ្កាយរណប Himawari 8/9 និង GK-2A ឱ្យដំណើរការនៅក្នុងគេហទំព័រនេះផងដែរ (Satellite Animation)។ ក្រសួងធនធានទឹក និងឧតុនិយម ដែលមាននាយកដ្ឋានឧតុនិយមជាសេនាធិការ បានធ្វើការផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានស្ដីពីស្ថានភាពធាតុអាកាស សេចក្ដីជូនដំណឹងស្ដីពីស្ថានភាពព្យុះ និងសេចក្ដីជូនដំណឹងផ្សេងៗទៀតបានចំនួន ៤០៧ដង បានដាក់បញ្ចូលទិន្នន័យព័ត៌មានធាតុអាកាសនៅលើគេហទំព័រនិងMOWRAMAPP។










*រូបភាពទី ៤៧: គេហទំព័រឧតុនិយម www.cambodiameteo.com*



*រូបភាពទី ៤៨: ការផ្សព្វផ្សាយព័ត៌មានអំពីធាតុអាកាស និងការព្យាករអាកាសធាតុ និងសេចក្តីជូនដំណឹងផ្សេងៗជាសាធារណៈ*

### ខ ការងារឧតុនិយម

នាយកដ្ឋានបានធ្វើការជួសជុល ថែទាំស្ថានីយឧតុនិយមស្វ័យប្រវត្តិ ២៧ស្ថានីយ មិនស្វ័យប្រវត្តិ ៤ស្ថានីយ និងតម្រងទឹកភ្លៀង ២២កន្លែង។ បានដំឡើងស្ថានីយឧតុនិយមស្វ័យប្រវត្តិ ១ស្ថានីយ នៅកោះរ៉ុង ខេត្តព្រះសីហនុ និង ៨ស្ថានីយ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ ក្រោមគម្រោងឧតុនិយម-កសិកម្ម (FAO)។



*រូបភាពទី ៤៩: សកម្មភាពជួសជុល ថែទាំស្ថានីយឧតុនិយម និងតម្រងទឹកភ្លៀង និងដំឡើងស្ថានីយឧតុនិយមស្វ័យប្រវត្តិ*

## ៤.២.៥. ការងារសហគមន៍កសិករប្រើប្រាស់ទឹក

សហគមន៍កសិករប្រើប្រាស់ទឹក មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង បែងចែកទឹកសម្រាប់ការដាំដុះ និងការចិញ្ចឹមសត្វ ក៏ដូចជាការផ្គត់ផ្គង់ទឹកសម្រាប់ការប្រើប្រាស់។ សហគមន៍នេះត្រូវបានបង្កើតឡើងក្នុងគោលបំណង បម្រើផលប្រយោជន៍រួមឱ្យប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីរួមចំណែកលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងលើកស្ទួយសេដ្ឋកិច្ចសង្គម។

ព្រះរាជាណាចក្រកម្ពុជា មានប្រព័ន្ធធារាសាស្ត្រប្រហែល ២,៣៥២ប្រព័ន្ធ (ប្រព័ន្ធពេញលេញមាន ៧៤ប្រព័ន្ធ) ចែកចេញជា ៣ខ្នាត គឺប្រព័ន្ធខ្នាតតូច (តូចជាង ២០០ហ.ត) ខ្នាតមធ្យម (ពី ២០០-៥,០០០ហ.ត) និងខ្នាតធំ (ធំជាង ៥,០០០ហ.ត)។ រហូតពេលនេះ ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងធ្វើការរៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ.) ក្នុងក្របខ័ណ្ឌទូទាំងប្រទេស បានប្រមាណជា ៥៨៤ ស.ក.ប.ទ. ក្នុងនោះមានតែ ១៨៥ ស.ក.ប.ទ. ដែលបាន និងកំពុងទទួលឋវិកាសម្រាប់ប្រតិបត្តិការការងារបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស.ក.ប.ទ. និងការងារប្រតិបត្តិការ និងថែទាំប្រព័ន្ធ (FWUCs, O&M)។ ការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹក និងប្រជាពលរដ្ឋគ្រប់កម្រិត គឺជាផ្នែកមួយដ៏សំខាន់ដើម្បីជម្រុញឱ្យរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយងាកមកចាប់អារម្មណ៍ និងជួយលើផ្នែកមួយនេះ។

នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ដែលជាអង្គភាពជំនាញក្រោមចំណុះអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និងឧតុនិយម បានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៨ បាន និងកំពុងអនុវត្តយ៉ាងសកម្មនូវសោរាចរលេខ ០១ សរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការអនុវត្តគោលនយោបាយ និរន្តរភាព នៃប្រព័ន្ធធារាសាស្ត្រ និងអនុក្រឹត្យលេខ ០៣១ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ចរបស់សហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីរៀបចំបង្កើតឱ្យមាន ស.ក.ប.ទ. ស្របទៅតាមមុខងារ និងភារៈកិច្ចរបស់ខ្លួន។ ក្នុងឆ្នាំ២០២៥នេះ នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក បានអនុវត្តនូវសកម្មភាពការងារនៅទូទាំង ២៥រាជធានី-ខេត្ត លើការងារដូចខាងក្រោម

### ក. ការងាររៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

ក្នុងឆ្នាំ២០២៥នេះ នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក បានធ្វើការបង្កើត ស.ក.ប.ទ. បន្ថែមចំនួន ៧កន្លែង ក្នុងខេត្តចំនួន ៤ ដូចតារាងខាងក្រោម៖

| ឈ្មោះខេត្ត | ចំនួន ស.ក.ប.ទ. | ផ្ទៃដីស្រោចស្រព | | សរុប (ហ.ត) | ចំនួនគ្រួសារ | ឈ្មោះ ស.ក.ប.ទ. |
|---|---|---|---|---|---|---|
| | | ប្រាំង (ហ.ត) | វស្សា (ហ.ត) | | | |
| ពោធិ៍សាត់ | ១ | ៥០០ | ៦,០០០ | ៦,០០០ | ៧,៥៥៣ | បំណក់ |
| កំពង់ធំ | ២ | ២,៥០០ | ៣,៥០០ | ៣,៥០០ | | ៣០កញ្ញា |
| | | ២,៥០០ | ៥៥០ | ២,៥០០ | ៤,២៨០ | កងមាស |
| កំពង់ស្ពឺ | ២ | ៣៥០ | ៨៦៩ | ៨៦៩ | ១,២១៨ | សំរោងបាក់ |
| | | ១,៥៣០ | ៣,១៥៧ | ៣,១៥៧ | ៥,៦១៦ | រលាំងជ្រៃត្បូង |
| កំពង់ឆ្នាំង | ២ | ៧៥០ | ៥០០ | ៧៥០ | ៣៣០ | គោកបន្ទាយ |
| | | ៧៨៧ | ០ | ៧៨៧ | ៤១៧ | បត់ត្រង់ |
| សរុប | ៧ | ៨,៩១៧ | ១៤,៥៧៦ | ១៧,៥៦៣ | ១៩,៤១៤ | |

*តារាងទី ១៨: បង្ហាញពីចំនួនសហគមន៍កសិករប្រើប្រាស់ទឹកដែលបានបង្កើត*

### ខ. ការងារពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក

នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក បានចុះធ្វើការត្រួតពិនិត្យ និងគាំទ្របច្ចេកទេសសម្រាប់ ស.ក.ប.ទ. ចំនួន ១៨៥ កន្លែង តាមបណ្តា ២៥ រាជធានី-ខេត្ត ដោយសម្រេចលទ្ធផលបាន ១០០% ដូចខាងក្រោម៖

| | ចំនួន ស.ក.ប.ទ | ផ្ទៃដីដំណាំស្រូវ | | សរុប (ហ.ត) | ចំនួនគ្រួសារ |
|---|---|---|---|---|---|
| | | ប្រាំង (ហ.ត) | វស្សា (ហ.ត) | | |
| សរុប | ១៨៥ | ១១៧,៣០៦ | ៤៤០,៩៦៨ | ៤៦៩,៨៦០ | ៣៥៣,២១៥ |

*តារាងទី ១៩: តារាងបង្ហាញពីចំនួនសរុបផ្ទៃដីដំណាំស្រូវ និងអ្នកទទួលផល*




*ក្រាហ្វិកទី ២០: ក្រាហ្វិកបង្ហាញពីផ្ទៃដីដំណាំស្រូវសរុប និងអ្នកទទួលផល តាមបណ្តាខេត្តនីមួយៗ*




*ក្រាហ្វិកទី ២១: ក្រាហ្វិកបង្ហាញពីចំនួនសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមបណ្តារាជធានី-ខេត្តទាំង២៥*

## គ. ការងារប្រមូលទិន្នន័យសម្រាប់អនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន

នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក បានសហការជាមួយក្រុមហ៊ុនឯកជន ដៃគូអភិវឌ្ឍន៍ ចុះប្រមូលទិន្នន័យព័ត៌មានសម្រាប់អនុវត្តការងារគម្រោងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន នៅសហគមន៍កសិករប្រើប្រាស់ទឹកចំនួចន ៣កន្លែង ក្នុងខេត្តចំនួន៣ គឺ ស.ក.ប.ទ. ទំនប់រលួស ស្ថិតក្នុងខេត្តកំពង់ធំ ស.ក.ប.ទ. អូរជ្រៃ ស្ថិតក្នុងខេត្តកំពង់ចាម និងស.ក.ប.ទ. ធម្មវិន័យ ស្ថិតក្នុងខេត្តតាកែវ។





រូបភាពទី ៥០: សកម្មភាពប្រជុំផ្សព្វផ្សាយដល់ ស.ក.ប.ទ. (កម្មវិធី បិទ បើក បែងចែកទឹក និងទទួលទឹក ទៅតាមកាលវិភាគ/វេន)





រូបភាពទី ៥១: ប្រជុំផ្សព្វផ្សាយដល់ ស.ក.ប.ទ. ដើម្បីពិនិត្យមើលសកម្មភាពប្រចាំខែ ប្រចាំរដូវ និងប្រចាំឆ្នាំ









រូបភាពទី ៥២: ការបង្កើត ស.ក.ប.ទ. និងការជ្រើសរើសគណៈកម្មាធិការ ស.ក.ប.ទ.





*រូបភាពទី ៥៣: បច្ចេកទេសនៃការថែទាំ ការស្តារកែលម្អ និងសំណង់សិល្បការតូចៗ តាមប្រឡាយរងតូចៗ*

### ៤.២.៦. ការងារគ្រប់គ្រង និងអភិរក្សធនធានទឹក

ក្នុងរយៈពេល ០១ឆ្នាំកន្លងមកនេះ នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក បានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អប្រសើរ ស្របតាមផែនការ និងទិសដៅដែលថ្នាក់ដឹកនាំបានកំណត់ ដោយផ្តោតលើការគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ធនធានទឹកឱ្យមានប្រសិទ្ធភាព និងចីរភាព។ នាយកដ្ឋានបានអនុវត្តសកម្មភាពសំខាន់ៗរួមមាន ការប្រមូល និងវិភាគទិន្នន័យពាក់ព័ន្ធនឹងធនធានទឹក ការរៀបចំ និងធ្វើបច្ចុប្បន្នភាពព័ត៌មានអាងទន្លេ ការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំទាំងក្នុង និងក្រៅក្រសួង ក៏ដូចជាបេសកកម្មក្រៅប្រទេស ព្រមទាំងការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍។

ជាមួយគ្នានេះ នាយកដ្ឋានក៏បានអនុវត្តការងារផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយជាតិលើវិស័យធនធានទឹក ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ។ បន្ថែមពីនេះ បានព្រាង និងអនុវត្តលិខិតបទដ្ឋានពាក់ព័ន្ធនឹងការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ទឹក ស្របតាមមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជា។ ព្រមទាំងបានចុះត្រួតពិនិត្យ និងតាមដានសកម្មភាពប្រើប្រាស់ទឹក និងការរំលោភយកដីចំណីអាងនៅតាមបណ្តារាជធានីខេត្ត។

#### ក. ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន ២លើក ក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ
- បានចូលរួមរៀបចំដាក់តាំងពិព័រណ៍ និងផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសមិទ្ធផលរបស់ក្រសួងធនធានទឹក និងឧតុនិយម ចំនួន ៤លើក។

ការផ្សព្វផ្សាយច្បាប់នេះ អនុវត្តឡើងដើម្បីបង្កើនការយល់ដឹង និងការអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ដល់ស្ថាប័នពាក់ព័ន្ធ និងសាធារណជន។





*រូបភាពទី ៥៤: សកម្មភាពផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា*





*រូបភាពទី ៥៥: សកម្មភាពដាក់តាំងពិព័រណ៍ និងសមិទ្ធផលការងាររបស់ក្រសួងធនធានទឹក និងឧតុនិយម*

## ខ. ការចុះសិក្សា និងផ្តល់យោបល់លើលិខិតស្នើសុំប្រើប្រាស់ទឹក

ការចុះសិក្សា ពិនិត្យ និងផ្តល់យោបល់នេះ ត្រូវបានអនុវត្តឡើងដើម្បីវាយតម្លៃស្ថានភាពប្រើប្រាស់ទឹកជាក់ស្តែងនៅតាមទីតាំងស្នើសុំ ស្របតាមបទដ្ឋានគតិយុត្ត និងគោលការណ៍គ្រប់គ្រងធនធានទឹក។ ការងារនេះ មានគោលបំណងធានាឱ្យការប្រើប្រាស់ទឹកប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព មិនប៉ះពាល់ដល់ធនធានទឹក និងគោរពតាមច្បាប់ជាធរមាន មុនពេលចេញលិខិតអនុញ្ញាតប្រើប្រាស់ទឹក។




*ក្រាហ្វិកទី ២២: ក្រាហ្វិកបង្ហាញពីទីតាំងស្នើសុំប្រើប្រាស់ទឹកនៅ ១២រាជធានី-ខេត្ត ស្មើនឹង ៣៣ទីតាំង*





*រូបភាពទី ៥៦: រូបភាពសកម្មភាពចុះពិនិត្យទីតាំងស្នើសុំប្រើប្រាស់ទឹក*

### គ. ការចុះពិនិត្យ វាយតម្លៃ និងចុះអន្តរាគមន៍ដល់ទីតាំងលើការទន្ទ្រានយកដីអាងស្តុកទឹក និងចំណីផ្លូវទឹក

ការចុះពិនិត្យ វាយតម្លៃ និងចុះអន្តរាគមន៍នេះ ត្រូវបានអនុវត្តឡើងដើម្បីពិនិត្យស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ និងការកាន់កាប់ដីអាងទឹក និងចំណីផ្លូវទឹក ស្របតាមបទដ្ឋានគតិយុត្ត និងគោលការណ៍គ្រប់គ្រងធនធានទឹក។ ការងារនេះ មានគោលបំណងទប់ស្កាត់ និងដោះស្រាយបញ្ហាការទន្ទ្រានយកដីអាងទឹក ការប៉ះពាល់ដល់សំណង់ធារាសាស្ត្រ និងប្រយោជន៍សាធារណៈ។ ជាមួយគ្នានេះ ការចុះអន្តរាគមន៍ក៏ជាការគាំទ្រដល់ការសម្របសម្រួល និងដោះស្រាយបញ្ហារវាងស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ ឱ្យប្រព្រឹត្តទៅដោយសន្តិវិធី និងស្របច្បាប់។ នាយកដ្ឋានបានចុះអន្តរាគមន៍ដល់ទីតាំងលើការទន្ទ្រានយកដីអាងស្តុកទឹក និងចំណីផ្លូវទឹក បាន ៤កន្លែង។




*រូបភាពទី ៥៧: រូបភាពអំពីការចុះអន្តរាគមន៍ដល់ទីតាំងទន្ទ្រានយកដីអាងស្តុកទឹក និងចំណីផ្លូវទឹក*

### ឃ ការចុះសិក្សា វាយតម្លៃ និងផ្តលយោលបល់លើសំណង់ការងារទឹក

នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក បានចុះពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើសំណង់ការងារទឹក ៣ កន្លែង។ ការចុះសិក្សា វាយតម្លៃ និងផ្តល់យោបល់នេះ អនុវត្តឡើងដើម្បីពិនិត្យសំណង់ការងារទឹក និងផ្តល់អនុសាសន៍បច្ចេកទេស ស្របតាមបទដ្ឋាន និងគោលការណ៍គ្រប់គ្រងធនធានទឹក។




*រូបភាពទី ៥៨: រូបភាពសកម្មភាពចុះពិនិត្យ វាយតម្លៃ ផ្តល់យោបល់លើការងារសោងសង់ទំនប់ និងស្តារអាងទឹក*

### ង. ការចុះសិក្សា និងប្រមូលទិន្នន័យ ក្នុងការរៀបចំកម្រងព័ត៌មានអាងទន្លេ

បានប្រមូលព័ត៌មាន និងទិន្នន័យ ដើម្បីរៀបចំកម្រងព័ត៌មានអាងទន្លចំនួន ២ អាងទន្លេគឺ អាងព្រែកទេវ និងអាងព្រែកផ្លូង។ ក្រសួងក៏បាន និងកំពុងខិតខំពង្រឹងការងារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាឱ្យបាននូវការគ្រប់គ្រង អភិវឌ្ឍន៍ អភិរក្សធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាព និងបរិយាបន្នសំដៅធានាឱ្យបាននូវសន្តិសុខទឹកសម្រាប់ប្រជាជនកម្ពុជា។ ក្រសួង បានរៀបចំសៀវភៅ/ឯកសារណែនាំបច្ចេកទេសផ្សេងៗ សរុបមានចំនួន ០៩ សៀវភៅ/ឯកសារ (សៀវភៅលក្ខណៈទូទៅ និងជលសាស្ត្ររបស់អាងទន្លេ និងស្ទឹងធំៗនៅប្រទេសកម្ពុជា ចំនួន ១ ក្បាល, សៀវភៅគោល ការណ៍ណែនាំបច្ចេកទេសវិធីសាស្ត្រការពារច្រាំងស្ទឹង ទន្លេ ចំនួន ១ ក្បាល, សៀវភៅកំណត់ចំណាំ បច្ចេកទេសស្តីពីប្រតិបត្តិការទំនប់អាងទឹក (ទំនប់អាងទឹក សេកសក រក្សា និងតាសាល) ចំនួន ៣ ក្បាល, សៀវភៅ

ទិដ្ឋភាពទូទៅ និងកំណត់ចំណាំអាងទឹកធំៗក្នុងប្រទេសកម្ពុជា ចំនួន ១ ក្បាល និងឯកសារប្រកាសសម្រាប់កិច្ចដំណើរការ និងគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹក ចំនួន ៣ ក្បាល)។

### ៤.២.៧. ការងារទឹកស្អាត និងអនាម័យ

ការងារទឹកស្អាត និងអនាម័យ គឺជាផ្នែកមួយសំខាន់ក្នុងការធានានូវសុខភាពសាធារណៈ និងជីវភាពប្រសើររបស់ប្រជាជនតាមរយៈការពិនិត្យ តាមដានគុណភាពទឹក និងអនាម័យ។ ក្រសួងធនធានទឹក និងឧតុនិយម បានព្យាយាមអនុវត្តគម្រោងផ្សេងៗដើម្បីធានានូវការផ្តល់ប្រភពទឹកស្អាត និងមានអនាម័យដល់ប្រជាជន ទាំងក្នុងតំបន់ជនបទ និងទីក្រុង។ សកម្មភាពសំខាន់រួមមានការស្រាវជ្រាវគុណភាពទឹក ការផ្សព្វផ្សាយចំណេះដឹងអំពីអនាម័យ និងវិធានការទប់ស្កាត់ការប៉ះពាល់នៃការប្រើទឹកកខ្វក់ ការសហការជាមួយសហគមន៍ ក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធអនាម័យ។ ការងារនេះមិនត្រឹមតែរួមចំណែកដល់ការធានាសុខភាពសាធារណៈប៉ុណ្ណោះទេ តែវានៅជាសិទ្ធិមូលដ្ឋានមួយសម្រាប់មនុស្សគ្រប់គ្នា។

#### ក. ការរៀបចំក្របខណ្ឌឯកសារគ្រប់គ្រងទឹកក្រោមដី

នាយកដ្ឋានបានរៀបចំសិក្ខាសាលា និងកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ និងអន្តរក្រសួង ចំនួន ២លើក ដើម្បីពិភាក្សាពិគ្រោះយោបល់ផ្តល់ធាតុចូល និងសិក្ខាសាលាបញ្ចប់ក្នុងការរៀបចំឯកសារព្រាងក្របខណ្ឌគ្រប់គ្រងទឹកក្រោមដីនៅកម្ពុជា ដែលជាឯកសារជាតិសម្រាប់កំណត់បង្ហាញ និងជាត្រីវិស័យសម្រាប់ការគ្រប់គ្រងទឹកក្រោមដីនៅកម្ពុជា។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីស្ថាប័នជាតិពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា គណៈកម្មាធិកាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងរ៉ែ និងថាមពល គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ ឯកសារព្រាងក្របខណ្ឌទឹកក្រោមដីនេះគ្រោងនឹងរៀបចំបោះពុម្ពនៅចុងឆ្នាំ២០២៦។












*រូបភាពទី ៥៩: រូបភាពសកម្មភាពសិក្ខាសាលាពាក់ព័ន្ធការងារធនធានទឹកក្រោមដី*




*រូបភាពទី ៦០: រូបភាពសកម្មភាពវគ្គបណ្តុះបណ្តាលពាក់ព័ន្ធការងារធនធានទឹកក្រោមដី*

## ខ. ការងារសិក្សា និងតាមដានទឹកក្រោមដី

ក្រោមក្របខណ្ឌថវិកាជាតិ ឆ្នាំ២០២៥ នាយកដ្ឋានបានកសាងអណ្តូងត្រួតពិនិត្យ និងតាមដានទឹកក្រោមដីបាន ០១ កន្លែងបន្ថែមទៀត នៅក្នុងខេត្តកំពង់ធំ។ សម្រាប់ការត្រួតពិនិត្យ និងតាមដានទឹកក្រោមដី។ នាយកដ្ឋានបានចុះប្រមូល និងកត់ត្រាទិន្នន័យ ព័ត៌មានកម្រិតកម្ពស់ទឹកក្រោមដីជាប្រចាំខែចំនួន ៣៩ អណ្តូង ដែលក្នុងនោះ ២២ អណ្តូង ស្ថិតក្នុងខេត្តព្រៃវែង ១២ អណ្តូង ស្ថិតក្នុងខេត្តស្វាយរៀង និង ៥អណ្តូង ស្ថិតក្នុងខេត្តកំពង់ស្ពឺ ។

តាមការប្រមូលទិន្នន័យ និងការសិក្សាបានកំណត់ជាលទ្ធផលបញ្ជាក់ថា ស្ថានភាពទឹកក្រោមដីនៅខេត្តទាំងបីខាងលើមានការថយចុះកម្រិតកំពស់ទឹកក្រោមដីជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃការប្រើប្រាស់ទឹកក្រោមដី។




*រូបភាពទី ៦១: សកម្មភាពការកសាងអណ្តូង*





*រូបភាពទី ៦២: សកម្មភាពចុះប្រមូល និងកត់ត្រាទិន្នន័យនីវ៉ូទឹកក្រោមដី*




| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| k1 | 6.07 | 6.04 | 6.04 | 6.40 | 6.44 | 6.02 | 6.1 | 6.73 | 5.90 | 5.62 | 5.5 | 5.58 |
| k2 | 5.40 | 5.48 | 5.40 | 5.28 | 3.37 | 5.06 | 3.64 | 5.16 | 5.40 | 4.96 | 5.05 | 5.00 |
| k3 | 6.50 | 5.42 | 6.70 | 6.80 | 7.18 | 6.90 | 7.2 | 7.00 | 6.79 | 6.84 | 6.71 | 6.96 |
| k4 | 3.88 | 4.00 | 4.00 | 4.04 | 3.11 | 3.43 | 6.12 | 4.70 | 4.72 | 4.22 | 5.52 | 4.11 |
| k5 | 5.40 | 5.48 | 5.40 | 5.28 | 6.40 | 5.82 | 5.9 | 5.92 | 6.80 | 6.94 | 6.98 | 5.92 |

*ក្រាហ្វិកទី ២៣: ក្រាហ្វិកនីវ៉ូទឹកក្រោមដី តាមអណ្តូងនីមួយៗ នៅខេត្តកំពង់ស្ពឺ*




| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| S1 | 6.87 | 5.91 | 7.75 | 7.80 | 7.86 | 7.75 | 7.53 | 7.15 | 6.93 | 6.58 | 6.15 | 6.50 |
| S2 | 8.10 | 8.59 | 8.17 | 8.21 | 8.35 | 8.82 | 8.75 | 8.28 | 8.05 | 7.85 | 7.38 | 7.65 |
| S4 | 6.05 | 6.12 | 6.45 | 6.52 | 6.60 | 6.38 | 6.3 | 6.20 | 6.10 | 5.9 | 5.66 | 5.80 |
| S6 | 7.60 | 8.45 | 8.43 | 8.33 | 7.98 | 7.86 | 7.47 | 7.12 | 6.98 | 6.62 | 6.23 | 6.52 |
| S10 | 5.55 | 6.10 | 6.98 | 7.16 | 6.94 | 6.45 | 6.12 | 5.88 | 5.46 | 5.05 | 4.65 | 4.80 |
| S13 | 5.35 | 6.31 | 6.50 | 6.25 | 6.13 | 6.00 | 5.9 | 5.14 | 4.95 | 4.5 | 4.33 | 4.67 |
| S17 | 6.16 | 7.54 | 7.83 | 7.54 | 7.25 | 6.97 | 6.7 | 6.51 | 6.14 | 6.1 | 6.26 | 6.16 |
| S18 | 9.20 | 9.51 | 8.95 | 8.75 | 8.47 | 7.95 | 7.55 | 7.23 | 7.14 | 7.25 | 7.35 | 7.72 |
| S20 | 6.44 | 6.60 | 6.96 | 7.06 | 7.35 | 7.15 | 7.22 | 7.02 | 6.85 | 6.47 | 6.25 | 6.15 |
| S21 | 5.97 | 6.18 | 7.65 | 7.29 | 7.10 | 6.93 | 6.86 | 6.45 | 6.20 | 5.94 | 5.5 | 5.69 |

*ក្រាហ្វិកទី ២៤: ក្រាហ្វិកនីវ៉ូទឹកក្រោមដី តាមអណ្តូងនីមួយៗ នៅខេត្តស្វាយរៀង*




| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| P1 | 12.92 | 13.00 | 13.15 | 12.82 | 12.97 | 12.65 | 12.48 | 12.62 | 12.35 | 11.35 | 11.02 | 11.12 |
| P3 | 17.22 | 17.41 | 17.45 | 16.89 | 13.65 | 16.18 | 15.93 | 15.87 | 15.77 | 15.21 | 15.01 | 15.07 |
| P4 | 10.95 | 11.10 | 11.07 | 10.92 | 11.19 | 11.31 | 11.34 | 11.33 | 10.95 | 11.39 | 11.36 | 11.34 |
| P5 | 14.90 | 15.25 | 14.73 | 13.98 | 13.74 | 13.25 | 13.21 | 13.09 | 12.98 | 12.70 | 12.25 | 12.53 |
| P6 | 4.39 | 8.97 | 7.87 | 8.09 | 7.91 | 8.12 | 7.31 | 8.08 | 8.00 | 6.17 | 5.70 | 6.23 |
| P7 | 10.92 | 12.19 | 8.48 | 7.26 | 7.11 | 6.90 | 5.44 | 6.29 | 5.45 | 3.23 | 3.16 | 3.59 |
| P8 | 5.29 | 7.87 | 6.75 | 5.25 | 5.01 | 6.78 | 4.30 | 3.95 | 3.65 | 2.10 | 1.85 | 2.65 |
| P9 | 2.73 | 3.57 | 3.60 | 3.17 | 4.30 | 4.19 | 2.01 | 1.71 | 1.46 | 0.85 | 0.78 | 1.59 |
| P10 | 10.05 | 9.88 | 9.82 | 9.75 | 9.14 | 9.23 | 8.84 | 8.83 | 8.85 | 7.81 | 7.41 | 7.43 |
| P14 | 10.67 | 11.11 | 12.00 | 11.82 | 11.76 | 11.65 | 11.50 | 11.44 | 11.05 | 10.40 | 9.95 | 7.97 |
| P15 | 11.93 | 12.60 | 12.00 | 11.60 | 11.87 | 11.71 | 13.60 | 13.44 | 13.37 | 11.00 | 10.45 | 10.25 |
| P21 | 8.30 | 8.77 | 8.79 | 8.75 | 8.86 | 8.36 | 8.30 | 8.15 | 8.10 | 8.80 | 8.77 | 8.55 |
| P22 | 10.43 | 10.55 | 10.33 | 10.47 | 10.31 | 10.13 | 10.05 | 10.17 | 10.10 | 9.70 | 9.57 | 9.73 |
| P23 | 10.04 | 10.17 | 10.13 | 10.11 | 10.00 | 9.77 | 9.63 | 9.60 | 9.54 | 9.28 | 8.80 | 9.03 |
| P24 | 8.10 | 8.38 | 8.54 | 8.57 | 8.48 | 8.46 | 8.30 | 8.20 | 8.10 | 7.92 | 7.62 | 7.64 |
| P26 | 10.17 | 10.30 | 10.57 | 10.50 | 10.42 | 10.07 | 9.96 | 9.87 | 9.75 | 9.47 | 9.40 | 9.48 |
| P32 | 7.70 | 7.97 | 8.83 | 8.80 | 9.07 | 8.50 | 8.42 | 8.48 | 8.30 | 6.62 | 6.48 | 6.64 |
| P33 | 9.76 | 10.23 | 10.18 | 9.86 | 10.19 | 10.05 | 10.03 | 9.75 | 9.60 | 9.38 | 8.57 | 9.06 |

*ក្រាហ្វិកទី ២៥: ក្រាហ្វិកនីវ៉ូទឹកក្រោមដី តាមអណ្តូងនីមួយៗ នៅខេត្តព្រៃវែង*




| | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|
| P3(2022) | 12.92 | 13.96 | 13.35 | 13.12 | 12.88 | 12.55 | 13.10 | 12.65 | 12.54 | 12.31 | 12.40 | 12.67 |
| P3(2023) | 13.23 | 13.69 | 13.47 | 13.38 | 13.68 | 13.73 | 13.77 | 12.56 | 13.26 | 12.25 | 12.53 | 13.08 |
| P3(2024) | 14.86 | 15.41 | 15.87 | 15.95 | 13.84 | 16.56 | 16.22 | 16.16 | 16.03 | 15.35 | 14.97 | 14.62 |
| P3(2025) | 17.22 | 17.41 | 17.45 | 16.89 | 13.65 | 16.18 | 15.93 | 15.87 | 15.77 | 15.21 | 15.01 | 15.07 |

*ក្រាហ្វិកទី ២៦: ក្រាហ្វិកបម្រែបម្រួលនីវ៉ូទឹកក្រោមដី នៅភូមិស្វាយអន្ទរ នៅខេត្តព្រៃវែង*

### គ. ការងារសហប្រតិបត្តិការ

ក្នុងក្របខណ្ឌជាតិ នាយកដ្ឋានបានសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ មន្ទីរធនធានទឹក និងឧតុនិយម និងស្ថាប័នជាតិផ្សេងៗទៀតក្នុងការផ្តល់ព័ត៌មាន និងធាតុចូលពាក់ព័ន្ធទឹកក្រោមដី តាមរយៈសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ។ នាយកដ្ឋានបានបន្តទំនាក់ទំនង និងសហការជាមួយអង្គការ និងដៃគូអភិវឌ្ឍន៍នានាក្នុងការគាំទ្រការកសាងសមត្ថភាពមន្ត្រីរាជការរបស់នាយកដ្ឋាន និងស្ថាប័ន។

## ៤.៣. ការរួមចំណែករបស់យេនឌ័រក្នុងការអភិវឌ្ឍ និងគ្រប់គ្រងវិស័យធនធានទឹក

វិស័យយេនឌ័របានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍ ការគ្រប់គ្រង និងការអភិរក្សធនធានទឹក ដើម្បីធានាបានសមភាពនៃការចូលរួមចំណែករបស់ស្ត្រីនៅក្នុងដំណើរការបែងចែក និងការប្រើប្រាស់ទឹកសំដៅកែលម្អស្ថានភាពសេដ្ឋកិច្ច និងការរស់នៅរបស់ស្ត្រី និងកុមារ។

ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រតាមប្រព័ន្ធការងារក្នុងវិស័យធនធានទឹក នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៧-២០១០ ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការរបស់ក្រសួង-ស្ថាប័ននោះ ក្រសួងធនធានទឹក និងឧតុនិយម បានចេញសេចក្តីសម្រេចបង្កើត និងកែសម្រួលក្រុមការងារបច្ចេកទេសយេនឌ័រ (GMAG) ប្រចាំក្រសួងបន្តបន្ទាប់ ៩លើក ដោយមានសមាសភាពក្រុមការងារយេនឌ័រគ្រប់ទាំង ១២អង្គភាព ក្រោមឱវាទក្រសួង និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា, អាជ្ញាធរទន្លេសាប ព្រមទាំងមន្ត្រីបង្គោលទាំង ២៥មន្ទីរធនធានទឹក និងឧតុនិយម រាជធានី ខេត្ត ចំណុះក្រសួង។







*ក្រាហ្វិកទី ២៧: ដាដ្យាក្រាមសមាសភាពក្រុមការងារ, យន្តការបញ្ជ្រាបយេនឌ័រ និងទំនាក់ទំនងការងារយេនឌ័រទៅនឹងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ*

ក្រសួងធនធានទឹក និងឧតុនិយម បន្តផ្តល់ការគាំទ្រ និងអនុវត្តសកម្មភាពដើម្បីឆ្លើយតបនឹង SDG ឆ្នាំ២០៣០ គោលដៅទី៥៖ ៥.៥ សម្រេចឱ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប និងដើម្បីចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ដែលរាជរដ្ឋាភិបាលបន្តផ្តល់សារៈសំខាន់លើការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចរបស់ស្ត្រី ដែលរាជរដ្ឋាភិបាលបានចាត់ទុកថា **"ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ"** ក៏ដូចជាគោលដៅទី៦៖ ៦.៥ **ធានាឱ្យមានទឹក និងអនាម័យ និងការគ្រប់គ្រងទឹក និងអនាម័យ ប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប។**

យោងតាមច្បាប់គ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ជំពូកទី១ មាត្រា៤ ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍដោយផ្អែកទៅលើ វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដែលក្នុងនោះគោលការណ៍

ណែនាំនៃការគ្រប់គ្រងទឹក ទី៣៖ ស្រីដើរតួនាទីកណ្តាលក្នុងការផ្គត់ផ្គង់ ចាត់ចែង និងការពារដល់ទឹក។ តួនាទីស្នូលដ៏សំខាន់បំផុតរបស់ស្ត្រី ដែលជាអ្នកផ្គត់ផ្គង់ និងប្រើប្រាស់ទឹក ថែមទាំងជាអ្នកការពារដល់បរិស្ថានមានជីវិតផងនោះ ត្រូវបានគេលើកយកមកឆ្លុះបញ្ចាំងដោយកម្រនៅក្នុងការរៀបចំស្ថាប័នសម្រាប់ការអភិវឌ្ឍ និងចាត់ចែងប្រភពធនធានទឹក។ នៅក្នុង SDG ឆ្នាំ ២០៣០ គោលដៅទី៧៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន និងលើកកម្ពស់នវានុវត្តន៍ នោះក្រុមការងារយេនឌ័រក្រសួង ក៏បានធ្វើបច្ចុប្បន្នភាពការបញ្ជ្រាបយេនឌ័រក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹកសម្រាប់ឆ្នាំ ២០១៩-២០២៣។ នាពេលបច្ចុប្បន្ននេះ ក្រសួងធនធានទឹក និងឧតុនិយម កំពុងស្វែងរកការជួយគាំទ្រពីសំណាក់ដៃគូរអភិវឌ្ឍន៍ដើម្បីធ្វើបច្ចុប្បន្នភាពការបញ្ជ្រាបសកម្មភាពយេនឌ័រនៅក្នុងវិស័យធនធានទឹកសម្រាប់ឆ្នាំ២០២៥-២០២៩។

ក្នុងការអនុវត្តប្រព័ន្ធការងារបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យធនធានទឹក និងឧតុនិយម ដែលបានរៀបចំ និងកំពុងអនុវត្តបានឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រក្រសួងធនធានទឹក និងឧតុនិយម ដោយបានបញ្ជ្រាបនៅគ្រប់សសរស្តម្ភក្នុងផែនការយុទ្ធសាស្ត្រក្រសួង នឹងឆ្លើយតបទៅយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ នីតិកាលទី៧ នៃរដ្ឋសភា ក្នុងបញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ក្នុងមុំទី១៖ ការធ្វើបរមភាវូបនីយកម្មជលលាភ ប្រជាសាស្ត្រ ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ និងដើម្បីឆ្លើយតបនឹងគោលនយោបាយក្នុងវិស័យធនធានទឹក នោះក្រុមការងារយេនឌ័របានអនុវត្ត GMSP ក្នុងវិស័យធនធានទឹកឆ្នាំ ២០១៩-២០២៣ មានយុទ្ធសាស្ត្រ៥ ៖








❖ **វឌ្ឍនភាពឆ្នាំ២០២៥**

- បាននឹងកំពុងបន្តផ្សព្វផ្សាយការយល់ដឹងអំពីអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)
- បានបន្តចុះតាមដានការអនុវត្តច្បាប់ បទបញ្ញត្តិពាក់ព័ន្ធនានា គោលនយោបាយ និងអនុសាសន៍រាជរដ្ឋាភិបាល បានចូលរួមពិធីអបអរសាទរទិវាទឹក និងឧតុនិយមពិភពលោកឆ្នាំ២០២៥ ក្រោមប្រធានបទ"ការការពារផ្ទាំងទឹកកក និងការបិទបញ្ចប់គម្លាតទទួលបានការប្រកាសព័ត៌មានឱ្យដឹងជាមុនរួមគ្នា" នៅទីស្តីការក្រសួង
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ២០២៦ លើការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យធនធានទឹកបញ្ចូលក្នុងផែនការរួមរបស់ក្រសួង
- បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយដៃគូរអភិវឌ្ឍន៍នានា លើការបញ្ជ្រាបយេនឌ័រក្នុងក្របខណ្ឌគម្រោង និងកិច្ចសហប្រតិបត្តិការភាពជាដៃគូរល្អរវាង GMAG
- បានបន្តធ្វើបច្ចុប្បន្នភាពអភិវឌ្ឍនផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យធនធានទឹករយៈពេល៥ឆ្នាំ បានចូលរួមវគ្គបណ្តុះបណ្តាលជាសេរីស្តីពីការវិភាគ និងស្ថិតិយេនឌ័រ ក្នុងក្របខណ្ឌការប្រែប្រួល អាកាសធាតុ បានចូលរួមសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីកម្មវិធីអភិបាលកិច្ចធនធានទឹកដែលធន់នឹងការប្រែប្រួលអាកាសធាតុកម្ពុជា
- រៀបចំផែនការសកម្មភាពយេនឌ័រក្នុងការបញ្ជ្រាបយេនឌ័រលើវិស័យធនធានទឹក ទៅក្នុងក្របខណ្ឌផែនការបច្ចុប្បន្នភាពគោលនយោបាយជាតិការប្រែប្រួលអាកាសធាតុ NDC 3.0 និងបន្តសហការអនុវត្តគោលនយោបាយនារីរតនៈទី៦
- ផ្តល់កិច្ចសម្ភាសន៍មន្ត្រីតំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានៃក្រសួងធនធានទឹក និងឧតុនិយម ស្តីពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ។
- ចូលរួមសិក្ខាសាលាស្តីពីការអនុវត្តវិធានការឆ្លើយតបយេនឌ័រតាមវិស័យក្នុងផែនការជាតិ រួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាជំណាក់កាលទី៣(NDC3.0)
- បានចុះសិក្សាស្រាវជ្រាវ អំពីតួនាទី និងបញ្ហាយេនឌ័រក្នុងវិស័យធនធានទឹក នៅតាមសហគមន៍កសិករប្រើប្រាស់ទឹក បានចំនួន ៥ខេត្ត (ខេត្តកែប ខេត្តកំពត ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តមណ្ឌលគីរី)
- បានរៀបចំរបាយការណ៍វឌ្ឍនភាពការងារយេនឌ័រក្នុងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន៥៧ ចំណុចរបស់គណៈកម្មាធិការ CEDAW របស់អង្គការសហប្រជាជាតិលើរបាយការណ៍លើកទី៦ របស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញា CEDAW ទៅក្រសួងកិច្ចការនារី
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាបន្នសង្គមទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ។
- ចូលរួមសិក្ខាសាលាស្តីពីការផ្ទៀងផ្ទាត់ និងផ្សព្វផ្សាយសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃការងារបញ្ជ្រាបយេនឌ័រលើវិស័យធនធានទឹក និងការបញ្ជ្រាបយេនឌ័រការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានទឹកចម្រុះ សរុបសិក្ខាកាមចូលរួមចំនួន ៦៧រូប
- រៀបចំកិច្ចប្រជុំក្រុមការងារយេនឌ័រស្តីពីរបាយការណ៍បូកសរុបលទ្ធផលការងាររយៈពេល៩ខែ និងប្រចាំឆ្នាំ និងលើកទិសដៅអនុវត្តបន្ត បានចំនួន ២លើក សរុបចំនួន ៨០រូប ។

# ៥. បញ្ហាប្រឈម





## ៥. បញ្ហាប្រឈម

តាមការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០២៦ របស់ខ្លួន ក្រសួងធនធានទឹក និងឧតុនិយមសម្រេចបានលទ្ធផលការងារគួរជាទីកត់សម្គាល់ ដោយឈរលើស្មារតីទទួលខុសត្រូវ និងការបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន។ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ ក្រសួងបានជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដែលតម្រូវឱ្យមានការពុះពារ និងរកដំណោះស្រាយដើម្បីឈានទៅសម្រេចបានលទ្ធផលថ្មីៗថែមទៀត ដូចដែលបានគ្រោងទុកក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យធនធានទឹកឆ្នាំ ២០២៤-២០២៨។ ខាងក្រោមនេះគឺជាបញ្ហាប្រឈមសំខាន់ៗដែលក្រសួងបានជួបប្រទះ

- ចំនួនមន្ត្រីបច្ចេកទេស ដែលត្រូវចូលនិវត្តន៍ក្នុងអាណត្តិនេះ មានច្រើន ដែលធ្វើឱ្យក្រសួង អាចប្រឈមនឹងការខ្វះខាតធនធានមនុស្សដែលមានបទពិសោធន៍និងសមត្ថភាពផ្នែកបច្ចេកទេស ជាពិសេសនៅថ្នាក់ក្រោមជាតិ។
- ការប្រែប្រួលអាកាសធាតុ បានធ្វើអោយកើនឡើងនូវគ្រោះទឹកជំនន់ជាញឹកញាប់ និងធ្ងន់ធ្ងរ ដែលអាចខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធការងារទឹក ប្រព័ន្ធជលសាស្ត្រ និងភាពងាយរងគ្រោះនៃធនធានទឹក។
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ-ព័ត៌មាន ឧតុនិយម ជលសាស្ត្រ និងធនធានទឹក ឧបករណ៍វាយតម្លៃ និងបទដ្ឋានគតិយុត្តិនានានៅមិនទាន់គ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ ដើម្បីជួយគាំទ្រដល់ការធ្វើផែនការ និងការសម្រេចចិត្ត សម្រាប់ជានាការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកប្រកបដោយចីរភាព និងប្រសិទ្ធភាព។
- ការគ្រប់គ្រងធនធានទឹកចម្រុះអន្តរវិស័យ រួមទាំងការគ្រប់គ្រងអាងទន្លេ ពុំទាន់បានអនុវត្តឱ្យបានទូលំទូលាយ និងមានលក្ខណៈស៊ីជម្រៅ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ និងខិតខំបន្ថែមទៀត ដើម្បីពង្រឹងការអនុវត្ត សហការអន្តរស្ថាប័ន និងភាគីពាក់ព័ន្ធ និងសំដៅចូលរួមដោះស្រាយចំពោះការកើនឡើងនៃសម្ពាធលើធនធានទឹក ដែលបណ្តាលមកពីការអភិវឌ្ឍដូចជាៈ កំណើនវិស័យកសិកម្ម នគរូបនីយកម្ម ឧស្សាហូបនីយកម្ម និងការផលិតថាមពល។
- លិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានគ្រប់ជ្រុងជ្រោយ ហើយត្រូវការបង្កើតថ្មី និងធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃសេដ្ឋកិច្ចសង្គម និងអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា។
- ឆ្នាំទំនប់មានចំនួនតិចនៅឡើយ ក្នុងការជួយដល់ការគ្រប់គ្រងធនធានទឹក ជានាមុខងារប្រព័ន្ធធារាសាស្ត្រអោយមានប្រសិទ្ធភាព ដែលមិនស្របតាមកំណើននៃប្រព័ន្ធធារាសាស្ត្រដែលមាននៅទូទាំងប្រទេស និងមិនអាចឆ្លើយតបទៅតាមតម្រូវការរបស់កសិករបាន។
- ផែនការថវិកាកម្មវិធីប្រចាំឆ្នាំសម្រាប់ការងារជួសជុល ថែទាំ និងសម្រាប់កិច្ចដំណើរការលើហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ មិនទាន់ឆ្លើយតបទៅនឹងចំនួនប្រព័ន្ធធារាសាស្ត្រដែលមាន និងបានអភិវឌ្ឍន៍ថ្មីៗនៅទូទាំងប្រទេស។
- ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដែលអាចជួយបង្កើនភាពធន់ទៅនឹងអាកាសធាតុ នៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកនៅមានតិចតួច។
- ការចូលរួមរបស់កសិករ ក្នុងសហគមន៍កសិករប្រើប្រាស់ទឹក លើការងារគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រសំរាប់ការស្រោចស្រព នៅមានកម្រិត ដោយសារការយល់ដឹង សមត្ថភាព និងការលើកទឹកចិត្ត នៅមិនគ្រប់គ្រាន់។

# ៦. សេចក្តីសន្និដ្ឋាន





## ៦. សេចក្តីសន្និដ្ឋាន

ឆ្នាំ ២០២៥ គឺជាឆ្នាំបន្តកំណែទម្រង់រដ្ឋបាលតាមរយៈការវិភាគមុខងារ និងរចនាសម្ព័ន្ធ និងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងថវិកាដែលបាននិងកំពុងជួយតម្រង់ទិស និងពង្រឹងការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួង។ ទន្ទឹមគ្នានឹងលទ្ធផលដែលលេចជារូបរាងបណ្តើរៗ ក្រសួងក៏នៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលត្រូវពុះពារ ដូចជា បញ្ហាធនធានមនុស្ស ឧបករណ៍ សម្ភារៈបរិក្ខារ និងថវិកា នៅមានកម្រិត មិនទាន់ឆ្លើយតបទៅនឹងផែនការប្រចាំឆ្នាំដែលបានលើកឡើង។ ក្រសួងនឹងបន្តជម្រុញ និងពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព តាមគោលការណ៍ សារាចរណែនាំរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ជាផ្នែកដែលមិនអាចខ្វះបាន និងជាត្រីវិស័យសម្រាប់ការតម្រង់ទិសដល់កិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព ចីរភាព និងបរិយាប័ន្ន ក្រសួងធនធានទឹក និងឧតុនិយម បានបន្តពង្រឹងការកសាង និងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងលិខិតបទដ្ឋានគតិយុត្តនានា លើការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅសម្រេចបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងធនធានទឹក ដូចដែលមានចែងនៅក្នុងគោលនយោបាយទឹកឆ្នាំ ២០០៤ និងច្បាប់ទឹកឆ្នាំ ២០០៧។ ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាព ក្រសួងបានបញ្ចប់និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើសេចក្តីប្រកាសស្តីពី "ការបង្កើត និងការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹក និង គោលការណ៍ណែនាំស្តីពីកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ"។ ទន្ទឹមនឹងនេះក្រសួងក៏បាននឹងកំពុងរៀបចំបង្កើត "ឯកសារស្តង់ដាជាតិសម្រាប់ប្រព័ន្ធធារាសាស្ត្រ" ដើម្បីសម្រួលដល់ការសិក្សា ការរៀបចំប្លង់ និងការសាងសង់សម្រាប់គម្រោងអភិវឌ្ឍន៍ធនធានទឹក។

ឆ្លងតាមការអនុវត្តការងារកន្លងមក ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាព លើការកសាង និង ប្រតិបត្តិការប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព តម្រូវឱ្យមានការចូលរួមសហការពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាពិសេសប្រជាពលរដ្ឋ ដែលអាស្រ័យផលក្នុងការថែទាំ និងដំណើរការប្រព័ន្ធធារាសាស្ត្រ និងសំណង់សិល្បការ ដើម្បីធានាបានការបែងចែកទឹកប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន សម្រាប់គ្រប់វិស័យ ក៏ដូចជា សម្រាប់ប្រព័ន្ធអេកូឡូស៊ី។

តាមរយៈការអនុវត្តការងារកន្លងមកជាពិសេសក្នុងឆ្នាំ២០២៥ ក្រសួងបានខិតខំបន្តការកសាង និងការអភិវឌ្ឍរាល់បណ្តាហេដ្ឋារចនាសម្ព័ន្ធទឹកជាពិសេសប្រព័ន្ធធារាសាស្ត្រ និងអាងស្តុកទឹក ដើម្បីរក្សាទឹកទុក និងបង្កើនសន្តិសុខទឹកទូទាំងប្រទេស ជាពិសេសបង្កើនលទ្ធភាពស្រោចស្រព ជាក់ស្តែងក្រសួងធនធានទឹក និងឧតុនិយម បានបង្កើនលទ្ធភាពស្រោចស្រពដល់ដំណាំស្រូវសរុបបានចំនួន ៣៦,៨៧៩ហិកតា ក្នុងនោះ (ស្រូវវស្សាចំនួន ១៧,៧៤០ហិកតា និងស្រូវប្រាំងចំនួន ១៩,១៣៩ហិកតា) ព្រមទាំងស្រោចស្រពដំណាំរួមផ្សំបានចំនួន ៧៧៤ហិកតានិង ចំការ ៥៧៩ហិកតា។ ក្រៅពីបង្កើន ក៏មានការរក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រពលើដំណាំស្រូវសរុបចំនួន ៦៥៩,២៥៩ហិកតា ក្នុងនោះ (ស្រូវរដូវវស្សាចំនួន ៥១២,០៤៣ហិកតា និងស្រូវរដូវប្រាំងចំនួន ១៤៧,២១៦ហិកតា) រក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រពដំណាំរួមផ្សំបានចំនួន ៤,០០៩ហិកតា ព្រម ទាំងបានរក្សានិរន្តរភាពការពារកុំឱ្យទឹកប្រៃហូរចូលផ្ទៃដីស្រូវវស្សាសរុបចំនួន ១៤,៧៨៤ហិកតា ផងដែរ។ ក៏ដូចឆ្នាំមុនៗដែរ ក្រសួងបានបន្តពង្រឹងសេវាកម្មផ្សព្វផ្សាយការព្យាករណ៍កម្ពស់ទឹក និងស្ថានភាពជលសាស្ត្រ តាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេសំខាន់ៗដទៃទៀត ក៏ដូចជាការព្យាករណ៍ធាតុអាកាស ដែលបានជួយកាត់បន្ថយផលប៉ះពាល់គ្រោះធម្មជាតិដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត និងព្យុះភ្លៀង។

កិច្ចសហប្រតិបត្តិការកន្លងមក និងក្នុងឆ្នាំ២០២៥ រវាងក្រសួងធនធានទឹក និងឧតុនិយម ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដែលធ្វើការងារទាក់ទងនឹងវិស័យធនធានទឹកបាននាំមកនូវសមិទ្ធផល គួរឱ្យកត់សម្គាល់ក្នុងការចូលរួមចំណែកធានាសន្តិសុខទឹក និងការផ្គត់ផ្គង់ទឹកឱ្យបានសមរម្យសម្រាប់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម ឧស្សាហកម្ម សិប្បកម្ម ថាមពលអគ្គិសនី នាវាចរណ៍ ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងបំពេញតម្រូវការ នៃការប្រើប្រាស់ប្រចាំថ្ងៃ។ ដើម្បីធ្វើឱ្យសន្តិសុខទឹក និងការផ្គត់ផ្គង់ទឹកកាន់តែប្រសើរឡើង ក៏ដូចជាជំរុញការអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម នឹងបន្តខិតខំ ប្រឹងប្រែង និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគរជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញប្បទាន ដើម្បីជានាថាជំនួយទាំងនោះនឹងឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងអាទិភាពរបស់ក្រសួងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០២៤-២០២៨ របស់ខ្លួន សំដៅរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ មានគម្រោងចំនួន ២ ត្រូវបានបញ្ចប់គឺ គម្រោងប្រព័ន្ធធារាសាស្ត្រស្ទឹងព្រែកត្នោតនិងគ្រប់គ្រងទឹកជំនន់ និងគម្រោងអភិវឌ្ឍន៍ទំនប់ដូនទ្រី និងមានគម្រោងចំនួន ២១ កំពុងត្រូវបានអនុវត្តន៍ ដែលគាំទ្រថវិកា ដោយដៃគូអភិវឌ្ឍន៍។ នៅក្នុងឆ្នាំ២០២៥ ក៏មានគម្រោង ចំនួន ៥ កំពុងត្រូវបានអនុវត្តន៍ ដែលគាំទ្រថវិកាដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានថវិកាសរុបចំនួនប្រមាណ ៥៩៩,៨៥ លានដុល្លារ។

ក្រសួង បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ដល់ការជំរុញគាំទ្រ និងលើកទឹកចិត្តដល់ការចូលរួមចំណែក របស់ស្ត្រីក្នុងសកម្មភាពគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកតាមរយៈការរៀបចំយន្តការសម្រាប់បង្កើនឱកាស ដល់មន្ត្រីរាជការជាស្ត្រីដែលមានសមត្ថភាពនឹងទទួលបាននូវតួនាទីធ្វើសេចក្តីសម្រេចផ្សេងៗ នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីចូលរួមកាត់បន្ថយគម្លាតយេនឌ័រ និងសម្រេចឱ្យបាននូវសមភាពយេនឌ័រនៅក្នុងការអនុវត្តការងារ ដែលរាជរដ្ឋាភិបាលបានចាត់ទុក "ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ"។ ដើម្បីសម្រេចបានគោលដៅនេះ តម្រូវឱ្យមាន ការបន្តលើកទឹកចិត្តពីថ្នាក់ដឹកនាំ ការផ្តល់ឱកាស ប្រកបដោយសមភាព សមធម៌ និងសមទាន ការចូលរួមជំរុញពី ភាគីបុរស និងការបណ្តុះបណ្តាលប្រកបដោយគុណភាព។

ផ្អែកតាមលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០២៥ បានបង្ហាញឱ្យឃើញថា ក្រសួងធនធានទឹក និងឧតុនិយមបានខិតខំអនុវត្តនូវភារកិច្ចរបស់ខ្លួនយ៉ាងសកម្មប្រកបដោយការយកចិត្តទុកដាក់ និងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេសគឺការបង្កើនល្បឿននៃការកែទម្រង់ និងការពង្រឹងអភិបាលកិច្ចដែលជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយក្រសួងបានយកចិត្តទុកដាក់លើការងារអភិបាលកិច្ច ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលជាកម្លាំងចលករក្នុងការជួយជំរុញការអនុវត្តភារកិច្ច និងការលើកកម្ពស់ប្រសិទ្ធភាពការងារ ព្រមទាំងពង្រឹងការអនុវត្តលើការចំណាយឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព និងចំទិសដៅ។

# ៧. ទិសដៅអនុវត្តឆ្នាំ២០២៦





## ៧. ទិសដៅអនុវត្តឆ្នាំ២០២៦

### ៧.១. ការងាររដ្ឋបាល និងធនធានមនុស្ស

- បំពេញបន្ថែម ឧបករណ៍ សម្ភារៈ និងថវិកា សម្រាប់គាំទ្រការអនុវត្តផែនការគ្រប់គ្រងការងាររដ្ឋបាល និងធនធានមនុស្ស ដោយប្រព័ន្ធ Digital ស្របតាមបដិវត្តន៍ឧស្សាហកម្ម ៤.0 ដើម្បីឱ្យស្របតាមការវិវត្តន៍នៃសង្គម និងសកលលោក។
- បន្តពង្រឹងសមត្ថភាពមន្ត្រីលើផ្នែកជំនាញរដ្ឋបាល និងបច្ចេកវិទ្យា ដើម្បីគ្រប់គ្រង និងកិច្ចដំណើរការការងាររដ្ឋបាល ឱ្យបានកាន់តែប្រសើរ និងប្រសិទ្ធភាព។
- ជំរុញការអនុវត្តន៍នូវប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិត្ថកម្មការងារក្នុងវិស័យធនធានទឹក និងឧតុនិយម។
- បន្តអនុវត្តន៍ការងារ៖
  - រៀបចំលើកសំណើដំឡើងថ្នាក់ ឋានន្តរស័ក្តិ តាមវេនជ្រើសរើស អតីតភាពការងារ និងសញ្ញាបត្រជូនមន្ត្រីរាជការ ក្រសួងធនធានទឹក និងឧតុនិយមប្រចាំឆ្នាំ តាមគោលការណ៍ច្បាប់កំណត់
  - រៀបចំលើកសំណើសុំគ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការនៃក្រសួងធនធានទឹក និងឧតុនិយមដែលមានស្នាដៃល្អក្នុងការបំពេញការងារប្រចាំឆ្នាំ។
- រៀបចំកម្មវិធីចែករំលែកចំណេះដឹង បទពិសោធន៍ការងារវិស័យធនធានទឹក និងឧតុនិយម ដល់មន្ត្រីចំណុះក្រសួង តាមប្រព័ន្ធ Digital។
- បន្តយកចិត្តទុកដាក់ និងជំរុញការងារពិនិត្យឡើងវិញ រចនាសម្ព័ន្ធ ការវិភាគមុខងារ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយមជាថ្មីឡើងវិញ ធានាបានការអនុវត្តតួនាទី ភារកិច្ច ឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។
- ក្រោយពីបានធ្វើការរៀបចំត្រួតពិនិត្យឡើងវិញ រចនាសម្ព័ន្ធ និងការវិភាគមុខងាររបស់អង្គភាពបានបញ្ចប់មានតម្រូវការជ្រើសរើសមន្ត្រីបន្ថែម៖
  - មុខតំណែង គុណវុឌ្ឍិនៃមុខតំណែងអង្គភាពមានតម្រូវការ
  - ប្រភេទក្របខ័ណ្ឌមន្ត្រីបច្ចេកទេស/ជំនាញ តាមបណ្តាអង្គភាពដែលមានតម្រូវការ
  - មន្ត្រីជាប់កិច្ចសន្យា ឆ្នាំទំនប់ដោយផ្អែកលើកិច្ចសន្យាកិច្ចព្រមព្រៀងការងារ។

### ៧.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុ

- អនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តថវិកាកម្មវិធី/សមិទ្ធកម្មឆ្នាំ២០២៦។
- គាំទ្រ អាជ្ញាធរទន្លេសាប និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញ។
- អនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម ។
- គ្រោងរៀបចំអង្គភាពដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញទាំង២ (អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស) ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅឆ្នាំបន្តបន្ទាប់។
- ជំរុញនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ។
- គ្រោងបញ្ជូនមន្ត្រីចំនួន ៥ រូប ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៦។
- បន្តគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាការកំណត់ និងតម្រូវការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- គ្រោងនឹងអនុវត្ត FMIS ពេញលេញ ទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៧.៣. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- សហការចូលរួមពិនិត្យឡើងវិញនូវបណ្តាបទដ្ឋានគតិយុត្ត និងគោលនយោបាយជាតិលើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យស្របទៅនឹងតថភាពបច្ចុប្បន្ន
- ចូលរួមសហការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំពង្រាងផែនការយុទ្ធសាស្ត្របញ្ជាបយេនឌ័រក្នុងវិស័យធនធានទឹក និងឧតុនិយមរយៈពេល ៥ឆ្នាំ
- បន្តការរៀបចំបញ្ជីសារពើភ័ណ្ឌស្ថិតិលើវិស័យធនធានទឹក និងឧតុនិយម និងបញ្ចូលក្នុងប្រព័ន្ធព័ត៌មាន នៃប្រព័ន្ធស្រោចស្រពកម្ពុជា(CISIS) ដើម្បីជាព័ត៌មានជាក់លាក់ ច្បាស់លាស់ និងមានប្រសិទ្ធិភាព សម្រាប់កសាងផែនការរយៈពេលខ្លី មធ្យម និងរយៈពេលវែងបញ្ចូលក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ដើម្បីស្វែងរកជំនួញពីដៃគូរអភិវឌ្ឍក្នុងប្រទេស និងក្រៅប្រទេស។
- បន្តចុះប្រមូល និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រព័ន្ធជាវាសាស្ត្រ ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធការពារទឹកប្រៃ ចំនួន ១០០ប្រព័ន្ធ និងស្ថិតិស្ថានីយឧតុនិយម ស្ថិតិស្ថានីយជលសាស្ត្រ និងស្ថិតិសកបទតាមបណ្តា រាជធានី-ខេត្ត និងរៀបចំចងក្រងជារបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ។
- បន្តត្រួតពិនិត្យតាមដាន វាយតម្លៃការអនុវត្តគម្រោងប្រើប្រាស់ថវិកាជាតិ និងថវិកាដៃគូរអភិវឌ្ឍន៍តាម បណ្តារាជធានី-ខេត្ត និងធ្វើបច្ចុប្បន្នភាពទិន្នន័យនៃការអនុវត្តផែនការ
- បន្តចូលរួមសហការក្នុងក្របខ័ណ្ឌកិច្ចសហសប្រតិបត្តិការអន្តរជាតិ និងបណ្តាប្រទេសជាសមាជិកអាស៊ាន
- ចូលរួមបន្តធ្វើកម្មវិធីសហប្រតិបត្តិការក្នុងប្រទេស ក្រៅប្រទេស និងសម្របសម្រួលជំនួយពីបរទេស និងដៃគូអភិវឌ្ឍព្រមទាំងត្រួតពិនិត្យការអនុវត្តន៍លើវិស័យអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម។
- ចូលរួមរៀបចំឯកសារកិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងធនធានទឹក និងឧតុនិយមជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ។

## ៧.៤. ការងារមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម

### ក. សិក្សាវាស់តម្រូវការទឹករបស់ដំណាំស្រូវនៅតាមបណ្តាខេត្ត (Direct Method)

- ធ្វើការដំឡើងឧបករណ៍តម្រូវការទឹករបស់ដំណាំស្រូវវាស់ដោយដៃ នៅខេត្តកំពង់ឆ្នាំងចំនួន ២កន្លែង និងខេត្តបាត់ដំបងចំនួន ១កន្លែង និងបន្តប្រមូលទិន្នន័យតាមបណ្តាខេត្តរួមមាន៖ ខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែង កំពង់ចាម សៀមរាប និងខេត្តបន្ទាយមានជ័យ។

### ខ. ការងារបណ្តុះបណ្តាល

មជ្ឈមណ្ឌលគ្រោងនឹងធ្វើការបណ្តុះបណ្តាលចំនួន ៦ វគ្គ ក្នុងនោះថ្នាក់ជាតិចំនួន ៣វគ្គ និងថ្នាក់ក្រោមជាតិចំនួន ៣វគ្គ រួមមាន៖

- **បណ្តុះបណ្តាលថ្នាក់ជាតិ**

  ១- វគ្គបណ្តុះបណ្តាលស្តីពី ការសិក្សាឋានលេខា ប្រព័ន្ធធារាសាស្ត្រ តាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)

  ២- វគ្គបណ្តុះបណ្តាលស្តីពី ការសិក្សាគ្រោងប្លង់ប្រព័ន្ធធារាសាស្ត្រ

  ៣-វគ្គបណ្តុះបណ្តាលស្តីពី កិច្ចដំណើការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ។

- **បណ្តុះបណ្តាលថ្នាក់ក្រោមជាតិ**

  ស្តីពីការចូលរួមគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រដល់គណកម្មាធិការ ស.ក.ប.ទ.រួមមាន៖

  ១- សហគមន៍លំហាច ខេត្តកំពង់ឆ្នាំង

  ២- សហគមន៍ដំណាក់អំពិល ខេត្តពោធិ៍សាត់

  ៣- សហគមន៍រាមគន់ ខេត្តបាត់ដំបង

### គ. ការសហការជាមួយគម្រោងសហប្រតិបត្តិការ

មជ្ឈមណ្ឌលនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយគម្រោងដែលមានស្រាប់ និងគម្រោងថ្មីៗបន្ថែមទៀត មានដូចខាងក្រោម៖

- បន្តចូលរួម សិក្សាស្រាវជ្រាវពីការកាត់បន្ថយការបំភាយឧស្ម័នមេតាន និងការបង្កើនទិន្នផលស្រូវដោយវិធីសាស្ត្រស្រោចស្រពពន្លិច និងបង្ហោកនៅប្រព័ន្ធធារាសាស្ត្រលំហាច ស្ថិតក្នុងខេត្តកំពង់ឆ្នាំង(គម្រោងសហប្រតិបត្តិការជាមួយ JWA)។
- បន្តចូលរួមជាមន្ត្រីសមភាគី គម្រោងរៀបចំស្តង់ដាជាតិប្រព័ន្ធធារាសាស្ត្រ (ប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹក) ជាគម្រោងកិច្ចសហប្រតិបត្តិការគាំទ្របច្ចេកទេសរបស់ JICA និងដៃគូអភិវឌ្ឍន៍នានាបន្តទៀត ។
- បន្តចូលរួមជាមន្ត្រីសមភាគីគម្រោងស្តារកែលម្អឡើងវិញប្រព័ន្ធស្រោចស្រព និងដោះទឹកភាគនារតី នៃរាជធានីភ្នំពេញ (CP-P14 & CP-P28) ស្ថិតក្នុងខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។
- តាមរយៈគម្រោងកិច្ចសហប្រតិបត្តិការ ពីដៃគូអភិវឌ្ឍន៍នានា ជាពិសេសជាមួយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នឹងស្វែងរកសិក្ខាសាលា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែង នៅក្នុង និងក្រៅប្រទេស ដើម្បីបង្កើនចំណេះដឹង និងចូលរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៧.៥. ការងារធារាសាស្ត្រកសិកម្ម

នាយកដ្ឋានធារាសាស្ត្រកសិកម្ម បានរៀបចំចងក្រង និងត្រួតពិនិត្យសៀវភៅគម្រោងការងារថែទាំប្រព័ន្ធធារាសាស្ត្រ ឆ្នាំ២០២៦ ចំនួន ១៩៣ ប្រព័ន្ធ តាមបណ្តា ២៥ រាជធានី-ខេត្ត រួមមាន៖

- ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម ចំនួន ១៧១ ប្រព័ន្ធ
- ការងារថែទាំប្រចាំប្រព័ន្ធធារាសាស្ត្រខ្នាតធំ ចំនួន ១៨ ប្រព័ន្ធ
- ការងារថែទាំខួបប្រព័ន្ធធារាសាស្ត្រ ចំនួន ៤ ប្រព័ន្ធ
- ការងារជួសជុលបន្ទាន់ ចំនួន ២០ កន្លែង
- ការងារជួសជុល និងថែទាំម៉ាស៊ីនបូមទឹកចល័ត (Kirloskar) ឥណ្ឌា ៦៥ សេះ ចំនួន ១៥ គ្រឿង។

| ល.រ | លេខកូដ | ឈ្មោះមន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្ត | ២០២៦ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនប្រព័ន្ធ | ទំនប់ | | ប្រឡាយ | | សំណង់សិល្បការ្យ (កន្លែង) | ផ្ទៃដី | | អ្នកទទួលផល |
| | | | | ខ្សែ | ប្រវែង (km) | ខ្សែ | ប្រវែង (Km) | | ប្រាំង | វស្សា | ប្រជាជនសរុប |
| ក | ការងារថែទាំជាប្រចាំ ប្រព័ន្ធធារាសាស្ត្រ (ខ្នាតធំ) | | 18 | 11 | 111 | 142 | 924 | 2.146 | 370.284 | 151.081 | 751.215 |
| ខ | ការងារថែទាំខួប | | 4 | | | 12 | 23 | 52 | 4.522 | 2.223 | 15.587 |
| គ | ការងារថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ (ខ្នាតមធ្យម) | | 171 | 171 | 424 | 437 | 788 | 2.353 | 225.479 | 445.432 | 845.529 |
| | សរុបរួម៖ | | 193 | 182 | 535 | 591 | 1.734 | 4.551 | 600.285 | 598.736 | 1.612.331 |

*តារាងទី ២០: តារាងគម្រោងការងារថែទាំប្រព័ន្ធធារាសាស្ត្រ*




*ក្រាហ្វិកទី ២៨: ក្រាហ្វិកបង្ហាញពីគោលដៅសមិទ្ធិផល ឆ្នាំ២០២៦*

## ៧.៦. ការងារវិស្វកម្មធនធានទឹក

នាយកដ្ឋានវិស្វកម្មបន្តអនុវត្តផែនការការងារជួសជុល ស្តារ សាងសង់ប្រព័ន្ធធារាសាស្ត្រឆ្នាំ២០២៦ មានចំនួន ២៣ គម្រោង ស្ថិតក្នុង ១០ខេត្ត ១០ខេត្ត រួមមាន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកោះកុង ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តស្វាយរៀង និងខេត្តតាកែវ។




| ល.រ | ឈ្មោះគម្រោង | ខេត្ត |
|---|---|---|
| ១ | គម្រោងស្តារអូរប្រឡាយក្លាន់(ដំហាន៣) ស្ថិតនៅឃុំហាត់ទឹក ស្រុកមង្គលបុរី | ខេត្តបន្ទាយមានជ័យ |
| ២ | គម្រោងស្តារប្រឡាយមេអន្លង់ទៀវ ស្ថិតនៅឃុំណាំតៅ ស្រុកភ្នំស្រុក | ខេត្តបន្ទាយមានជ័យ |
| ៣ | គម្រោងជួសជុលសំណង់ស្នាក់ទឹកម្នាស់កាល ស្ថិតនៅឃុំតាគ្រី ស្រុកកំរៀង | ខេត្តបាត់ដំបង |
| ៤ | គម្រោងស្តារអូរតាកេវ្ត (ដំហាន២) ស្ថិតនៅឃុំស្តើងជ័យ ស្រុកជើងព្រៃ | ខេត្តកំពង់ចាម |
| ៥ | គម្រោងស្តារប្រឡាយមេអូរសាលា ស្ថិតនៅឃុំស្អី ស្រុកចំការលើ | ខេត្តកំពង់ចាម |
| ៦ | គម្រោងស្តារប្រឡាយស្វាយមាស ស្ថិតនៅឃុំសំពងជ័យ ស្រុកជើងព្រៃ | ខេត្តកំពង់ចាម |
| ៧ | គម្រោងសាងសង់សំណង់ស្នាក់ទឹកព្រែកអន្លង់គគីរ ស្ថិតនៅឃុំស្តៅ ស្រុកកងមាស | ខេត្តកំពង់ចាម |
| ៨ | គម្រោងស្តារប្រឡាយមេបន្ទាយស្ទោង (ដំហាន១) ស្ថិតនៅឃុំបន្ទាយស្ទោង ស្រុកស្ទោង | ខេត្តកំពង់ធំ |
| ៩ | គម្រោងស្តារប្រឡាយរងបន្ទាយស្ទោង (ដំហាន២) ស្ថិតនៅឃុំបន្ទាយស្ទោង ស្រុកស្ទោង | ខេត្តកំពង់ធំ |
| ១០ | គម្រោងសាងសង់សំណង់ស្នាក់ទឹកបន្ទាយស្ទោង ស្ថិតនៅឃុំបន្ទាយស្ទោង ស្រុកស្ទោង | ខេត្តកំពង់ធំ |
| ១១ | គម្រោងជួសជុលប្រព័ន្ធធារាសាស្ត្រឬស្សីលរ ស្ថិតនៅឃុំស្វាយភ្លើង ស្រុកតាំងគោក | ខេត្តកំពង់ធំ |
| ១២ | គម្រោងស្តារប្រឡាយតាហោ (ដំហាន២) ស្ថិតនៅឃុំចុងដូង និងឃុំបឹង ស្រុកបារាយណ៍ | ខេត្តកំពង់ធំ |
| ១៣ | គម្រោងជួសជុលទំនប់ការពារទឹកប្រៃចំការលើ (ដំហាន២) ស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ | ខេត្តកោះកុង |
| ១៤ | ជួសជុលទំនប់អាងទឹកជ្រោយប្រស់ទី៣ ស្ថិតនៅឃុំជ្រោយប្រស់ ស្រុកកោះកុង | ខេត្តកោះកុង |
| ១៥ | គម្រោងស្តារព្រែកតាតាំ ឃុំព្រែកជ្រៃ ស្រុកពោធិ៍រៀង និងសង្កាត់កំពង់លាវ ក្រុងព្រៃវែង | ខេត្តព្រៃវែង |
| ១៦ | គម្រោងស្តារអូរយាយហុក(ដំហាន២) ស្ថិតនៅឃុំតាលោ ស្រុកតាលោសែនជ័យ | ខេត្តពោធិ៍សាត់ |
| ១៧ | គម្រោងសាងសង់ទំនប់អាងទឹកមជ្ឈមណ្ឌលអភិវឌ្ឍប៊ុនរ៉ានីសែនជ័យ ខ្សែទី៧ ស្ថិតឃុំព្រងិល ស្រុកភ្នំក្រវាញ | ខេត្តពោធិ៍សាត់ |
| ១៨ | គម្រោងសាងសង់ទំនប់អាងទឹកមជ្ឈមណ្ឌលអភិវឌ្ឍប៊ុនរ៉ានីសែនជ័យ ខ្សែទី១ ស្ថិតឃុំព្រងិល ស្រុកភ្នំក្រវាញ | ខេត្តពោធិ៍សាត់ |
| ១៩ | គម្រោងជួសជុលទំនប់អាងទឹកស្ទួង៧៨(ដំហាន៣) ស្ថិតនៅឃុំស្ពានត្នោត ស្រុកជីក្រែង | ខេត្តសៀមរាប |
| ២០ | គម្រោងសាងសង់ទំនប់សណ្តរវ៉ៃតោ (ដំហាន២) ស្ថិតនៅសង្កាត់ចេក ក្រុងស្វាយរៀង | ខេត្តស្វាយរៀង |
| ២១ | គម្រោងស្តារព្រែកកំពង់ជ្រៃក្រោម (ដំហាន១) ស្ថិតនៅឃុំស្វាយធំ ស្រុកស្វាយជ្រំ | ខេត្តស្វាយរៀង |
| ២២ | គម្រោងស្តារប្រឡាយមេលេខ៩០ ស្ថិតនៅឃុំក្រពុំឈូក ស្រុកព្រៃកប្បាស | ខេត្តតាកែវ |
| ២៣ | គម្រោងស្តារប្រឡាយមេពង់មួយ ស្ថិតនៅឃុំកុមាររាជា ស្រុកបាទី | ខេត្តតាកែវ |

*តារាងទី ២១: តារាងគម្រោងការងារជួសជុល ស្តារ សាងសង់ប្រព័ន្ធធារាសាស្ត្រ២០២៦*




*ក្រាហ្វិកទី ២៩: ក្រាហ្វិកបង្ហាញពីគោលដៅសមិទ្ធផលនៃការអនុវត្តគម្រោង២០២៦*




*ក្រាហ្វិកទី ៣០: ក្រាហ្វិកបង្ហាញពីគោលដៅផ្ទៃដីស្រោចស្រពនៅឆ្នាំ២០២៦*

## ៧.៧. ការងារជលសាស្ត្រ និងទន្លេ

- បន្តពង្រឹង និងអនុវត្តការងារដែលបានបំពេញកន្លងមក ឱ្យបានកាន់តែល្អប្រសើរ
- បន្តចុះថែទាំ ជួសជុលស្ថានីយជលសាស្ត្រ
- បន្តតាមដានស្ថានភាពជលសាស្ត្រទាំងក្នុងប្រទេសកម្ពុជា និងតំបន់
- បន្តការប្រមូលទិន្នន័យជលសាស្ត្រ យកសំណាកទឹក កករដី និងវិភាគគុណភាពទឹក តាមបណ្តាស្ថានីយដែលបានអនុវត្តកន្លងមក និងកន្លែងផ្សេងទៀតតាមការចាំបាច់
- ពង្រឹងសមត្ថភាពមន្ត្រីឱ្យស្វែងយល់ពីការងារព្យាករណ៍កម្ពស់ទឹក ការងារជលសាស្ត្រ ការងារទន្លេ និងការវិភាគគុណភាពទឹក ដោយបន្តសហការជាមួយ MRCS និងដៃគូផ្សេងៗ
- អនុវត្តគម្រោងការពារច្រាំងទន្លេឆ្នាំ២០២៦ មាន ៦គម្រោងរួមមាន៖
  - គម្រោងការពារច្រាំងទន្លេបាសាក់ ប្រវែង ៥០០ម៉ែត្រ ជាSpun pile បេតុងអាមេ ក្រណាត់បាវ និងប្រអប់ថ្មនៅភូមិជ្រៃធំ សង្កាត់ព្រែកជ្រៃ ក្រុងសំពៅពូន ខេត្តកណ្តាល
  - គម្រោងការពារច្រាំងព្រែកកុយ ប្រវែង ២០០ម៉ែត្រ ជាប្រអប់ថ្ម ស្ថិតនៅភូមិអន្លង់គគីរ ឃុំព្រែកស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម

- គម្រោងការពារច្រាំងព្រែកកុយ ចំនួន ៤ទីតាំង ប្រវែង ៤៦៥ម៉ែត្រ ជាប្រអប់ថ្ម រួមជាមួយប្រព័ន្ធដោះទឹកក្រោមដី និងធ្វើផ្លូវបេតុង ស្ថិតនៅភូមិព្រែកកុយ ឃុំព្រែកស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម
- គម្រោងការពារច្រាំងទន្លេមេគង្គ ប្រវែង ៦០០ម៉ែត្រ ដោយប្រើបាវខ្សាច់ Geobag ប្រវែង ៤០០ម៉ែត្រ និងប្រអប់ថ្ម Gabion box ជាមួយបាវខ្សាច់ Geobag នៅផ្នែកខាងក្រោមប្រវែង ២០០ម៉ែត្រ ស្ថិតនៅភូមិផ្សារថ្មី និងភូមិជីហែ ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម
- គម្រោងការពារច្រាំងទន្លេមេគង្គ ប្រវែង ៤៣០ម៉ែត្រ ដោយប្រើបាវខ្សាច់ Geobag នៅភូមិតាហុប ឃុំជំនិក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និង
- គម្រោងការពារច្រាំងទន្លេមេគង្គ ប្រវែង ៤២០ម៉ែត្រ ដោយប្រើបាវខ្សាច់ Geobag ស្ថិតនៅភូមិខ្សាច់ប្រឆេះកណ្ដាល ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

## ៧.៨. ការងារឧតុនិយម

- បន្តចុះថែទាំ ជួសជុលស្ថានីយឧតុនិយមមិនស្វ័យប្រវត្តិ និងប៉ុស្តិ៍តម្រងទឹកភ្លៀង
- បន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានប្រតិបត្តិសម្រាប់ការប្រមូល និងគ្រប់គ្រងការប្រើប្រាស់ ធនធានទិន្នន័យឧតុនិយម ដើម្បីផ្តល់ដល់គ្រប់វិស័យពាក់ព័ន្ធរួមមាន ធនធានទឹក កសិកម្ម ឧស្សាហកម្ម គមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) បរិស្ថាន និងទេសចរណ៍ ទាំងថ្នាក់ជាតិ និងអន្តរជាតិ ដោយអនុលោមតាម WMO ដែលមានប្រទេសជាសមាជិក ១៩៣ប្រទេស
- បន្តពង្រឹង និងពង្រីកការដំឡើងបណ្តាញស្ថានីឧតុនិយម ដូចជាៈឧតុនិយមរ៉ាដា ឧតុនិយមផ្កាយរណប ស្ថានីយឧតុនិយម វាស់សម្ពាធបរិយាកាស (Upper Air Radiosondes) ដើម្បីប្រមូលទិន្នន័យឧតុនិយមឱ្យស្របតាមលក្ខណៈការប្រែប្រួលអាកាសធាតុ
- បន្តសហការជាមួយដៃអភិវឌ្ឍន៍ ជាតិ និងអន្តរជាតិ ថ្នាក់តំបន់ និងសកលលោក ក្នុងការអភិវឌ្ឍវិស័យឧតុនិយមទាំងផ្នែកធនធានមនុស្ស ផ្នែកឧបករណ៍ និងសម្ភារៈបច្ចេកទេស ឱ្យសមស្របតាមការវិវត្តបច្ចេកវិទ្យា ដើម្បីឱ្យឆ្លើយតបតាមតម្រូវការជាក់ស្តែង និងបម្រើដល់គ្រប់វិស័យ
- ជួសជុលស្ថានី ថែទាំស្ថានីយឧតុនិយមស្វ័យប្រវត្តិ ៣៩ស្ថានីយ មិនស្វ័យប្រវត្តិ ៤ស្ថានីយ និងតម្រងទឹកភ្លៀង ២២កន្លែង

## ៧.៩. ការងារសហគមន៍កសិករប្រើប្រាស់ទឹក

ឆ្នាំ២០២៦នេះ នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក បានលើកទិសដៅចុះអនុវត្តសកម្មភាពការងារជាក់ស្តែងបន្តនៅតាមបណ្តារាជធានី-ខេត្ត ទាំង២៥ ដូចខាងក្រោមៈ

### ក. ការងាររៀបចំពង្រីកក្រុមកសិករប្រើប្រាស់ទឹក

នាយកដ្ឋានបានរៀបចំផែនការពង្រីកក្រុមកសិករប្រើប្រាស់ទឹក ១ក្រុម នៃសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រហ៊ុនសែនបារាយណ៍ ក្នុងខេត្តកំពង់ធំ។

### ខ. ការងារបណ្តុះបណ្តាល និងពង្រឹង ស.ក.ប.ទ.

នាយកដ្ឋានក៏បានរៀបចំផែនការសម្រាប់ការបណ្តុះបណ្តាលដល់សហគមន៍កសិករប្រើប្រាស់ទឹកចំនួន ២០០សហគមន៍ទូទាំង ២៥រាជធានី-ខេត្ត។

### គ. ការងារត្រួតពិនិត្យ ពង្រឹង និងគាំទ្រដល់ ស.ក.ប.ទ.

ផែនការការងារសម្រាប់ការត្រួតពិនិត្យ ពង្រឹង និងគាំទ្របច្ចេកទេសដល់សហគមន៍កសិករប្រើប្រាស់ទឹកចំនួន ១៧៦ សហគមន៍ ក្នុង ២២រាជធានី-ខេត្ត ដូចក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | ចំនួន ស.ក.ប.ទ. | ល.រ | រាជធានី-ខេត្ត | ចំនួន ស.ក.ប.ទ. |
|---|---|---|---|---|---|
| ១ | ខេត្តបន្ទាយមានជ័យ | ៥ | ១២ | ខេត្តព្រៃវែង | ៦ |
| ២ | ខេត្តបាត់ដំបង | ១០ | ១៣ | ខេត្តពោធិ៍សាត់ | ១២ |
| ៣ | ខេត្តកំពង់ចាម | ១៣ | ១៤ | ខេត្តសៀមរាប | ៥ |
| ៤ | ខេត្តកំពង់ឆ្នាំង | ១៥ | ១៥ | ខេត្តព្រះសីហនុ | ៣ |
| ៥ | ខេត្តកំពង់ស្ពឺ | ១៧ | ១៦ | ខេត្តស្ទឹងត្រែង | ១០ |
| ៦ | ខេត្តកំពង់ធំ | ១២ | ១៧ | ខេត្តស្វាយរៀង | ៦ |
| ៧ | ខេត្តកំពត | ៤ | ១៨ | ខេត្តតាកែវ | ៤ |
| ៨ | ខេត្តកណ្ដាល | ៨ | ១៩ | ខេត្តឧត្តរមានជ័យ | ៩ |
| ៩ | ខេត្តក្រចេះ | ៣ | ២០ | ខេត្តកែប | ២ |
| ១០ | រាជធានីភ្នំពេញ | ៣ | ២១ | ខេត្តប៉ៃលិន | ៣ |
| ១១ | ខេត្តព្រះវិហារ | ១១ | ២២ | ខេត្តត្បូងឃ្មុំ | ១១ |

## ៧.១០.ការងារគ្រប់គ្រង និងអភិរក្សធនធានទឹក

១. បន្តប្រមូលទិន្នន័យព័ត៌មាន ទាក់ទងនឹងធនធានទឹក ដើម្បីរៀបចំជាកម្រងព័ត៌មានអាងទន្លេ។

២. បន្តផ្សព្វផ្សាយច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក។

៣. បន្តចុះបញ្ជីជូនអ្នកប្រើប្រាស់ទឹកគ្រប់វិស័យ។

៤. បន្តធ្វើអន្តរាគមន៍លើការទន្ទ្រានយកដីអាងតម្កល់ទឹក ដីចំណីអាងទឹក ចំណីទន្លេ ព្រែក ស្ទឹង អូរ និងប្រភពទឹក។

៥. បន្តពិនិត្យតាមដានការកំណត់ព្រំអាងទឹក និងជំរុញការទៅចុះបញ្ជី។

៦. បន្តចេញលិខិតអនុញ្ញាតប្រើប្រាស់ទឹក ទៅតាមបទដ្ឋានគតិយុត្ត។

៧. ចូលរួមពិនិត្យខ្លឹមសារ និងការរៀបចំសៀវភៅទិដ្ឋភាពទូទៅ និងកំណត់ចំណាំអាងទឹកធំៗ។

## ៧.១១.ការងារទឹកស្អាត និងអនាម័យ

១. សាងសង់បន្ថែមអណ្ដូងតាមដានទឹកក្រោមដី (ទីតាំងខេត្តកំពង់ធំ និងខេត្តសៀមរាប)។

២. តាមដាន ត្រួតពិនិត្យ និងកត់ត្រាទិន្នន័យទឹកក្រោមដីប្រចាំខែសម្រាប់ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង។

៣. ពិនិត្យលទ្ធភាពពង្រីកការតាមដាន និងកសាងទិន្នន័យទឹកក្រោមដី នៅបណ្ដាខេត្តថ្មីផ្សេងទៀត។

៤. រៀបចំបញ្ចប់ឯកសារក្របខណ្ឌគ្រប់គ្រងទឹកក្រោមដី។

## ៧.១២.ការងារយេនឌ័រ

- បន្តចុះសិក្សាស្រាវជ្រាវពីតួនាទី និងបញ្ហាយេនឌ័រ និងផ្តល់ការផ្សព្វផ្សាយក្នុងការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ (O&M) ដែលឆ្លើយតបនឹងយេនឌ័រតាម សកបទ ក្នុងវិស័យធនធានទឹក ២៥ខេត្ត។
- បន្តពង្រឹងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តឆ្លើយតបនឹងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្រសួង។
- បន្តសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលសូចនាករយេនឌ័រក្នុងគោលនយោបាយច្បាប់ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍របស់ក្រសួង។
- បន្តផ្តល់វគ្គបណ្តុះបណ្តាល/សិក្ខាសាលាលើការងារយេនឌ័រដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (GMSP)ក្នុងវិស័យធនធានទឹកឆ្នាំ២០២៤-២០២៨ និងពន្លឿនការអនុវត្តន៍ប្រកបដោយសមធម៌។

- បន្តកៀងគរថវិកាពីដៃគូអភិវឌ្ឍ ដើម្បីអនុវត្តការបញ្ជ្រាបប្រព័ន្ធការងារយេនឌ័រក្នុងវិស័យធនធានទឹក (គាំទ្រថវិកាសមិទ្ធកម្ម, ថវិកាបង្កប់ក្នុងគម្រោង IWRM, IAIP, CFAVCSP/ADB, EIB, AIIB, WB..)។
- បន្តផ្សព្វផ្សាយអនុសញ្ញាស៊ី-ដ តាមរយៈកិច្ចប្រជុំ និងទស្សនកិច្ចសិក្សា សិក្ខាសាលា និងវេទិកាយេនឌ័រ។
- បន្តពង្រឹងសមត្ថភាពក្រុមការងារយេនឌ័រ និងមន្ត្រីបង្គោល, រួមទាំងមន្ត្រីវ័យក្មេងទាំងបុរស និងស្ត្រី នៅថ្នាក់ជាតិ និងតាមមន្ទីររាជធានី ខេត្ត នឹងទទួលបាននូវការបញ្ជ្រាប និងការវិភាគយេនឌ័រ, វដ្តនៃការគ្រប់គ្រងគម្រោង ដែលឆ្លើយតបនឹងយេនឌ័រ, ការធ្វើផែនការ និងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ, បញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុ, បញ្ជ្រាបយេនឌ័រ និងការគ្រប់គ្រងធនធានទឹកចម្រុះ(IWRM), ការគ្រប់គ្រង និងប្រើប្រាស់សំណង់ជារាសាស្រ្ត(O&M) ដោយមានការចូលរួមពីយេនឌ័រ, ការសរសេរគម្រោង និងសរសេរបាយការណ៍ ដែលឆ្លើយតបនឹងយេនឌ័រ (Gender Responsive) យេនឌ័រសេវនកម្ម......។

# ៨. គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ





## ៨. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ

### ៨.១. លទ្ធផលការងារសម្រេចការងារឆ្នាំ២០២៥

- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័នលើកទី២ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥
- បានរៀបចំផលិតព្រឹត្តិបត្រព័ត៌មានប្រតិបត្តិការទំនប់ធំៗសំខាន់ៗ
- បានចុះជំរុញផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេដល់ថ្នាក់ខេត្តចំនួន៤ និង១ សកលវិទ្យាល័យ រួមមាន៖ ខេត្តពោធិ៍សាត់ ខេត្តតាកែវ ខេត្តកណ្ដាល ខេត្តស្វាយរៀង និងសកលវិទ្យាល័យន័រតុន
- បានសម្របសម្រួលថ្នាក់ខេត្តរៀបចំសេចក្ដីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងអាងទន្លេរាជធានី-ខេត្តទាំង២៥
- បានចុះអនុវត្តពង្រឹងវិធានការច្បាប់នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេនៅអាងទន្លេនានា







រូបថតកិច្ចប្រជុំ នាថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥**នៅទីស្តីការក្រសួង (សាលប្រជុំរំដួល)**

# សកម្មភាពចុះជំរុញផ្សព្វផ្សាយអនុក្រឹត្យស្តីពី ការគ្រប់គ្រងអាងទន្លេ



ខេត្តកណ្តាល



ខេត្តតាកែវ



ខេត្តពោធិ៍សាត់




ខេត្តកំពង់ស្ពឺ



ខេត្តកំពង់ធំ



សកលវិទ្យាល័យន័រតុន

# ការរៀបចំផលិតព្រឹត្តិបត្រព័ត៌មានប្រតិបត្តិការទំនប់ធំៗសំខាន់ៗ



ព្រឹត្តិបត្រព័ត៌មានប្រតិបត្តិការទំនប់ សម្រាប់រដូវប្រាំង



ព្រឹត្តិបត្រព័ត៌មានប្រតិបត្តិការទំនប់ សម្រាប់រដូវវស្សា

# រូបភាពតំណាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងអាងទន្លេ រាជធានីខេត្តទាំង២៥


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង
លេខ ០១៧/ ស.ស.រ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលគណៈកម្មាធិការខេត្តគ្រប់គ្រងអាង ទន្លេ ខេត្តកោះកុង

អភិបាល នៃគណៈអភិបាលខេត្តកោះកុង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្ទឹងត្រែង
លេខ ៖ ០៤៥/២៥ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មាធិការគ្រប់គ្រងអាងទន្លេខេត្តស្ទឹងត្រែង

អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង
លេខ: ១០២/២៣សសរ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពគណៈកម្មាធិការគ្រប់គ្រងក្រវ៉ាងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ក្នុងខេត្តស្វាយរៀង

អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រៃវែង
លេខ: ០៤០/២៥ សសរ.ព.វ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការខេត្តគ្រប់គ្រងស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ខេត្តព្រៃវែង

អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំង

## ៨.២. ទិសដៅអនុវត្តការងារឆ្នាំ២០២៦

- គ្រោងស្នើសុំចង់កែសម្រួលសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដោយដាក់បញ្ចូលសមាសភាពពីអន្តរក្រសួងបន្ថែមទៀត ដើម្បីបំពេញឱ្យត្រូវទៅតាម អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ
- បន្តផ្សព្វផ្សាយដល់អាជ្ញាធរខេត្តពាក់ព័ន្ធទាំងអស់ ស្តីពីសារសំខាន់នៃការគ្រប់គ្រងអាងទន្លេ បញ្ជ្រាបការយល់ដឹងពីច្បាប់ទឹក និងអនុក្រឹតស្តីពីការគ្រប់គ្រងអាងទន្លេ
- ចុះបេសកកម្មទៅតាមខេត្តប្រមូលព័ត៌មានជាបឋម ដើម្បីឈានទៅរកការរៀបចំផែនការគ្រប់គ្រងអាងទន្លេ
- បន្តគ្រប់គ្រងការងារប្រតិបត្តិទំនប់ដើម្បីគ្រប់គ្រងទឹក ជំនន់ និងរាំងស្ងួត
- រៀបចំសិក្ខាសាលាជាមួយដៃគូ អង្គការជាតិ និងអន្តរជាតិ
- ផ្សព្វផ្សាយ និងពង្រឹងការយល់ដឹងអំពីបរិមាណទឹក ការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ទឹកក្នុងអាងស្ទឹង ទន្លេ
- សហការជាមួយបណ្តាក្រសួងដែលជាសមាជិកគណៈកម្មាជាតិគ្រប់គ្រងអាងទន្លេ
- ស្វែករកប្រភពថវិការសម្រាប់អនុវត្តការងារ

# ៩. គណៈកម្មាធិការជាតិគ្រប់គ្រងធនធានខ្សាច់











## ៩. របាយការណ៍គណៈកម្មាធិការជាតិគ្រប់គ្រងធនធានខ្សាច់

### ១. សេចក្តីផ្តើម

**ខ្សាច់** គឺជាធនធានធម្មជាតិដ៏មានតម្លៃ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុង ឧស្សាហកម្មសំណង់ និងវិស័យផ្សេងៗ។ ខ្សាច់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយចូលរួមថែរក្សាសុខភាព និងមុខងាររបស់ស្ទឹង ទន្លេ និងសមុទ្រ។ វាជាតម្រងធម្មជាតិ ជួយរក្សាគុណភាពទឹក និងផ្តល់ជាជម្រកសម្រាប់សេរីរាង្គទឹកផ្សេងៗ។ ខ្សាច់ គឺជាធាតុផ្សំដ៏សំខាន់នៃដីល្បាប់ វាជួយការពារ និងថែទាំបាតស្ទឹង ទន្លេ តំបន់ដីសណ្តរ និងតំបន់ឆ្នេរ ព្រមទាំងអាចជួយរក្សាស្ថិរភាពច្រាំងស្ទឹង ទន្លេ ការពារការកកស្ទះរំហូរទឹក និងការពារហេដ្ឋារចនាសម្ព័ន្ធផងដែរ។

ការគ្រប់គ្រងធនធានខ្សាច់ គឺមានសារៈសំខាន់ណាស់ដើម្បីធានាបាននូវការធ្វើអាជីវកម្មធនធានខ្សាច់ ពាក់ព័ន្ធនឹងធនធានទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងបរិយាបន្ន ដែលចាំបាច់ត្រូវមានការការពារសុខភាពស្ទឹង ទន្លេ និងប្រព័ន្ធអេកូឡូស៊ីឱ្យបានល្អ។ ផ្ទុយទៅវិញ ការធ្វើអាជីវកម្មធនធានខ្សាច់ដែលទាញយកខ្សាច់ច្រើនហួសកម្រិតពីស្ទឹង ទន្លេ និងតំបន់ឆ្នេរ អាចមានផលវិបាកអវិជ្ជមានជាច្រើនដូចជា៖ ការបាក់ច្រាំងស្ទឹង ទន្លេ ការកកស្ទះរំហូរទឹក ការផ្លាស់ប្តូរចរន្តទឹក និងបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ច និងសង្គមផងដែរ។

ការងារគ្រប់គ្រងធនធានខ្សាច់ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវការជាចាំបាច់នូវកិច្ចសហការពីអន្តរក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធពីវិស័យផ្សេងៗ ដើម្បីចូលរួមពិភាក្សាគ្នា និងស្វែងរកដំណោះស្រាយសមស្របនានា។

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ (**គ.ធ.ខ.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ដែលជាសេនាធិការ ឱ្យរាជរដ្ឋាភិបាលដើម្បី "**ត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មធនធានខ្សាច់ពាក់ព័ន្ធនឹងធនធានទឹក សំដៅធានាប្រសិទ្ធភាព និរន្តរភាព និងបរិយាបន្ន**"។

ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ (**ល.គ.ធ.ខ**) ត្រូវបានបង្កើតឡើងដោយ សេចក្តីសម្រេចលេខ ០០៨ សសរ.ធទឧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គ.ធ.ខ.ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥ ដែល ជួយសម្របសម្រួល និងគាំទ្រដល់ការអនុវត្តភារកិច្ច និងការទទួលខុសត្រូវ។

លេខាធិការដ្ឋាននៃ គ.ធ.ខ. មានភារកិច្ច៖ (១) រៀបចំផែនការការងារ ហិរញ្ញវត្ថុ និងកិច្ចប្រជុំរបស់ គ.ធ.ខ. (២) សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាសមាជិក គ.ធ.ខ. (៣) ចុះត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មធនធានខ្សាច់ពាក់ព័ន្ធនឹងធនធានទឹក និងបច្ចេកទេសបូមខ្សាច់ ស្របតាមបទដ្ឋានបច្ចេកទេសជលវិទ្យានិងជលគតិ ដើម្បីរាយការណ៍ជូនប្រធាន គ.ធ.ខ. និង(៤)អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន គ.ធ.ខ។

### ២. លទ្ធផលការងារសម្រេចបានឆ្នាំ២០២៥

ដើម្បីធានាបានប្រសិទ្ធភាព ប្រសិទ្ធផលការងារ និងសម្រួលដល់កិច្ចដំណើរការ និងកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃរបស់ខ្លួន លេខាធិការដ្ឋានបានបំពេញបន្ថែមសមាសភាព ចំនួន ៤ រូប និងរៀបចំបែងចែកភារកិច្ចទទួលបន្ទុករបស់ថ្នាក់ដឹកនាំ និងការទទួលខុសត្រូវតាមផ្នែកនានាចំណុះឱ្យលេខាធិការដ្ឋាន ដែលមានផ្នែកចំនួន ៥។




ដើម្បីសម្រួលដល់ដំណើរការបំពេញការងារប្រចាំថ្ងៃ និយាមនីតិវិធីប្រតិបត្តិ (SOP) ចំនួន៣ ត្រូវបានបង្កើតឡើងសម្រាប់អនុវត្ត ដូចខាងក្រោម៖

១) នីតិវិធីលើដំណើរការរៀបចំកិច្ចប្រជុំរបស់ គ.ធ.ខ

២) នីតិវិធីលើកិច្ចដំណើរការចុះត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មខ្សាច់ពាក់ព័ន្ធនឹងធនធានទឹក និងបច្ចេកទេសបូមខ្សាច់ស្របតាមបទដ្ឋានបច្ចេកទេសជលវិទ្យា និងជលគតិ និង

៣) នីតិវិធីលើកិច្ចដំណើរការសិក្សាជលវិទ្យា និងជលគតិ។









## រំហូរការងារ និងរយៈពេលត្រូវការសម្រាប់ការសិក្សាជលវិទ្យា និងជលគតិ ១ករណី




## ២.១. ថ្នាក់ដឹកនាំ

- ដឹកនាំក្រុមការងារលេខាធិការដ្ឋានដើម្បីសម្របសម្រួល និងរៀបចំដំណើរបេសកកម្ម និងកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ដឹកនាំក្រុមការងារលេខាធិការដ្ឋាន ដើម្បីបំពេញការងាររបស់លេខាធិការដ្ឋាន
- បំពេញការងារផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- សហការជាមួយអន្តរក្រសួង ដៃគូរអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជនក្នុងជំនួញផ្សេងៗ កិច្ចប្រជុំ សិក្ខាសាលា ដើម្បីផ្តល់ការពិភាក្សា និងជាតុចូលទាក់ទងនឹងការគ្រប់គ្រងធនធានខ្សាច់ ។







## ២.២. ផ្នែករដ្ឋបាល



ផ្នែករដ្ឋបាល ជាសេនាធិការរបស់លេខាធិការដ្ឋាន នៃ គ.ធ.ខ . ក្នុងការរៀបចំបែបបទឯកសារទាំងឡាយ សម្រាប់បម្រើឱ្យការអនុវត្តសកម្មភាពនានា នៅក្នុងលេខាធិការដ្ឋាននៃ គ.ធ.ខ. និងសហការជាមួយផ្នែកផ្សេងៗ ព្រមទាំងទំនាក់ទំនងជាមួយក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន មុនដំណើរការចុះបេសកកម្ម ដែលសកម្មភាពរួមមានដូចខាងក្រោម ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់គណៈកម្មាធិការ និងលេខាធិការដ្ឋាន ព្រមទាំងឯកសារ និងធ្វើរបាយការណ៍កិច្ចប្រជុំ ចំនួន ៦ដង នៅក្នុងឆ្នាំ២០២៥

- រៀបចំសម្របសម្រួលសំណើសុំបោះត្រាលើរបាយការណ៍សិក្សាជលវិទ្យា និងជលគតិ នៃគម្រោងស្នើសុំធ្វើអាជីវកម្មខ្សាច់ ចំនួន ១៧គម្រោង ដែលមានចំនួន ១៦ក្រុមហ៊ុន/សហគ្រាស
- រៀបចំបន្ទប់លេខាធិការដ្ឋាននៃ គ.ធ.ខ. ដែលមានទីតាំង នៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម (លុច្ប)។



- រៀបចំសំណុំបែបបទលិខិតចុះបេសកកម្ម និង របាយការណ៍ ជូនគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងលេខាធិការដ្ឋាននៃ គ.ធ.ខ.
- សហការរៀបចំ (១)នីតិវិធីលើដំណើរការរៀបចំកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងលេខាធិការដ្ឋាន (២)នីតិវិធីលើកិច្ចដំណើរការចុះត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្មធនធានខ្សាច់ពាក់ព័ន្ធនឹងធនធានទឹក និងបច្ចេកទេសបូមខ្សាច់ស្របតាមបទដ្ឋានបច្ចេកទេសជលវិទ្យា និងជលគតិ និង (៣)នីតិវិធីលើកិច្ចដំណើរការសិក្សាជលវិទ្យា និងជលគតិ
- សហការជាមួយរាល់ផ្នែកពាក់ព័ន្ធ ដើម្បីប្រមូលនិងរៀបចំចងក្រងរបាយការណ៍សង្ខេប ស្តីពីវឌ្ឍនភាពការងារប្រចាំត្រីមាស-ឆមាស និងផែនការសកម្មភាពការងារសម្រាប់ត្រីមាស-ឆមាសបន្ទាប់

## ២.៣. ផ្នែកហិរញ្ញវត្ថុ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០២៦ និងថវិកា៣ឆ្នាំរំកិល ២០២៦-២០២៨
- រៀបចំផែនការថវិកា សម្រាប់ចុះបេសកកម្មប្រចាំឆ្នាំ២០២៥ និងរៀបចំផែនការចំណាយប្រចាំឆ្នាំ២០២៥ លើកផែនការចំណាយប្រចាំឆ្នាំ២០២៦ និងឆ្នាំបន្តបន្ទាប់
- ចូលរួមប្រជុំស្តីពីផែនការថវិកាឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម** និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ នៅសាលរំដួល (ក្បាលថ្នល់)
- ចូលរួមប្រជុំចរចាថវិកាឆ្នាំ២០២៦ សម្រាប់ក្រសួងធនធានទឹក និងឧតុនិយម នៅ ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



- បានស្នើសុំគោលការណ៍ចំណាយថវិកា ចំនួន ៦៩៦.០០០.០០០៛ សម្រាប់អនុវត្តសកម្មភាពការងារក្នុងកម្មវិធីទី៤ អនុកម្មវិធីទី២ ចង្កោមសកម្មភាពទី១ ឆ្នាំ២០២៥ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំរចនាសម្ព័ន្ធកម្មវិធីថវិកាឆ្នាំ២០២៦ និងគោលបំណងគោលនយោបាយ-កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាពឆ្នាំ២០២៦
- បាននិងកំពុងរៀបចំធ្វើការបិទបញ្ជីលើចំណាយសម្រាប់កិច្ចប្រជុំលើកទី១ និងលើកទី២ និងការចំណាយប្រចាំថ្ងៃ ក្នុងលេខាធិការដ្ឋាន

## ២.៤. ផ្នែកបច្ចេកទេស

- បានចូលរួមសហការរៀបចំនីតិវិធីទាំងបីរួមមាន៖(១) នីតិវិធីលើដំណើរការរៀបចំកិច្ចប្រជុំ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងលេខាធិការដ្ឋាន (២) នីតិវិធីលើកិច្ចដំណើរការចុះត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្ម ធនធានខ្សាច់ពាក់ព័ន្ធនឹងធនធានទឹក និង បច្ចេកទេសបូមខ្សាច់ស្របតាមបទដ្ឋានបច្ចេកទេសជលវិទ្យា និងជលគតិ និង (៣)នីតិវិធីលើកិច្ចដំណើរការសិក្សាជលវិទ្យា និងជលគតិ
- បានធ្វើការសិក្សាជលវិទ្យា និងជលគតិ លើការស្នើសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មខ្សាច់ ដែលសរុបមានក្រុមហ៊ុនចំនួន ១៦ ស្មើនឹង ១៩ទីតាំង ដូចមានក្នុងតារាងខាងក្រោម៖



*រូបថត ផែនទី សៀវភៅសិក្សាជលវិទ្យា ក្រាហ្វិក និងក្រុមការងារចុះសិក្សា*

| ល.រ | ក្រុមហ៊ុន | ទីតាំងធ្វើអាជីវកម្ម | ផ្ទៃដី (ហ.ត) |
|---|---|---|---|
| ១ | ក្រុមហ៊ុន ស៊ី មីនើរ៉ល អិចផ្លថេសិន ប្រូសេស៊ីង អ៊ីមផត អ៊ិចផត ឯ.ក | ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង | ១០៥.០០ |
| | | តាមដងព្រែកអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ និងឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង | ៩.០០ |
| ២ | សហគ្រាស ស៊ី ធី បាសាក់ រីវើ | តាមដងទន្លេបាសាក់ ឃុំព្រែកគយ និងឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល | ៨.៤០ |
| ៣ | លោក គៀង ចិត្រា | ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង | ៧.០០ |
| ៤ | លោក អ៊ាត សីម៉ា | តាមដងស្ទឹងអារ៉ែង ភូមិសំរោង ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្តកោះកុង | ៨.៧០ |
| ៥ | ក្រុមហ៊ុន អេស៊ា អេនើជី អ៊ិនធើណេសិនណល ឯ.ក | តាមដងព្រែកកោះប៉ោ ភូមិកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង | ៨០.២២ |
| ៦ | សហគ្រាសបញ្ញាឫទ្ធិ ធ្វើអាជីវកម្មខ្សាច់ សំណង់ | ឃុំសេសាន ស្រុកអូរយ៉ាដាវ ខេត្តរតនគីរី | ៧.០០ |
| ៧ | ក្រុមហ៊ុន ចតុមុខ | តាមដងទន្លេមេគង្គលើ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម | ៩៣.៣០ |
| ៨ | ក្រុមហ៊ុន កោះកុង អេស អ៊ី ហ្សិត ខូអិលធីឌី | ភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង | ៣៧៥.០០ |
| ៩ | ក្រុមហ៊ុន ជៀកាង ឌីវេឡុបមិន ឯ.ក | តាមដងទន្លេបាសាក់ព្រំប្រទល់ឃុំព្រែកស្តី និងឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល | ១១៨.៤៩ |
| ១០ | សហគ្រាសខ្សាច់សំណង់កងមាស អភិវឌ្ឍន៍ | តាមដងទន្លេក្រោម ឃុំជីឥដ្ឋ និងឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល | ៣១.០០ |

| | | | |
|---|---|---|---|
| ១១ | ក្រុមហ៊ុន ASIA ENERGY INTERNATIONAL CO., LTD | ព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង | ២៩.៤២ |
| ១២ | ក្រុមហ៊ុន CATALYST MARINE AND RESOURCES CAMBODIA CO., LTD. | ព្រែកកោះប៉ោ ខេត្តកោះកុង | ១៤៧.០០ |
| | | ព្រែកត្រពាំងរូង ខេត្តកោះកុង | ៦១.០០ |
| ១៣ | ក្រុមហ៊ុន GLOBAL GREEN ( CAMBODIA ) ENVERGY DEVELOPMENT CO., LTD | សង្កាត់កោះឧញ៉ាតី សង្កាត់ព្រែកហ្លួង និងសង្កាត់ព្រែកតាកូវ ក្រុងអរិយក្សត្រ ខេត្តកណ្ដាល | ៣៣.៤០ |
| | | សង្កាត់ព្រែកលៀប និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | ៤៤.០០ |
| ១៤ | ក្រុមហ៊ុន អេស.ធី.វ៉ាយ.ភី អាហ្វ្រិខលឈរ ឯ.ក | ឃុំសេសាន ស្រុកអណ្ដូងមាស ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី | ៦.៤០ |
| ១៥ | លោក ហេន សុខឃាង | តាមដងទន្លេមេគង្គលើ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ | ៥.០០ |
| ១៦ | លោក ហ៊ី ហ៊ុនទូច | តាមដងទន្លេទន្លេមេគង្គលើ ឃុំកោះច្រែង ស្រុកចិត្របុរី ខេត្តក្រចេះ | ៥.០០ |

## ២.៥. ផ្នែកផែនការ

- បានសហការរៀបចំផែនការសកម្មភាព ជូនក្រុមការងារបច្ចេកទេសនៃ គ.ធ.ខ. ដើម្បីចុះធ្វើការសិក្សាជលវិទ្យា និងជលគតិលើទីតាំងស្នើសុំអាជ្ញាបណ្ណសម្រាប់ធ្វើអាជីវកម្មខ្សាច់ថ្មីរបស់ក្រុមហ៊ុន-សហគ្រាសចំនួន ៧
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សម្រាប់ទីតាំងគ្រោងស្នើសុំថ្មីទាំងអស់ផងដែរ
- ក្រុមការងារក៏បានចូលរួមជាមួយផ្នែកបច្ចេកទេសចុះសិក្សាជលវិទ្យា និងជលគតិតាមការស្នើសុំរបស់ក្រុមហ៊ុនចំនួន ១៦ ស្មើនឹង ១៩ទីតាំង។

## ២.៦. ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ

- បានបង្កើតហ្វេសប៊ុកផ្លូវការរបស់ លេខាធិការដ្ឋាន នៃ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដែលមានឈ្មោះថា «**លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់**»
- បានផ្សព្វផ្សាយអត្ថបទសម្រាប់ធ្វើការផ្សព្វផ្សាយទំព័រហ្វេសបុកផ្លូវការរបស់ក្រសួងធនធានទឹក និងឧតុនិយម និងលេខាធិការដ្ឋានអំពីសកម្មភាពកិច្ចប្រជុំ និងការចុះបេសកកម្មទាំងអស់ របស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់



## ៣. លទ្ធផលការងារចុះត្រួតពិនិត្យ

ក្រុមការងារលេខាធិការដ្ឋាន គ.ធ.ខ បានចុះត្រួតពិនិត្យស្វែងរកការពិតលើទីតាំងធ្វើអាជីវកម្មធនធានរ៉ែខ្សាច់មួយចំនួនមានដូចខាងក្រោម៖

➢ **ស្វែងយល់ការព្រួយបារម្ភ** របស់ប្រជាពលរដ្ឋដែលរស់នៅតំបន់ធ្វើអាជីវកម្មនៅសង្កាត់ព្រែកតាកូវ និងសង្កាត់ព្រែកលួង ក្រុងអរិយក្សត្រ ខេត្តកណ្ដាល របស់ក្រុមហ៊ុន Global Green



- ✓ ព្រួយបារម្ភពីការខ្លាចបាក់ច្រាំង (២០ ឆ្នាំមុនមានការបូមខុសបច្ចេកទេស បូមក្បែរច្រាំង)
- ✓ សាឡង់បូមនៅទីតាំងដដែលពុំមានការចល័ត (៧ថ្ងៃ)
- ✓ អនុវត្តធ្វើអាជីវកម្មតាមឃ្លង ក៏ប៉ុន្តែពុំមានការបោះពោងសញ្ញា

តាមការពិនិត្យជាក់ស្តែងរបស់ក្រុមការងារ បើក្រុមហ៊ុន Global Green ធ្វើអាជីវកម្មបូមខ្សាច់នេះដោយអនុវត្តតាម៖



- ប្រកាសស្តីពី លក្ខខណ្ឌនៃអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម (សម្រាប់អាជីវកម្មខ្សាច់)
- អនុវត្តតាមឃ្លងដែលបានកំណត់ដោយការសិក្សាជលវិទ្យា និងជលគតិ

ក្រុមការងារក៏បានណែនាំក្រុមហ៊ុន Global Green បន្តបូមខ្សាច់បន្តគោរពតាមច្បាប់ និងលក្ខណៈបច្ចេកទេស ដូចជា ទីតាំងបូមខ្សាច់ត្រូវធ្វើការចល័តតាមលក្ខណៈបច្ចេកទេស (ទីតាំង បូមកន្លែងនីមួយៗ មិនឱ្យលើសពី៧ថ្ងៃ) និងត្រូវមានការដាក់ពោង សញ្ញាឱ្យបានពេញលេញឡើងវិញ។ អាជ្ញាធរមូលដ្ឋានត្រូវចូលរួមតាមដានសកម្មភាពបូមខ្សាច់ជាប្រចាំ ករណីមានការប្រែប្រួល ឬមិនគោរពតាមច្បាប់ និងបច្ចេកទេស ត្រូវរាយការណ៍ មកស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់។

➢ **ស្វែងយល់ការព្រួយបារម្ភ** របស់ប្រជាពលរដ្ឋដែលរស់នៅតំបន់ធ្វើអាជីវកម្ម នៅឃុំសំបួរ ឃុំកោះរកា និងឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង របស់ក្រុមហ៊ុន Global Green និងក្រុមហ៊ុនចតុមុខ



- ✓ ប្រភពពី Facebook page Khmer times 10/09/2025 មានការបាក់ច្រាំងយ៉ាងសកម្ម
- ✓ ចុះជួបប្រជាពលរដ្ឋ និងបានទទួលការរាយការណ៍ថាមានការបូមក្បែរច្រាំង និងផ្ទះពួកគាត់។

តាមការពិនិត្យជាក់ស្តែងរបស់ក្រុមការងារលេខាធិការដ្ឋាន បើក្រុមហ៊ុន Global Green និងក្រុមហ៊ុនចតុមុខ រីសសស៍ សឹបផ្លាយ អ៊ឹមផត អិចផត ឯ.ក ធ្វើអាជីវកម្មបូមខ្សាច់នេះដោយអនុវត្តតាម៖

- ប្រកាសស្ដីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណអណ្ដូងរ៉ែបើក និងការដ្ឋានវាយថ្ម (សម្រាប់អាជីវកម្មខ្សាច់)
- អនុវត្តតាមឃ្លងដែលបានកំណត់ដោយការសិក្សាជលវិទ្យា និងជលគតិ នោះនឹងមិនមានការបាក់ស្រុតដីច្រាំងទន្លេ ដូចការព្រួយបារម្មណ៍របស់ប្រជាពលរដ្ឋទេ។




➢ **ចុះត្រួតពិនិត្យទីតាំង** ធ្វើអាជីវកម្មខ្សាច់ចំនួន៩ទីតាំង នៅឃុំការអារ និងឃុំកោគយ ស្រុកកងមាស ខេត្តកំពង់ចាម និង៣ទីតាំង នៅឃុំការកោង ស្រុកមុខកំពូល ខេត្តកណ្ដាល

✓ ការ**អនុវត្តតាមព្រំប្រទល់**ដែលអនុញ្ញាតដោយក្រសួងរ៉ែ និងថាមពល

✓ **ពុំមានការបាក់ច្រាំង**បណ្ដាលមកពីការធ្វើអាជីវកម្មនោះទេការអនុញ្ញាតស្ថិតក្រោមអាជ្ញាបណ្ណចេញដោយក្រសួងរ៉ែ និងថាមពល (អាជ្ញាបណ្ណចាស់) **ដោយពុំមានការសិក្សាជលវិទ្យា និងជលគតិ** ដូច្នោះក្រុមការងារមានការពិបាកក្នុងការត្រួតពិនិត្យជម្រៅបូមឱ្យស្របតាមបទដ្ឋានបច្ចេកទេស





➢ **ចុះត្រួតពិនិត្យទីតាំង** ធ្វើអាជីវកម្មខ្សាច់ នៅភូមិបាក់អង្រុត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង

✓ ការដ្ឋានខ្សាច់បក (9000ម$^{២}$)





✓ ការចុះពិនិត្យជាក់ស្ដែង នៅទីតាំងខាងលើដែលម្ចាស់អាជីវកម្មបានធ្វើការបូមខ្សាច់ក្នុងការធ្វើអាជីវកម្មខ្សាច់នេះ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ បានពិនិត្យឃើញថា ម្ចាស់អាជីវកម្ម បានធ្វើអាជីវកម្មប្រាស់ចាកពីអាជ្ញាបណ្ណខ្សាច់បក ដែលបានចេញដោយរដ្ឋបាលខេត្តកោះកុង។ យោងតាមការវិភាគរបស់ក្រុមការងារលេខាធិការដ្ឋាន ទៅលើរណ្ដៅខ្សាច់បកដែលនៅត្រើយម្ខាង នៃព្រែក មានទីតាំងនៅប្រមាណជា ៣៥០ ម៉ែត្រ ពីទីតាំងគំនរខ្សាច់ នៅត្រើយម្ខាងទៀត ឃើញថា ការអនុវត្តអាជីវកម្មធនធានរ៉ែខ្សាច់នេះមានភាពមិនប្រក្រតី។ ម្យ៉ាងវិញទៀត ក្រុមការងារបច្ចេកទេស ក៏បានពិនិត្យជាក់ស្ដែងពីប្រភេទខ្សាច់នៅលើគំនរ ឃើញថាជា**ប្រភេទខ្សាច់បាតព្រែក**ផងដែរ។

✓ ក្រុមការងារលេខាធិការដ្ឋានបានណែនាំម្ចាស់អាជីវកម្ម ឱ្យរក្សាបរិមាណខ្សាច់នេះទុកដោយមិនឱ្យធ្វើអាជីវកម្មចាប់តាំងពីថ្ងៃចុះទៅពិនិត្យជាក់ស្ដែងនេះ រហូតដល់មានវិធានការតាមផ្លូវច្បាប់។

✓ បានចុះហត្ថលេខាទទួលស្គាល់ នឹងរង់ចាំអនុវត្តតាមនីតិវិធីផ្លូវច្បាប់

➢ **ចុះត្រួតពិនិត្យទីតាំង**ធ្វើអាជីវកម្មខ្សាច់ នៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ

✓ ការដ្ឋានខ្សាច់បក (3507ម² ជម្រៅ1.5ម)

✓ សាឡង់បូមខ្សាច់គ្មានសកម្មភាព និងការផ្អាកសកម្មភាពធ្វើអាជីវកម្មរបស់ក្រុមហ៊ុន ហៀក ប៊ុនសុជា នៅពេលក្រុមការងាចុះទៅដល់ទីតាំង មិនមែនមកពីសាឡង់ខូច និងគ្មានការបញ្ជាទិញ នោះទេ នោះជាការបិទបាំងសកម្មភាពមិនប្រក្រតី ដែលក្រុមការងារអាចសន្និដ្ឋានបានថា ការធ្វើអាជីវកម្មខ្សាច់នេះ មិនមែនតែធ្វើអាជីវកម្មខ្សាច់បកមួយមុខទេ អាចបន្លំលាយការបូមខ្សាច់ពីបាតបឹងផងដែរ។



**វិធានការចំពោះមុខ៖**

- បានណែនាំឱ្យក្រុមហ៊ុនត្រូវគោរពតាមលក្ខខណ្ឌអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ (សម្រាប់អាជីវកម្មជីកយកខ្សាច់ ឬខ្សាច់បក)ឱ្យបានត្រឹមត្រូវ និងជាបន្ទាន់ត្រូវបោះព្រំសម្គាល់ ដែនធ្វើអាជីវកម្មឱ្យបានច្បាស់លាស់ដើម្បីក្រុមជំនាញ អាជ្ញាធរមូលដ្ឋាន និងសាធារណជនបានដឹងច្បាស់អំពីទីតាំងធ្វើអាជីវកម្មរបស់ក្រុមហ៊ុន និងត្រូវដាក់ផ្លាកសញ្ញាសំគាល់ទីតាំងស្តុកទុកខ្សាច់ឱ្យបានត្រឹមត្រូវ។
- បានណែនាំដល់ក្រុមការងាររបស់មន្ទីររ៉ែ និងថាមពល ក្រុមការងារនៃមន្ទីរជំនាញពាក់ព័ន្ធ និងអាជ្ញាធរ មូលដ្ឋានត្រូវចូលរួមសហការគ្នាតាមដានការអនុវត្តរបស់ក្រុមហ៊ុនឱ្យបានខ្ជាប់ខ្ជួន។
- ក្រុមការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់នឹងបន្តតាមដានការងារនេះបន្តទៀត។

## ៤. ផែនការសកម្មភាពសម្រាប់ឆមាសទី១ ឆ្នាំ២០២៦

ផែនការសកម្មភាពអាទិភាពសម្រាប់ឆមាសទី១ ឆ្នាំ២០២៦ មានដូចខាងក្រោម៖

### ៤.១. ថ្នាក់ដឹកនាំ

- ពង្រឹងការដឹកនាំក្រុមការងារលេខាធិការដ្ឋានដើម្បីសម្របសម្រួល និងរៀបចំដំណើរបេសកកម្ម និងកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ពង្រឹងដឹកនាំក្រុមការងារលេខាធិការដ្ឋាន ដើម្បីបំពេញការងាររបស់លេខាធិការដ្ឋាន
- បន្តបំពេញការងារផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ពង្រឹង និងពង្រីកកិច្ចសហការជាមួយអន្តរក្រសួង ដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជនលើការងារគ្រប់គ្រងធនធានខ្សាច់។

### ៤.២. ផ្នែករដ្ឋបាល

- រៀបចំបន្ទប់ការិយាល័យសម្រាប់អនុវត្តការងារប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន នៃ គ.ធ.ខ. ដែលស្ថិតនៅក្រសួងធនធានទឹក និងឧតុនិយម (លុច្ប)
- រៀបចំសម្រាប់កិច្ចប្រជុំបន្ទាប់របស់ល.គ.ធ.ខ និងគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- សហការជាមួយផ្នែកផែនការ និងផ្នែកបច្ចេកទេសក្នុងការរៀបចំការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃតំបន់ដែលកំពុងធ្វើអាជីវកម្ម។

### ៤.៣. ផ្នែកហិរញ្ញវត្ថុ

- រៀបចំគម្រោងចំណាយលើសកម្មភាពការងាររបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងលេខាធិការដ្ឋាននៃគ.ធ.ខ. ក្នុងកម្មវិធីទី៤ អនុកម្មវិធីទី២ ចង្កោមសកម្មភាពទី១ សម្រាប់ ឆ្នាំ២០២៦
- រៀបចំផែនការថវិកាសម្រាប់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ក្នុងកម្មវិធីទី៤ អនុកម្មវិធីទី២ ចង្កោមសកម្មភាពទី១ ឆ្នាំ ២០២៦

- រៀបចំសំណុំឯកសារ សម្រាប់ចំណាយការលើសកម្មភាពការងាររបស់លេខាធិការដ្ឋាន ដើម្បីដាក់ជូន ឯកឧត្តមប្រធានលេខាធិការដ្ឋានពិនិត្យ និងសម្រេច សម្រាប់ទូទាត់តាមនីតិវិធីហិរញ្ញវត្ថុ(SOP)
- រៀបចំឯកសារសម្រាប់ចូលរួមប្រជុំចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៧
- សហការជាមួយផ្នែកផែនការ និងផ្នែកបច្ចេកទេស សម្រាប់រាល់ការចំណាយក្នុងការចុះត្រួត ពិនិត្យតាមដាន និងវាយតម្លៃតំបន់ដែលកំពុងធ្វើអាជីវកម្ម។

### ៤.៤. ផ្នែកបច្ចេកទេស

- សហការជាមួយក្រសួងសាធារណៈការ និងដឹកជញ្ជូន សម្រាប់ការសិក្សាជលវិទ្យា និងជលគតិ ក្នុងការសម្រួលផ្លូវនាវាចរណ៍ ចាប់ពីការកោងដល់ទីរួមខេត្តកំពង់ចាម
- ពិភាក្សាជាមួយក្រសួងរ៉ែ និងថាមពល លើទិដ្ឋភាពបច្ចេកទេសស្តីពី របាយការណ៍សិក្សារូបសណ្ឋានបាតទន្លេមេគង្គ ចាប់ពីព្រំប្រទល់ខេត្តកំពង់ចាម ដល់ក្បែរព្រំប្រទល់កម្ពុជា-វៀតណាម ប្រវែង ២៥៨,៨គ.ម និងទន្លេបាសាក់ប្រវែង ៨៥គ.ម ដែលបានធ្វើឡើងដោយក្រុមហ៊ុន CES ដើម្បីឱ្យមានការយល់កាន់តែច្បាស់ក៏ដូចជាការស្រាយបំភ្លឺនូវចង្ងល់មួយចំនួនផងដែរ មុននឹងឈានដល់ការកំណត់ឱ្យបានច្បាស់លាស់ពីលទ្ធភាពប្រើប្រាស់ជាក់ស្តែងផ្នែកបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មខ្សាច់ និងការការពារច្រាំងទន្លេ
- ពិភាក្សាជាមួយក្រសួងរ៉ែ និងថាមពល ដើម្បីទទួលបានបច្ចុប្បន្នភាពនូវបញ្ជីរាល់បណ្តាក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មខ្សាច់ ដើម្បីសម្រួលដល់ការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ ដោយលេខាធិការដ្ឋាន និងគណៈកម្មាធិការ សម្រាប់តំបន់ដែលកំពុងធ្វើអាជីវកម្មខ្សាច់
- សហការជាមួយផ្នែកផែនការ និងរដ្ឋបាលក្នុងការរៀបចំការលើកកម្ពស់ការយល់ដឹងស្តីពី យន្តការ គ្រប់គ្រងបទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេស និងភាពចាំបាច់ក្នុងការការធ្វើអាជីវកម្មខ្សាច់ប្រកបដោយការទទួលខុសត្រូវទាំងទិដ្ឋភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន នៅតាមបណ្តារាជធានី- ខេត្ត សំខាន់ៗ ដោយមានការសហការជាមួយមន្ទីរពាក់ព័ន្ធ អាជ្ញាធរខេត្ត និងម្ចាស់អាជីវកម្មខ្សាច់។

ផែនការសកម្មភាពចុះត្រួតពិនិត្យ តាមដាន ការការធ្វើអាជីវកម្មខ្សាច់ សម្រាប់ឆមាសទី១ ឆ្នាំ២០២៦ មានដូចក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ទីតាំង | ចំនួន |
|---|---|---|---|
| ១ | ចុះសិក្សាជលវិទ្យា និងជលគតិ | ទីតាំងស្នើសុំធ្វើអាជីវកម្មខ្សាច់នាំចេញទៅក្រៅប្រទេសស្ថិតនៅតាមដងទន្លេមេគង្គ ក្នុងភូមិសាស្ត្រ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨ទីតាំង |
| | | ទីតាំងស្នើសុំធ្វើអាជីវកម្មខ្សាច់ក្នុងស្រុក ស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង | ១ទីតាំង |
| | | បណ្តាក្រុមហ៊ុនដែលចប់អាជ្ញាបណ្ណ ហើយមានបំណងបន្តអាជីវកម្ម ដោយត្រូវស្នើអាជ្ញាបណ្ណថ្មីពីក្រសួងរ៉ែ និងថាមពល ដែលទាមទារឱ្យមានការសិក្សាជលវិទ្យា និងជលគតិ | |
| ២ | ពិភាក្សាជាមួយក្រសួងរ៉ែ និងថាមពល លើការចុះសិក្សាដើម្បីកំណត់តំបន់ធ្វើអាជីវកម្មនៅតាមដងទន្លេមេគង្គ | សិក្សាកំណត់តំបន់ធ្វើអាជីវកម្មខ្សាច់ នៅតំបន់ចាប់ពីទីរួមខេត្តកំពង់ចាម ទៅផ្នែកខាងលើប្រមាណ ២០ គ.ម | |
| ៣ | សហការជាមួយផ្នែកផែនការ និងផ្នែករដ្ឋបាល ដើម្បីរៀបចំការចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃ | ទីតាំងធ្វើអាជីវកម្មខ្សាច់ស្ថិតនៅតាមដងទន្លេមេគង្គ ក្នុងភូមិសាស្ត្រខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨ទីតាំង |

| | | | |
|---|---|---|---|
| | ដោយលេខាធិការដ្ឋាន និងគណៈកម្មាធិការ សម្រាប់តំបន់ដែលកំពុងធ្វើអាជីវកម្ម | ទីតាំងធ្វើអាជីវកម្មខ្សាច់ស្ថិតនៅខេត្តកោះកុង | ២ទីតាំង |

### ៤.៥. ផ្នែកផែនការ

- សហការរៀបចំផែនការសកម្មភាព ជូនក្រុមការងារបច្ចេកទេសនៃ គ.ធ.ខ. ដើម្បីចុះធ្វើការសិក្សាជលវិទ្យា និងជលគតិលើទីតាំង ដូចខាងក្រោម៖

| ល.រ | សកម្មភាព | ទីតាំងស្នើសុំ | ចំនួន |
|---|---|---|---|
| ១ | ស្នើសុំធ្វើអាជីវកម្មខ្សាច់នាំចេញទៅក្រៅប្រទេស ស្ថិតនៅតាមដងទន្លេមេគង្គ | ខេត្តកណ្ដាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨ទីតាំង |
| ២ | ស្នើសុំធ្វើអាជីវកម្មខ្សាច់ក្នុងស្រុក | ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង | ១ទីតាំង |
| ៣ | ការធ្វើអាជីវកម្មខ្សាច់ស្ថិតនៅតាមដងទន្លេមេគង្គ | ខេត្តកណ្ដាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨ទីតាំង |
| ៤ | ការធ្វើអាជីវកម្មខ្សាច់ | ខេត្តកោះកុង | ២ទីតាំង |
| ៥ | កំណត់តំបន់ធ្វើអាជីវកម្មនៅតាមដងទន្លេមេគង្គ ដោយសិក្សាកំណត់តំបន់ធ្វើអាជីវកម្មខ្សាច់ នៅតំបន់ចាប់ពីទីរួមខេត្តកំពង់ចាម ទៅផ្នែកខាងលើប្រមាណ ២០គ.ម។ | | |

### ៤.៦. ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ

ចូលរួមកិច្ចប្រជុំ និងសកម្មភាពផ្សេងៗជាមួយផ្នែកពាក់ព័ន្ធ ព្រមទាំងត្រៀមរៀបចំផ្សព្វផ្សាយក្នុង គេហទំព័រផ្លូវការរបស់ក្រសួងធនធានទឹក និងឧតុនិយម និងលេខាធិការដ្ឋាន នូវរាល់សកម្មភាពរបស់លេខាធិការដ្ឋាន និងគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់។

## ៤. សេចក្ដីសន្និដ្ឋាន

លទ្ធផល និងវឌ្ឍនភាពការងារដែលសម្រេចបានប្រចាំឆ្នាំ២០២៥ របស់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ គឺសម្រេចបានដោយមានកិច្ចសហការល្អ និងការបំពេញឱ្យគ្នាទៅវិញទៅមកក្នុងការអនុវត្តន៍ការងារដោយបណ្ដាផ្នែកទាំង៥ នៃលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដែលបានខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ ការយកចិត្តទុកដាក់ និងវិជ្ជាជីវៈ។ ជាមួយគ្នានេះដែរ លទ្ធផលសម្រេចបានខាងលើនេះ ក៏បានមកដោយសារការយកចិត្តទុកដាក់ និងការតម្រង់ទិសពីសំណាក់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ផងដែរ។

ដើម្បីឈានទៅសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀតនាពេលខាងមុខ លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ នឹងបន្តពង្រឹង និងលើកកម្ពស់សមត្ថភាពបំពេញការងាររបស់ខ្លួន ដោយនឹងប្រកាន់ខ្ជាប់ និងយកមកអនុវត្តនូវរាល់និយាមនីតិវិធីប្រតិបត្តិ (SOP) ដែលបានបង្កើតឡើង ក៏ដូចជាផ្អែកលើឯកសារគតិយុត្តនានាជាធរមាន។

## ៥. សំណូមពរ

- ក្រសួងរ៉ែ និងថាមពល ធ្វើបច្ចុប្បន្នភាពលើទីតាំងធ្វើអាជីវកម្មខ្សាច់ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងផ្តល់មកលេខាធិការដ្ឋាននៃ គ.ធ.ខ. ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារចុះត្រួតពិនិត្យ និងតាមដាន
- មុននឹងផ្តល់អាជ្ញាបណ្ណថ្មីដល់បណ្តាក្រុមហ៊ុនអាជីវកម្មខ្សាច់ ដែលត្រូវបន្តអាជីវកម្ម ក្រសួងរ៉ែ និងថាមពល ត្រូវឱ្យក្រុមហ៊ុនអាជីវកម្មខ្សាច់ ស្នើសុំការសិក្សាជលវិទ្យា និងជលគតិ ជាមុនសិន ដើម្បីកំណត់បន្ទាត់មូលដ្ឋាន (baseline) សម្រាប់ជម្រៅនៃការបូមឱ្យស្របតាមបទដ្ឋានបច្ចេកទេស ទាំងជលវិទ្យា និងជលគតិ
- ក្រសួងរ៉ែ និងថាមពល គួរជ្រើសរើសទីតាំងអាទិភាព ដែលត្រូវធ្វើការសិក្សាជលវិទ្យា និងជលគតិ ក្នុងការកំណត់តំបន់ដែលត្រូវធ្វើអាជីវកម្មខ្សាច់
- ដើម្បីកាត់បន្ថយភាពអនាធិបតេយ្យនៃការធ្វើអាជីវកម្មខ្សាច់ ក្រសួងរ៉ែ និងថាមពល និងក្រសួងធនធានទឹក និងឧតុនិយម ត្រូវបន្តបង្កើនកិច្ចប្រឹងប្រែង និងផ្តល់ការសហការឱ្យបានជិតស្និទជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ក្នុងការលើកកម្ពស់ការយល់ដឹងស្តីពីយន្តការគ្រប់គ្រង បទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេស និងភាពចាំបាច់ក្នុងការការធ្វើអាជីវកម្មខ្សាច់ប្រកបដោយការទទួលខុសត្រូវ ទាំងទិដ្ឋភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ក្រសួងធនធានទឹក និងឧតុនិយម

Facebook: https://facebook.com/mowramcambodia

Website: https://mowram.gov.kh

Telegram: https://t.me/mowram_advertising

YouTube: https://YouTube.com/@MOWRAMofficial